ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍បូកសរុបលទ្ធផល ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ ២០២៣ និងទិសដៅអនុវត្ត ឆ្នាំ ២០២៤




អបអរសាទរ ខួបអនុស្សាវរីយ៍១០ឆ្នាំ
នៃការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
២០១៤-២០២៣

# ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា
# ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## អតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា



«រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាប្រយុទ្ធប្រឆាំងដាច់ខាត អំពើជួញដូរមនុស្ស ជាពិសេសលើស្ត្រី និងកុមារ ដោយពង្រឹងកិច្ចសហការល្អ នៅផ្ទៃក្នុងជាតិ និង ជាមួយប្រទេសនានា ក្នុងពិភពលោក ដើម្បីសន្តិសុខមនុស្សជាតិ ការគោរពសិទ្ធិមនុស្ស និងការអភិវឌ្ឍន៍ប្រទេសជាតិយើង!»

## សម្តេចក្រឡាហោម ស ខេង អតីតឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ



« ជាថ្មីម្តងទៀត ខ្ញុំសូមរំលឹក ដាស់តឿនចំពោះ មន្ត្រីរាជរដ្ឋាភិបាលទាំងឡាយ ដែលបាន និងកំពុង តែសាងបញ្ហា ឃុបឃិត និងសហការ ជាមួយ ជនល្មើសជួញដូរមនុស្ស និងអំពើពាក់ព័ន្ធទាំងឡាយ ទោះបីដោយចេតនាក្តី អចេតនាក្តី ត្រូវឆាប់ដកខ្លួន ជាបន្ទាន់ និងកែខ្លួនឲ្យបានល្អ ព្រោះមិនអាចសំងំលាក់លៀមសកម្មភាពទាំងនេះបានទៀតឡើយ ហើយនឹងត្រូវបានផ្តន្ទាទោសតាមច្បាប់ »

# សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត
# នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា



“ រាជរដ្ឋាភិបាលនីតិកាលទី៧ នៅតែបន្តការប្ដេជ្ញាចិត្តប្រឆាំងដាច់ខាតអំពើជួញដូរមនុស្ស គ្រប់ទម្រង់។ ខ្ញុំសូមអំពាវនាវ ដល់គ្រប់ភាគីពាក់ព័ន្ធជាតិ និងអន្តរជាតិ ចាំបាច់ត្រូវសហការគ្នាកាន់តែខ្លាំងដើម្បី រួមគ្នាប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន តាមដានស៊ើបអង្កេតបង្ក្រាប និងផ្ដន្ទាទោសជនល្មើសតាមច្បាប់។ ជនរងគ្រោះទាំងឡាយ ត្រូវទទួលបាននូវយុត្តិធម៌ និងការគាំពារឲ្យបានត្រឹមត្រូវ។ កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការពាក់ព័ន្ធ អាជ្ញាធរមានសមត្ថកិច្ច មន្ត្រីឈរជើងតាមព្រំដែន ត្រូវរួមកម្លាំងគ្នាគ្រប់គ្រង ត្រួតពិនិត្យលំហូរទេសន្តរប្រវេសន៍ឲ្យបានជាក់លាក់ លើកកម្ពស់ការផ្ដល់ឯកសារច្បាប់ឲ្យបានគ្រប់គ្រាន់ ឆាប់រហ័ស ងាយស្រួល និងលុបបំបាត់ប្រព័ន្ធក្រៅផ្លូវការឲ្យបានដាច់ខាត ដើម្បីការពារសុវត្ថិភាព និងផលប្រយោជន៍ជូនប្រជាពលរដ្ឋយើង។”

# ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា
# ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គ.ជ.ប.ជ



“គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងរាជរដ្ឋាភិបាល នីតិកាលទី៧នេះ បាននិងកំពុងបង្កើនការយកចិត្តទុកដាក់ ក្នុងការពង្រឹងសន្តិសុខ សុវត្ថិភាពសង្គម លើកកម្ពស់សិទ្ធិ និងផលប្រយោជន៍ជូនប្រជាពលរដ្ឋគ្រប់ស្រទាប់ គ្រប់មជ្ឈដ្ឋាន ដោយបន្តពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីជំនាញជួរមុខគ្រប់វិស័យ ដើម្បីបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងរាល់បទល្មើសក្នុងសង្គម ឧក្រិដ្ឋកម្មឆ្លងដែនគ្រប់រូបភាព ជាពិសេស អំពើជួញដូរមនុស្សគ្រប់ទំរង់ ដើម្បីកាត់បន្ថយឈានទៅលុបបំបាត់ភាពរងគ្រោះរបស់ប្រជាពលរដ្ឋ។”

# សារលិខិតថ្លែងអំណរគុណ

**សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរពរាប់អាន**

ឆ្នាំ២០២៣ ព្រះរាជាណាចក្រកម្ពុជាបានឈានចូលក្នុងបរិបទថ្មីមួយគួរឲ្យកត់សម្គាល់ ។ មិនត្រឹមតែទទួលរងផលប៉ះពាល់ជាអវិជ្ជមានពីពិភពលោក និងតំបន់ ដោយជំងឺរាតត្បាត សង្គ្រាម គ្រោះធម្មជាតិដែលកើតឡើងដោយបម្រែបម្រួលអាកាសធាតុប៉ុណ្ណោះទេ តែនៅមានការប្រកួតប្រជែងដណ្តើមឧត្តមភាពលើទីផ្សារសេដ្ឋកិច្ច ការកើនឡើងនូវបទល្មើសឆ្លងដែន និងបទល្មើសបច្ចេកវិទ្យាប្លែកៗគួរឲ្យព្រួយបារម្ភ បង្កហានិភ័យដល់ប្រជាពលរដ្ឋគ្រប់វ័យ គ្រប់ភេទ គ្រប់ស្ថានភាព ដែលធ្វើឲ្យរាជរដ្ឋាភិបាលចាំបាច់ត្រូវបង្កើនការទទួលខុសត្រូវ និងការប្រុងប្រយ័ត្នខ្ពស់ មិនអាចធ្វេសប្រហែសបាន ។

ទន្ទឹមនឹងនោះ ឆ្នាំ២០២៣ ក៏ជាឆ្នាំដែលរាជរដ្ឋាភិបាលកម្ពុជា ដល់ពេលវេលាត្រូវបញ្ចប់នីតិកាលទី៦ នៃរដ្ឋសភា ហើយត្រូវរៀបចំការបោះឆ្នោតជ្រើសរើស និងតែងតាំងរដ្ឋសភា និងរាជរដ្ឋាភិបាលនីតិកាលទី៧ តាមគោលការណ៍ច្បាប់ ។ គោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ក៏ត្រូវបានរៀបចំអភិវឌ្ឍន៍ឲ្យសមស្របទៅនឹងការវិវត្តន៍រីកចម្រើនរបស់សង្គម និងវិទ្យាសាស្ត្រ ។

ទោះបីជាកិច្ចការមមាញឹកយ៉ាងណាក្តី ក៏ការបង្ក្រាបបទល្មើស ជាពិសេសបទល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សគ្រប់ទម្រង់ នៅតែជាអាទិភាពខ្ពស់ ដែលរាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាប តាមវិធានការគ្រប់រូបភាព ដើម្បីការពារ និងថែរក្សាសន្តិសុខ សុវត្ថិភាព ជូនប្រជាពលរដ្ឋ និងប្រទេសជាតិឲ្យបានជាដាច់ខាត ។

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខ្ញុំពិតជាមានមោទកភាពចំពោះឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញគ្រប់ក្រសួង-ស្ថាប័ន អង្គភាព និងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌទាំងអស់ នៅក្នុងគណៈកម្មាធិការជាតិ និងរាជធានីខេត្ត ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលបានយកអស់កម្លាំងកាយ ចិត្ត បញ្ញា ស្មារតី បង្ការ ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រហូតធ្វើឲ្យបទល្មើសជួញដូរមនុស្ស បានថយចុះជាបណ្តើរៗ ។ ខ្ញុំសូមកោតសរសើរ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះគ្រប់កិច្ចខិតខំប្រឹងប្រែង ឆ្ពោះទៅរកទិសដៅតែមួយរួមគ្នា គឺការថែរក្សាឲ្យបាននូវសន្តិសុខជាតិ ដែលជាមូលដ្ឋានគ្រឹះនៃស្ថិរភាពនយោបាយ និងកំណើនសេដ្ឋកិច្ចជាតិ ។ ខ្ញុំក៏សូមអរគុណចំពោះគ្រប់ការចូលរួមសហការ និងឧបត្ថម្ភគាំទ្ររបស់ដៃគូជាតិ និងអន្តរជាតិ ដែលមានឆន្ទៈ និងគោលដៅដូចគ្នា និងទទួលស្គាល់ការពិត ហើយចូលរួមជួយដោយស្មោះត្រង់លើគ្រប់កិច្ចការដែលជាដំណោះស្រាយភាពប្រឈមដែលមានចំពោះមុខសម្រាប់កម្ពុជា តំបន់ និងក្នុងពិភពលោក ។

ខ្ញុំសង្ឃឹម និងជឿជាក់ថា អាស្រ័យដោយស្មារតីសាមគ្គី សហការ ប្រកបដោយឆន្ទៈ និងការទទួលខុសត្រូវបែបនេះ ព្រះរាជាណាចក្រកម្ពុជាយើង នឹងអាចធ្វើឲ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ជាតិតាមការគ្រោងទុក ។ សូមទេវតាឆ្នាំថ្មី ជួយបីបាច់ថែរក្សា សម្តេច លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា និងជនរួមជាតិទាំងអស់ ប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ថ្ងៃ ព្រហស្បតិ៍ ១២កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤

**ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**អភិសន្តិបណ្ឌិត ស សុខា**

# មាតិកា


I. ស្ថានភាពទូទៅ ...... ១

II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ...... ២

ក. ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើក កម្ពស់កិច្ចសហប្រតិបត្តិការ ...... ២

១. ការងារច្បាប់ គោលនយោបាយ សន្ធិសញ្ញា និងអនុស្សរណៈនៃការយោគយល់ ...... ២

២. ការងារច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត ...... ៣

៣. ការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិ ...... ៤

ខ. ការបង្ការ ទប់ស្កាត់ ...... ៦

១. តាមរយៈការលើកកម្ពស់ការយល់ដឹង ...... ៦

១.១. ការផ្សព្វផ្សាយដោយផ្ទាល់ ...... ៦

១.១.១. ការផ្សព្វផ្សាយតាមយុទ្ធនាការ ...... ៧

១.១.២. ការផ្សព្វផ្សាយតាមរយៈភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព និងវេទិកាសាធារណៈ ...... ៨

១.១.៣. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ ...... ១០

១.១.៤. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ ...... ១២

១.១.៥. ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC) ...... ១៣

១.២. ការផ្សព្វផ្សាយអប់រំដោយប្រយោល ...... ១៥

១.២.១. ការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយ(វិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក) ...... ១៥

២. ការបង្ការទប់ស្កាត់តាមវិធានការជំនាញ ...... ១៧

២.១. វិធានការបង្ការ ទប់ស្កាត់ ដោយការគ្រប់គ្រងចំណាកស្រុកខុសច្បាប់ ...... ១៧

២.២. ការធ្វើអធិការកិច្ច និងពង្រឹងប្រសិទ្ធភាពលើការអនុវត្តការងារ ...... ១៧

២.៣. ការគ្រប់គ្រងស្ថិតិជនបរទេស បច្ចុប្បន្នភាពចំណូលស្រុក ...... ១៧

២.៤.វិធានការគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ ...... ១៨

២.៥.វិធានការគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ ...... ២០

២.៦.ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស.២០

៣. កិច្ចការពារកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្ម ...... ២០

៤. ការលើកកម្ពស់ជីវភាព និងការផ្តល់ឱ្យមានអាជីពការងារ និងវិជ្ជាជីវៈ សម្រាប់ទីផ្សារការងារ ...... ២២

៤.១. ការផ្ដល់ព័ត៌មានការងារ និងបង្កើតកម្មវិធីសិក្សា សម្រាប់អាជីពការងារ និងវិជ្ជាជីវៈ........................២២
**គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស** ............................២៣
១. ការងារអនុវត្តច្បាប់........................................................................................២៣
១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ ...............................................................២៣
២. កិច្ចការយុត្តិធម៌..............................................................................................២៥
២.១.ចំណាត់ការផ្ដន្ទាទោស.......................................................................................២៥
**ឃ. កិច្ចការពារជនរងគ្រោះ និងការផ្ដល់សេវាគាំទ្រ** ................................................២៧
១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន(ផ្លូវគោក និងផ្លូវអាកាស)
ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ ........................................................................២៧
១.១. ការទទួល និងសម្ភាសពលរដ្ឋខ្មែរបញ្ជូនត្រឡប់ តាម ផ្លូវគោក និងផ្លូវអាកាស......................២៧
២. កិច្ចការពារជនរងគ្រោះ ការផ្ដល់សេវា និងការស្ដារនីតិសម្បទាជនរងគ្រោះដោយ
អំពើជួញដូរមនុស្ស ..........................................................................................២៩
២.១. កិច្ចការពារជនរងគ្រោះ និងការផ្ដល់សេវា ..............................................................២៩
២.២. ការស្ដារនីតិសម្បទាដល់ជនរងគ្រោះ.......................................................................២៩
៣. ការធ្វើសមាហរណកម្ម ពលរដ្ឋខ្មែរដែលជាជនរងគ្រោះ និងងាយរងគ្រោះ .............................៣០
៣.១. ការធ្វើសមាហរណកម្ម.......................................................................................៣០
៣.២. ការបិទករណី ..................................................................................................៣០
**III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល** ..................................................៣០
**ក. ការបណ្ដុះបណ្ដាល និងសិក្ខាសាលា**.....................................................................៣០
១. ការងារបណ្ដុះបណ្ដាលក្នុង និងក្រៅប្រទេស ............................................................៣០
១.១ ការងារបណ្ដុះបណ្ដាលក្នុងប្រទេស...........................................................................៣០
១.២. ការចូលរួមបណ្ដុះបណ្ដាលក្រៅប្រទេស ....................................................................៣៣
២. សិក្ខាសាលា.....................................................................................................៣៣
២.១. សិក្ខាសាលាក្នុងប្រទេស ......................................................................................៣៣
២.២. សិក្ខាសាលាក្រៅប្រទេស......................................................................................៣៥
**ខ. កិច្ចប្រជុំ សន្និសីទ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ** ..........................................៣៥
១. កិច្ចប្រជុំក្នុងប្រទេស និងក្រៅប្រទេស.......................................................................៣៥
១.១. កិច្ចប្រជុំក្នុងប្រទេស..............................................................................................៣៥

១.២. កិច្ចប្រជុំនៅក្រៅប្រទេស ..... ៣៧
**២. ទស្សនកិច្ច** ..... ៣៨
**៣. ជំនួបពិភាក្សាការងារ** ..... ៣៩
**គ. ការខារសម្របសម្រួល** ..... ៤២
**IV. ការសន្និដ្ឋានវាយតម្លៃ** ..... ៤៣
ក. ចំណុចខ្លាំង ..... ៤៣
ខ. ចំណុចខ្វះខាត ឬភាពប្រឈម ..... ៤៤
គ. សន្និដ្ឋាន និងសំណូមពរ ..... ៤៤
**V. ទិសដៅអនុវត្តបន្ត ឆ្នាំ២០២៤** ..... ៤៥
ក. ការងារច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ ..... ៤៥
ខ. ការងារបង្ការ ទប់ស្កាត់ ..... ៤៥
គ. ការងារអនុវត្តច្បាប់ និងយុត្តិធម៌ព្រហ្មទណ្ឌ ..... ៤៦
ឃ. ការងារការពារជនរងគ្រោះ ..... ៤៧
ង. ការងារពង្រឹងសមត្ថភាព និងការតាមដានត្រួតពិនិត្យ ..... ៤៨

- កម្រងរូបភាព
- ឧបសម្ព័ន្ធ

# របាយការណ៍ ឆ្នាំ២០២៣
# ស្ដីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
# និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅអនុវត្តបន្តឆ្នាំ២០២៤

## I. ស្ថានភាពទូទៅ

ឆ្នាំ២០២៣ សកលលោកបានប្រឈមនឹងវិបត្តិសាកលធំៗ ប្លែកៗ គួរឱ្យកត់សម្គាល់ រួមទាំងគ្រោះធម្មជាតិពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ ជម្ងឺរាតត្បាត វិបត្តិខ្វះស្បៀងអាហារ សង្គ្រាមពុំរ៉ៃដែលបាន និងកំពុងគម្រាមកំហែងដល់សន្តិសុខមនុស្សជាតិតាមបណ្ដាប្រទេសដែលមានខឿនឧស្សាហកម្មជឿនលឿនមួយចំនួន បានជះឥទ្ធិពលជាអវិជ្ជមានដល់សេដ្ឋកិច្ច និងសង្គមជាសកល គួរឲ្យព្រួយបារម្ភ ដែលវិបត្តិនេះ ក៏បានជះឥទ្ធិពលដល់បណ្ដាប្រទេសនានា រួមទាំងកម្ពុជាផងដែរ។ ក្នុងស្ថានភាពដ៏លំបាកនេះ ប្រជាពលរដ្ឋ តាមបណ្ដាប្រទេសនានា បានប្រឈមនឹងកង្វល់យ៉ាងធ្ងន់ធ្ងរនៃអសន្តិសុខ ក៏ដូចជាភាពស្មុគ្រស្មាញក្នុងជីវភាពរស់នៅ ដែលជាឱកាសឲ្យក្រុមទុច្ចរិតបានប្រើគ្រប់មធ្យោបាយទាញយកផលចំណេញ តាមរយៈការបង្កើតនូវបទល្មើសថ្មីៗ រួមទាំងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ ជាពិសេស ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានដ៏ទំនើប ទាក់ទាញមនុស្សគ្រប់វ័យ គ្រប់ភេទ គ្រប់ស្ថានភាព ឲ្យរងគ្រោះក្នុងកលល្បិចដ៏ពិសពុលដើម្បីបម្រើមហិច្ឆតាផលប្រយោជន៍ទុច្ចរឹតរបស់ខ្លួនយ៉ាងសាហាវឃោរឃៅ។

ដោយឡែកនៅកម្ពុជា ក្នុងឆ្នាំ២០២៣ គឺជាពេលវេលានៃការបោះឆ្នោតជាសកល ដើម្បីរៀបចំរាជរដ្ឋាភិបាលថ្មីនីតិកាលទី៧នៃរដ្ឋសភា និងបានបន្តការប្តេជ្ញាចិត្ត យកចិត្តទុកដាក់កាន់តែខ្លាំងលើកិច្ចការពារថែរក្សាសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្ដាប់ធ្នាប់ សុខសុវត្ថិភាព និងសុខុមាលភាពសង្គមឱ្យកាន់តែរឹងមាំ ព្រមទាំងការធានានូវសិទ្ធិសេរីភាពស្របច្បាប់របស់ពលរដ្ឋ ដោយផ្អែកលើរដ្ឋធម្មនុញ្ញនិងបទបញ្ញត្តិច្បាប់ជាធរមាន។ នៅក្នុងតំបន់ ព្រះរាជាណាចក្រកម្ពុជាបានរក្សាជំហរ ក្នុងការចូលរួមដោះស្រាយបញ្ហា ដោយទន់ភ្លន់ បញ្ចៀសការប្រឈមមុខដាក់គ្នា និងការពារភាពរឹងមាំនៃចំណងសាមគ្គីភាព និងកិច្ចសហប្រតិបត្តិការ។

ជាការឆ្លើយតបចំពោះការប្តេជ្ញាចិត្តខ្ពស់ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧ បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដែលក្នុងនោះ មុំទី១ បានផ្តោតលើការបន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល។ ដើម្បីពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ក្នុងនាមជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានកែសម្រួល និងបំពេញបន្ថែមសមាសភាពក្នុងរចនាសម្ព័ន្ធចាត់តាំងទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងរៀបចំផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ៥ឆ្នាំបន្ត ពីឆ្នាំ ២០២៤ ដល់ឆ្នាំ ២០២៨ បន្ថែមទៀត។

ក្នុងរយៈពេល ១២ខែ ក្នុងឆ្នាំ២០២៣ គ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព រាជធានី-ខេត្ត ជាសមាជិកនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅគ្រប់កម្រិត ដោយមានការចូលរួមគាំទ្រ និងសហការពីអង្គការដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ បានធ្វើសកម្មភាពប្រតិបត្តិការយ៉ាងសកម្ម តាមយុទ្ធសាស្ត្រទាំងបួននៃផែនការ ក៏ដូចជាតាមស្ថានភាពជាក់ស្តែង ទទួលបានលទ្ធផលដូចខាងក្រោម ៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

១. ការងារច្បាប់ គោលនយោបាយ សន្ធិសញ្ញា និងអនុស្សរណៈនៃការយោគយល់

- **ក្រសួងយុត្តិធម៌៖**
  - បន្តពិនិត្យសេចក្តីព្រាងសន្ធិសញ្ញាស្តីពី "ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" ចំនួន ០៣ច្បាប់ និង សន្ធិសញ្ញាស្តីពី "**បត្យាប័ន**" ០៣ច្បាប់ រវាងព្រះរាជាណាចក្រកម្ពុជាជាមួយនឹង៖ (១) សាធារណរដ្ឋឥណ្ឌា (២) សាធារណរដ្ឋបេឡារុស និង (៣) សាធារណរដ្ឋតួកគី។
  - បន្តពិនិត្យសេចក្តីព្រាងសន្ធិសញ្ញាស្តីពី «ការផ្ទេរទណ្ឌិត» ចំនួន០៥ច្បាប់ រវាងព្រះរាជាណាចក្រកម្ពុជា ជាមួយនឹង៖ (១)សាធារណរដ្ឋប៉េរូ (២)សាធារណរដ្ឋកូរ៉េ (៣)សាធារណរដ្ឋតួកគី (៤)សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (៥)ព្រះរាជាណាចក្របែលហ្សិក។
- **ក្រសួងមហាផ្ទៃ** បាន៖
  - ចុះអនុស្សរណៈនៃការយោគយល់ ជាមួយអង្គភាពការពារកុមារ (CPU) នៃអង្គការមូលនិធិកុមារកម្ពុជា ស្តីពីការរួមចំណែកនៅក្នុងសកម្មភាពមនុស្សធម៌ និងយុត្តិធម៌ព្រហ្មទណ្ឌ សម្រាប់អនីតិជន។
  - សហការជាមួយក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា បង្កើតសៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារកុមារសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។
- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** ៖ បាន និងកំពុងសិក្សារៀបចំសេចក្តីព្រាងច្បាប់ ស្តីពី «ទេសន្តរប្រវេសន៍ការងារកម្ពុជានៅបរទេស»។
- **អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្រសួងពាក់ព័ន្ធ** ៖ រៀបចំផែនការសកម្មភាពរួមគ្នានៃស្តង់ដារនីតិវិធីប្រតិបត្តិ ដើម្បីធ្វើសហប្រតិបត្តិការក្នុងការអនុវត្តច្បាប់ពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រវាងរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលថៃ និងត្រៀមពិភាក្សាទ្វេភាគីសម្រេចក្នុងឆ្នាំ២០២៤។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បាន៖
  - ធ្វើបច្ចុប្បន្នភាពលើនីតិវិធីប្រតិបត្តិបទដ្ឋាន(SOP) ស្តីពីការគ្រប់គ្រងករណី នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម ជនរងគ្រោះដោយអំពើជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។
  - បង្កើតសេចក្តីព្រាងច្បាប់ ស្តីពីកិច្ចការពារកុមារ ដោយយោងអនុសាសន៍របស់អង្គការសហប្រជាជាតិ ។
  - សហការជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងមានការគាំទ្រពីអង្គការ JICA អង្គការ IOM សិក្សាឡើងវិញនូវនីតិវិធីនៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដើម្បីធ្វើបច្ចុប្បន្នភាព គោលការណ៍ណែនាំ ឆ្នាំ២០១៥។
  - សហការជាមួយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងក្រសួងពាក់ព័ន្ធ សិក្សានិងរៀបចំប្រព័ន្ធបញ្ជូនថ្នាក់ជាតិករណីពាក់ព័ន្ធនឹងភាពរងគ្រោះដោយអំពើជួញដូរមនុស្ស ។
- **ក្រសួងកិច្ចការនារី** បានបន្តរៀបចំសេចក្តីព្រាង៖
  - វិសោធនកម្មអនុស្សរណៈនៃការយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងការជួញដូរមនុស្ស នៅមហាអនុតំបន់មេគង្គ(COMMIT)។

–យន្តការបញ្ជូនឆ្លងដែនមានលក្ខណៈស្តង់ដាររួមគ្នាតែមួយ និងរួមទាំងចាត់តាំងគ្រូបង្គោល របស់ប្រទេសជាសមាជិក ខមមីត(COMMIT)នីមួយៗ។

–អនុស្សរណៈនៃការយោគយល់ រវាងក្រសួងកិច្ចការនារី និងអង្គការសម្ព័ន្ធចាប់ដៃ ក្នុងគោលបំណងពង្រឹង៖ ១-ការប្រឹក្សាយោបល់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ នៅតាមសហគមន៍។ ២-កិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូ ក្នុងនិងក្រៅប្រទេស ក្នុងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ។ ៣-ការផ្តល់សេវាផ្នែកច្បាប់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ ជាពិសេសស្ត្រី និងកុមារ។

## ២. ការងារច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត

- **ក្រសួងសុខាភិបាល** បានប្រកាសដាក់ឱ្យអនុវត្តគោលនយោបាយជាតិ និងផែនការយុទ្ធសាស្ត្រជាតិ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ (២០២២-២០៣០) ដល់បណ្តាអន្តរក្រសួង ស្ថាប័នពាក់ព័ន្ធ និងទាំង២៥រាជធានី-ខេត្ត។
- **ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** បានបញ្ចប់ការរៀបចំគោលការណ៍ណែនាំ ស្តីពីកិច្ចការពារកុមារលើប្រព័ន្ធអនឡាញសម្រាប់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលនៅកម្ពុជា និងបានអនុម័តឱ្យអនុវត្តជាផ្លូវការដោយ **ឯកឧត្តមរដ្ឋមន្ត្រី** ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។
- **ក្រសួងព័ត៌មាន** បានចេញសេចក្តីសម្រេចលេខ ០១៤/២៣ សសរ ពម ស្តីពីការបង្កើតក្រុមការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស របស់ក្រសួងព័ត៌មាន។
- **បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា** សហការជាមួយ **អង្គការ IJM** ៖ ១-បានផលិតសៀវភៅលំហាត់អនុវត្តន៍ នៃរឿងក្តីជួញដូរមនុស្ស សម្រាប់កម្មវិធីបណ្តុះបណ្តាលដល់ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញាទៅតាមនីតិវិធីក្នុងបទល្មើសជួញដូរមនុស្ស។ ២-បានបញ្ចប់កំណែសេចក្តីព្រាងនៃសៀវភៅគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីសម្រាប់ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស សម្រាប់គ្រូបង្គោល។
- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ៖ (១)**ស្នើសុំសេចក្តីសម្រេចពី ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្តីពីការកែសម្រួលរចនាសម្ព័ន្ធ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈកម្មាធិការរាជធានី/ខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន **០៦**(រាជធានីភ្នំពេញ ខេត្តពោធិ៍សាត់ កំពង់ចាម ព្រៃវែង កណ្តាល និងខេត្តស្ទឹងត្រែង), **(២)**ដឹកនាំកិច្ចប្រជុំបច្ចេកទេស ថ្នាក់ជាតិ ដើម្បីពិនិត្យ និងសម្រេចផែនការជាតិសម្រាប់ការអនុវត្តនៃកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់(GCM) (៣) រៀបចំផែនការយុទ្ធសាស្ត្រជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ៥ឆ្នាំ ២០២៤-២០២៨ ។
- **រាជធានីភ្នំពេញ៖** បានចេញសេចក្តីសម្រេចលេខ ២៤៣/២៣ ស.ស.រ ស្តីពីការកែសម្រួលសមាសភាពលេខាធិការដ្ឋាន និងក្រុមការងារទាំង៦ នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.រ.ប.ជ)។
- **ខេត្តពោធិ៍សាត់៖** បានចេញសេចក្តីសម្រេច៖ **(១)**លេខ១០៥/២៣ ស.ស.រ/ខ.ព.ស ស្តីពីការកែសម្រួលសមាសភាពលេខាធិការដ្ឋាន(គ.ខ.ប.ជ)ខេត្ត, និង**(២)**-ក្រុមការងាររបស់លេខាធិការដ្ឋាន លេខ:១០៦/២៣ ស្តីពីការកែសម្រួលសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រុង/ស្រុក (ម.ក្រ. ស្រ.ប.ជ) និងឃុំ សង្កាត់ (ម.ឃ.ស.ប.ជ)។
- **ខេត្តកំពង់ចាម៖** បានចេញសេចក្តីសម្រេចលេខ ២៤២/២៣ ស.ស.រ ស្តីពីការកែសម្រួលសមាសភាពលេខាធិការដ្ឋាន និងក្រុមការងារទាំង៦ នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្ត។
- **ខេត្តកណ្តាល៖** បានចេញសេចក្តីសម្រេចលេខ ១៩៣/២៣ ស.ស.រ ស្តីពីការកែសម្រួលសមាសភាពលេខាធិការដ្ឋាន និងក្រុមការងារទាំង៦ នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្ត។

- **ខេត្តព្រៃវែង៖** បានចេញសេចក្តីសម្រេចលេខ ២៥៥/២៣ ស.ស.រ ស្តីពីការកែសម្រួលសមាសភាពលេខាធិការដ្ឋាន និងក្រុមការងារទាំង៦ នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្ត។
- **ខេត្តស្ទឹងត្រែង៖** បានចេញសេចក្តីសម្រេចលេខ ២៤៤/២៣ ស.ស.រ ស្តីពីការកែសម្រួលសមាសភាពលេខាធិការដ្ឋាន និងក្រុមការងារទាំង៦ នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្ត។

### ៣. ការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិ

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** មានកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន បានជំនួបពិភាក្សាការងារជាមួយ៖ (១) ស្នងការនគរបាលប្រទេសវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជួយសង្គ្រោះជនរងគ្រោះ នៅតាមខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម, (២)នាយកអង្គការ ASEAN-ACT ប្រចាំតំបន់ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា និងរចនាសម្ព័ន្ធ ក៏ដូចជាសកម្មភាពការងាររបស់ គ.ជ.ប.ជ និងកិច្ចសហប្រតិបត្តិការនានា ជាមួយបណ្តាអង្គការជាតិ អន្តរជាតិ និងបណ្តាប្រទេសជាមិត្តទាំងនៅក្នុងតំបន់ និងពិភពលោក, (៣)ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស នៃស្ថាប័នស៊ើបអង្កេតពិសេស (DSI) នៃរដ្ឋាភិបាលប្រទេសថៃ ពាក់ព័ន្ធនឹងស្ថានភាពនៃអំពើជួញដូរមនុស្ស និងកិច្ចសហប្រតិបត្តិការ រវាងសមត្ថកិច្ចនៃប្រទេសទាំងពីរកម្ពុជា-ថៃ, (៤)លោក David ដែលមានការិយាល័យគាំទ្រតំបន់របស់ Bali Process នៅទីក្រុងបាងកក ដើម្បីពិភាក្សាលើសេចក្តីត្រូវការក្នុងការគាំទ្រពី Bali Process ជាពិសេសការបណ្តុះបណ្តាលមន្ត្រីមានសមត្ថកិច្ច ស្តីពីជំនាញពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស, (៥)ឯកអគ្គរដ្ឋទូតជាន់ខ្ពស់ នៃសហរដ្ឋអាមេរិក ទទួលបន្ទុកកិច្ចការប្រឆាំងការជួញដូរមនុស្ស ដើម្បីសិក្សាបន្ថែមអំពីបទពិសោធការងាររបស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ និងដើម្បីធ្វើការបញ្ជាក់អំពីស្ថានភាពនៃអំពើជួញដូរមនុស្សនៅកម្ពុជា និងកិច្ចខិតខំប្រឹងប្រែង របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការឆ្លើយតបទៅនឹងបញ្ហានេះ, (៦)ប្រទេសថៃ អង្គការ UN Women និងអង្គការ ILO ដែលមានបណ្តាប្រទេសចូលរួមដូចជា កម្ពុជា ថៃ វៀតណាម ឡាវ ម៉ាឡេស៊ី ហ្វីលីពីន និងលេខាធិការដ្ឋានអាស៊ាន ក្នុងកម្មវិធីសុវត្ថិភាព និងតម្លាភាព ស្តីពីការសម្រេចសិទ្ធិ និងឱកាសរបស់ពលករទេសន្តរប្រវេសន៍ជាស្ត្រី នៅក្នុងតំបន់អាស៊ាន ដែលមានការគាំទ្រដោយសភាអ៊ឺរ៉ុប EU និងអង្គការ ILO, (៧)COMMIT វៀតណាម ជាអ្នករៀបចំសិក្ខាសាលា Consultation Workshop on Standard procedures and criteria for victim verification and identification ដែលមាន ៦ប្រទេសចូលរួមដូចមានប្រទេស (កម្ពុជា វៀតណាម ឡាវ ថៃ មីយ៉ាម៉ា និងចិន) ក្នុងនោះមានអង្គការ ILO និងអង្គការ IOM, (៨)ប្រទេសឥណ្ឌូនេស៊ី ជាអ្នករៀបចំវេទិកាអាស៊ាន ស្តីពីសិទ្ធិមនុស្សក្នុងលំហសមុទ្រ (ជានាឱ្យមានការងារសមរម្យចំពោះពលករនេសាទ ជាពិសេសជនចំណាកស្រុកជាពលករនេសាទ) ដោយមានការចូលរួមពីបណ្តាប្រទេសក្នុងអាស៊ាន ដូចជាប្រទេសថៃ កម្ពុជា វៀតណាម ឡាវ មីយ៉ាន់ម៉ា ម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងប្រទេសហ្វីលីពីន ក្នុងនោះតំណាង AICHR លេខាធិការអាស៊ាន វិស័យឯកជន ព្រមទាំងអង្គការ IOM និង IJM, (៩) ភាគីថៃដើម្បីឯកភាពបន្តលើការរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តនីតិវិធីប្រតិបត្តិការស្តង់ដារ (SOP)៖ ភាគីទាំងពីរ កម្ពុជា-ថៃ ស្តីពី «ការតាមដានករណីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ និងកិច្ចសហប្រតិបត្តិការទ្វេភាគី ក្នុងការអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្ស» ដោយផ្អែកលើនីតិវិធីចំនួនពីរ ដែលបានចុះហត្ថលេខារវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងគណៈកម្មាធិការជាតិ គ.ជ.ប.ជ កម្ពុជា ជាមួយក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្សថៃ ពីឆ្នាំ២០១៩, (១០)អង្គការដៃគូ រួមមានអង្គការ៖ ERIKS JALPEN, CHAB DAI, CARITAS SWISS, CARITAS CAMBODIA, PLAN, IJM, UNDP, AIM, RATANAK, WINROCK, APLE, HAGAR, SAMARITAN's PURSE, CPU, ASEAN-ACT, LSCW, IOM, CWCC, និង ILO ស្តីពីការពង្រឹងភាពជាដៃគូ ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស,

(១១)អង្គការ ASEAN-ACT ដែលជាអ្នកសម្របសម្រួល ទៅលើគោលដៅបណ្តាប្រទេសក្នុងតំបន់អាស៊ាន ស្តីពីការផ្តល់ជំនួយផ្នែកច្បាប់សម្រាប់ករណីជួញដូរមនុស្ស តាមរយៈប្រព័ន្ធវីដេអូហ្សូម, (១២)ជាមួយភាគីថៃ ស្តីពី «កិច្ចប្រជុំឆ្លងកាត់ព្រំដែន ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកសុខភាពជនទេសន្តរប្រវេសន៍ រវាងព្រះរាជាណាចក្រថៃ-ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ»។ (១៣)រៀបចំកិច្ចប្រជុំពិភាក្សាជាមួយអគ្គរដ្ឋទូតឥណ្ឌូនេស៊ីប្រចាំនៅកម្ពុជា ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានដឹកនាំក្រុមការងារបច្ចេកទេសធ្វើកិច្ចសហប្រតិបត្តិការជំនួបពិភាក្សាការងារៈ (១)ទ្វេភាគីកម្ពុជា-ថៃ ស្តីពីការគ្រប់គ្រងពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ចំនួន ០២លើក, (២)ប្រតិភូប្រទេសឡាវ ដើម្បីចែករំលែកបទពិសោធន៍ក្នុងការទទួល និងដោះស្រាយវិវាទទាក់ទងនឹងពលករទេសន្តរប្រវេសន៍ ការទទួលនិងការធ្វើសមាហរណកម្មពលករដែលបានវិលត្រឡប់ក្នុងអំឡុងពេល និងក្រោយពេលការរីករាលដាលជំងឺកូវីដ-១៩, (៣)រវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងធនធានមនុស្ស ស្តីពីអនុស្សរណៈនៃការយោគយល់ក្នុងការជ្រើសរើស ការប្រើប្រាស់ និងការធ្វើមាតុភូមិនិវត្តន៍របស់ពលករការងារផ្ទះ នៅប្រទេសម៉ាឡេស៊ី។ (៤)គណៈកម្មការប្រឹក្សាកម្មវិធីថ្នាក់តំបន់សម្រាប់កម្មវិធី «កាត់បន្ថយភាពក្រីក្រតាមរយៈទេសន្តរប្រវេសន៍ដោយសុវត្ថិភាព ការអភិវឌ្ឍជំនាញ និងការបង្កើនសេវាការងារធ្វើនៅក្នុងប្រទេសកម្ពុជា ឡាវ ភូមា និងប្រទេសថៃ»។
- **ក្រសួងកិច្ចការនារី** បានសហការដឹកនាំក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័នដែលជា សមាជិកនៃ គ.ជ.ប.ជ ជួបពិភាក្សាការងារជាមួយៈ (១) លោកសាស្ត្រាចារ្យ Sheldon Zhang នាយកមហាវិទ្យាល័យផ្នែកឧក្រិដ្ឋកម្ម និងយុត្តិធម៌នៃសាកលវិទ្យាល័យ University of Massachusetts និងលោកស្រី Rumi Kato Price សាស្ត្រាចារ្យមហាវិទ្យាល័យចិត្តវិទ្យា នៃមហាវិទ្យាល័យសុខាភិបាល និងសាកលវិទ្យាល័យ Washington University inSt. Louis. ដើម្បីប្រមូលទិន្នន័យរៀបចំគម្រោង ស្នើសុំថវិកាពីរដ្ឋាភិបាលសហរដ្ឋអាមេរិកពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ ការប្រែប្រួលអាកាសធាតុនៅកម្ពុជា និងការពិនិត្យលទ្ធភាពក្នុងការបង្កើតនូវប្រព័ន្ធត្រៀមបម្រុងទុកមុន ដើម្បីឆ្លើយតបនឹងអំពើជួញដូរមនុស្សនៅពេលមានវិបត្តិដូចជាគ្រោះមហន្តរាយ និងការរីករាលដាលនៃជំងឺឆ្លងជាដើម ដោយជ្រើសរើសយកខេត្តស្ថិតនៅជុំវិញ បឹងទន្លេសាបជាខេត្តគោលដៅ, (២)ជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, អង្គការអន្តរជាតិខាងការងារ (ILO) និងអង្គការសហប្រជាតិ ដើម្បីពិភាក្សាក្នុងការរៀបចំកិច្ចប្រជុំគណៈកម្មការប្រឹក្សាយោបល់ក្នុងការអនុវត្តកម្មវិធីសុវត្ថិភាព និងយុត្តិធម៌ ដើម្បីលើកកម្ពស់សិទ្ធិ និងឱកាសសម្រាប់ពលករទេសន្តរប្រវេសន៍ជាស្ត្រី នៃកម្មវិធីក្នុងតំបន់អាស៊ាន, (៣) អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) ស្តីពី «ការអភិវឌ្ឍ សូចនាករយេនឌ័រ ដើម្បីដាក់បញ្ចូលទៅក្នុងកិច្ចខិតខំប្រឹងប្រែងក្នុងការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្សក្រោមក្របខណ្ឌខមមីត» ក្នុងគោលបំណងប្រមូលធាតុចូលពីតំណាងក្រសួង ស្ថាប័ន ភាគីពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល និងការត្រៀមខ្លួនរបស់កម្ពុជាធ្វើជាម្ចាស់ផ្ទះ ដើម្បីរៀបចំកិច្ចប្រជុំថ្នាក់មហាអនុតំបន់មេគង្គប្រឆាំងអំពើជួញដូរមនុស្ស (កម្ពុជា ចិន ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម), (៤)ដឹកនាំកិច្ចប្រជុំក្រុមការងារខមមីតថ្នាក់តំបន់ (RTF) និងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ខមមីត (SOM15) ផ្អែកតាមការប្តូរវេន មានប្រទេសនៅមហាអនុតំបន់មេគង្គទាំង៦ចូលរួម គឺប្រទេសកម្ពុជា ចិន ថៃ ឡាវ មីយ៉ាន់ម៉ា និងវៀតណាម ដោយមានការគាំទ្រពី UNDP និងIOM ក្នុងគោលបំណងពិភាក្សាពី ការពន្យាពេលក្នុងការអនុវត្ត SPA-IV និងរៀបចំកសាង SPA-V កំណត់នូវសកម្មភាពជាគន្លឹះក្នុងការរៀបចំបង្កើតយន្តការបញ្ជូនឆ្លងដែន និងពង្រឹងកិច្ចសហប្រតិបត្តិការពហុភាគី ដើម្បីការពារសិទ្ធិរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្នុងចំណោមប្រទេសនៅមហាអនុតំបន់មេគង្គ រួមទាំងដំណោះស្រាយក្នុងការឆ្លើយតបទៅនឹងទម្រង់ថ្មីៗនៃអំពើជួញដូរមនុស្ស, (៥)ឯកឧត្តម

W.Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា ក្នុងគោលបំណងពិភាក្សាលើអនុសាសន៍ទាំង១៧ចំណុច ដែលបានដាក់ជូនមករាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការ និងបង្កើនប្រសិទ្ធភាព នៃការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា និងនៅក្នុងតំបន់។

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖**

  **ក**/-តាមរយៈរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក៏បានបន្តកិច្ចសហប្រតិបត្តិការជាមួយខាងភាគីនៃព្រះរាជាណាចក្រថៃ ក្នុងការដាក់ឱ្យសម្ពោធប្រើប្រាស់ជាផ្លូវការមជ្ឈមណ្ឌលស្តារនីតិសម្បទាជនរងគ្រោះ ប៉ោយប៉ែត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រធាន គ.ជ.ប.ជ**។

  **ខ**/-បានសហការជាមួយ៖ **១**-អង្គការ IOM រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ការធ្វើបច្ចុប្បន្នភាពកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម ស្តីពី«នីតិវិធីប្រតិបត្តិការបទដ្ឋាន(Sop)ក្នុងការកំណត់អត្តសញ្ញាណ ធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយ អំពើជួញដូរ»។ **២**-អង្គការអាស៊ាន-អូស្ត្រាលី ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា (ASEAN-ACT) ដើម្បីរៀបចំការវាយតម្លៃនៃវគ្គបណ្តុះបណ្តាល ស្តីពីគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ **៣**-អង្គការរតនៈអ៊ីនធើណេសិនណល និងអង្គការអាស៊ាន-អូស្ត្រាលី រៀបចំសិក្ខាសាលាផ្សព្វផ្សាយសារាចរណែនាំលេខ០១១/២២ ស្តីពីការងារសមាហរណកម្ម និងតាមដានជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទដែលស្នាក់នៅក្នុងមជ្ឈមណ្ឌលរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍។

  **គ**/-បានបន្តជួបពិភាក្សា នីតិវិធីប្រតិបត្តិបទដ្ឋាន(SOP) ស្តីពីការគ្រប់គ្រងករណី នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម ជនរងគ្រោះដោយអំពើជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ត្រូវបានចុះហត្ថលេខារួមគ្នានៅ ឆ្នាំ២០១៩។

  **ឃ**/-បានជួបពិភាក្សាកិច្ចប្រជុំទ្វេភាគីរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ស្តីពីការធ្វើបច្ចុប្បន្នភាព ផែនការសកម្មភាព (SOP) ឆ្នាំ២០២៣ -២០២៥ និងពិភាក្សាលើឧបសម្ព័ន្ធមួយចំនួនក្នុងការអនុវត្ត។

- **ខេត្តមណ្ឌលគិរី៖** ក្រុមការងារយេនឌ័រ មានកិច្ចសហការជួបពិភាក្សាជាមួយក្រុមការងារយេនឌ័រ នៅខេត្តដាក់ឡាក់ ប្រទេសវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការបង្ការ បង្ក្រាបបទល្មើសជួញដូរមនុស្ស និងការរំលោភបំពានលើស្ត្រី និងកុមារ។

- **ខេត្តតាកែវ៖** ប្រធានកិត្តិយសសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ និងប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា បានសហការជាមួយអនុប្រធានសម្ព័ន្ធសមាគមនារី និងក្រុមគ្រូពេទ្យខេត្តអានយ៉ាងនៃប្រទេសវៀតណាម រៀបចំកម្មវិធីពិគ្រោះជំងឺទូទៅ និងចែកអំណោយ ដល់ប្រជាពលរដ្ឋជាស្ត្រីក្រីក្រ និងសិស្សស្រីក្រីក្រ ដោយបានបញ្ជ្រាបការផ្សព្វផ្សាយអប់រំច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការអំពើធ្វើអាជីវកម្មផ្លូវភេទ និងការឆ្លងដែនខុសច្បាប់។

## ខ. ការបង្ការ ទប់ស្កាត់

### ១. តាមរយៈការលើកកម្ពស់ការយល់ដឹង

#### ១.១. ការផ្សព្វផ្សាយដោយផ្ទាល់

ក្នុងឆ្នាំ២០២៣ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សហការជាមួយអង្គការដៃគូបានធ្វើការផ្សព្វផ្សាយផ្ទាល់ដល់ប្រជាពលរដ្ឋ តាមរយៈវេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ទិវាជាតិអន្តរ

សាសនា យុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត និងតាមកម្មវិធីផ្សេងៗ សរុបចំនួន **១៦២.២០៧**លើក មានអ្នកចូលរួមសរុបចំនួន **៨.៩៧៨.២៨៩**នាក់ (ស្ត្រីចំនួន **៤.៥៤៥.៧៣១**នាក់) (ធៀបនឹងឆ្នាំ២០២២ មានចំនួន **៦.៤៤១.៨៧៣**នាក់) គឺមានការកើនឡើងចំនួន **២.៥៣៦.៤១៦**នាក់ ស្មើនឹង **២៨,២៥%** ដូចមានក្នុងតារាង ខាងក្រោម៖

***តារាងទិន្នន័យការផ្សព្វផ្សាយផ្ទាល់***

| ការផ្សព្វផ្សាយផ្ទាល់ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|
| ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ | ១១ | ៨.៤៣១ | ៣.៤៩០ |
| ទិវាជាតិអន្តរសាសនា | ០៣ | ៣៣៧ | ៥០ |
| យុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត | ០១ | ១.១៥០ | ៥៤៧ |
| ទិវាអន្តរជាតិ សម្រាប់ទេសន្តរប្រវេសន៍ | ០១ | ២២៨ | ៨០ |
| កម្មវិធីដង្ហែរព្យុហយាត្រា | ០១ | ៦១០ | ៣៣៣ |
| តាមរយៈភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព និងវេទិកាផ្សព្វផ្សាយសាធារណៈ | ១៥៩.៨៨៣ | ៨.៦៨០.៧៦៧ | ៤.៤៣១.៥០១ |
| តាមរយៈកម្មវិធីផ្សេងៗ (ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ) | ២.០៧៨ | ២៤៧.៩៩១ | ៩០.៥៧៤ |
| អង្គការដៃគូ | ២២៩ | ៣៨.៧៧៥ | ១៩.១៥៦ |
| **សរុប** | **១៦២.២០៧ លើក** | **៨.៩៧៨.២៨៩ នាក់** | **៤.៥៤៥.៣៧១ នាក់** |

### ១.១.១. ការផ្សព្វផ្សាយតាមយុទ្ធនាការ

❖ **ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ**

▪ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)៖**

- បានសហការជាមួយក្រសួង ស្ថាប័ន សាលារាជធានីភ្នំពេញ អង្គភាពពាក់ព័ន្ធ និងអង្គការដៃគូ មានដូចជា ERIKS, Plan International, IOM, APLE, A21, AIM, WINROCK, CHABDAI, Ratanak International, CHILD FUND, CPU, IJM, Marici, Nomi Network, ARM Cambodia, Hagar, Caristas Cambodia, Poung Studio ផលិតសម្ភារផ្សព្វផ្សាយអប់រំ
- សហការជាមួយទូរទស្សន៍បាយ័ន (BTV) ផលិតជាខ្សែវីដេអូបទយកការណ៍ ស្តីពី «ស្ថានភាពនៃអំពើជួញដូរមនុស្ស និងការឆ្លើយតបរបស់រាជរដ្ឋាភិបាលនិងប្រជាពលរដ្ឋកម្ពុជា»
- សហការជាមួយនាយកដ្ឋានទស្សនីយភាព ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ផលិត និងសម្តែងសិល្បៈចម្រុះរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីបញ្ជ្រាបការយល់ដឹងដល់អង្គពិធីទាំងមូល ក្នុងកម្មវិធីយុទ្ធនាការ នៃទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ លើកទី១៧ ឆ្នាំ២០២៣ នៅរាជធានីភ្នំពេញ អ្នកចូលរួមប្រមាណ **៣.៥០០**អង្គ/នាក់(ស្រី **១.០៣៤**នាក់) ជាថ្នាក់ដឹកនាំកំពូលសំខាន់ៗ ក្នុងស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ តុលាការ អង្គទូតនានាដែលមាននិវេសនដ្ឋាន នៅកម្ពុជា អាជ្ញាធរ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ តំណាងផ្នែកសាសនា និយោជិត កម្មករ និយោជក សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត និងសិស្សានុសិស្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គ.ជ.ប.ជ និងជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

▪ **គណៈកម្មាធិការថ្នាក់ក្រោមជាតិ៖ លេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ និងមន្ទីរអប់រំ យុវជន និងកីឡា**ខេត្តទាំង២៥រាជធានី-ខេត្ត(កោះកុង ឧត្តរមានជ័យ សៀមរាប កំពង់ធំ កំពង់ចាម ត្បូងឃ្មុំ ស្វាយរៀង ព្រៃវែង)

និងបានសហការជាមួយអង្គការដៃគូ រៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៣ និងផលិតសម្ភារផ្សព្វផ្សាយអប់រំក្នុងយុទ្ធនាការ ដែលមានអ្នកចូលរួមជាថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ មន្ទីរពាក់ព័ន្ធនានា សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត សិស្សានុសិស្ស និងប្រជាពលរដ្ឋ សរុបចំនួន **១០**លើក មនុស្សប្រមាណ **៤.៩៣១**នាក់ (ស្រី **២.៤៥៦**នាក់)។

❖ ទិវាជាតិអន្តរសាសនា

▪ **គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តស្វាយរៀង** សហការជាមួយអង្គការដៃគូ បានរៀបចំវេទិកាផ្សព្វផ្សាយអន្តរសាសនា ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមប្រធានបទ **«រួមគ្នាបញ្ឈប់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើគ្រប់រូបភាព»** ដោយមានការអញ្ជើញចូលរួម ពីព្រះមន្ត្រីសង្ឃព្រះអនុគណ ព្រះគ្រូចៅអធិការវត្ត លោកគ្រូអាចារ្យវត្ត បូជាចារ្យ គ្រូគង្វាល ថ្នាក់ដឹកនាំនៃគ្រីស្តសាសនា សាសនាមហាយាន ឥស្លាមសាសនា និងសមាគមបាហៃសាសនា ឯកឧត្តម លោកជំទាវអភិបាលរងខេត្ត លោក លោកស្រីអភិបាលរងក្រុង ស្រុក មន្ទីរពាក់ព័ន្ធនៃក្រុមការងារទាំង០៦ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ សរុបប្រមាណ **៣៣៧**អង្គ/នាក់ (ស្រី **៥០**នាក់)។

❖ យុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត

▪ **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានសហការជាមួយ**ក្រសួងអប់រំ យុវជន និងកីឡា** និង**អង្គការ APLE** បានរៀបចំកម្មវិធីយុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត ក្រោមប្រធានបទ «តោះ! នាំគ្នានិយាយអំពីការប្រើប្រាស់អ៊ីនធឺណិតប្រកបដោយសុវត្ថិភាពសម្រាប់កុមារ» ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ **តំណាងដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** ដោយមានការអញ្ជើញចូលពីតំណាងក្រសួង ស្ថាប័ន អង្គភាពជាសមាជិកក្រុមការងារបង្ការ ទប់ស្កាត់ អភិបាលរង និងប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត អង្គការអភិវឌ្ឍន៍ដៃគូជាតិ និងអន្តរជាតិ ប្រតិបត្តិករទូរគមនាគមន៍ អ្នកផលិតមាតិកា សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត និងសិស្សានុសិស្ស សរុបប្រមាណ **១.១៥០**នាក់(ស្ត្រី **៥៤៧**នាក់) នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។

❖ ទិវាអន្តរជាតិ សម្រាប់ទេសន្តរប្រវេសន៍

▪ **ក្រសួងការ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានរៀបចំទិវាអន្តរជាតិសម្រាប់ជនទេសន្តរប្រវេសន៍ ដែលមានអ្នកចូលរួមចំនួន **២២៨**នាក់ (ស្រី ៨០នាក់)។

❖ កម្មវិធីដង្ហែរព្យុហយាត្រា

▪ **ខេត្តសៀមរាប** បានសការជាមួយគណៈកម្មាធិការជាតិ គ.ជ.ប.ជ និងអង្គការមូលនិធិអេ២១ រៀបចំប្រារព្ធកម្មវិធីព្យុហយាត្រាឆ្ពោះទៅបញ្ឈប់អំពើជួញដូរមនុស្ស លើកទី២ ឆ្នាំ២០២៣ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងមានសមាសភាពអញ្ជើញចូលរួម មន្ត្រីរាជការពីបណ្តាមន្ទីរស្ថាប័នក្រោមឱវាទខេត្ត ស្រុក ក្រុង កងកម្លាំងនគរបាល កងរាជអាវុធហត្ថ លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស យុវជនកាយរិទ្ធ យុវជនកាកបាទក្រហម បុគ្គលិកអង្គការសមាគមន៍ ព្រមទាំងភ្ញៀវជាតិ និងអន្តរជាតិ សរុបប្រមាណ **៦១០**នាក់(ស្រី **៣៣៣**នាក់)។

### ១.១.២. ការផ្សព្វផ្សាយតាមរយៈភូមិឃុំ-សង្កាត់មានសុវត្ថិភាព- និងវេទិកាសាធារណៈ

ក្នុងឆ្នាំ២០២៣ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការដៃគូមួយចំនួន បានធ្វើការផ្សព្វផ្សាយផ្ទាល់ដល់ប្រជាពលរដ្ឋ រួមគ្នា និងដោយឡែកពីគ្នា

តាមរយៈវេទិកាសាធារណៈ ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព អំពើជួញដូរមនុស្ស និងតាមការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" សរុបចំនួន ១៥៩.៨៨៣លើក មានអ្នកចូលរួមសរុបចំនួន ៨.៦៨០.៧៦៧នាក់ ស្ត្រីចំនួន ៤.៤៣១.៥០១នាក់ (ធៀបនឹងឆ្នាំ២០២២ មានចំនួន **៦.០០៧.១៦៩**នាក់ គឺមានការកើនឡើងចំនួន **២.៦៧៣.៥៩៨**នាក់ ស្មើនឹង **៤៤,៥០%**) ដូចមានក្នុងតារាងខាងក្រោម៖

### តារាងទិន្នន័យផ្សព្វផ្សាយតាមរយៈភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន | ភូមិ-ឃុំមានសុវត្ថិភាព | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| **ថ្នាក់ជាតិ ក្រសួង ស្ថាប័ន** | | | | | | | |
| ១ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៤២ | ២.៦៦៨ | ១.២២៦ | | | |
| ២ | ក្រសួងកិច្ចការនារី | ០១ | ១១៩ | ៧៩ | ០២ | ២២៧ | ១២៧ |
| ៣ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និងនវានុវត្តន៍ | ០៤ | ១៥០ | ៦០ | | | |
| ៤ | កាកបាទក្រហមកម្ពុជា | ២២ | ១៦.៣៩១ | ១.៨៧០ | | | |
| ៥ | សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងការអភិវឌ្ឍន៍ថ្នាក់កណ្តាល | ៧៥ | ៦.៨០២ | ៧៤៦ | | | |
| ៦ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី | ០៦ | ៧២៦ | ៣៥៥ | | | |
| ៧ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ១.៦៣០ | ១៦២.៦៧៤ | ៨១.៧១៦ | ៧.៤៨៥ | ២៤៩.៩៥១ | ១៣៦.១៦៦ |
| **សរុប ក្រសួង ស្ថាប័ន** | | **១.៧៨០** | **១៨៩.៥៣០** | **៨៦.០៥២** | **៧.៤៨៧** | **២៥០.១៧៨** | **១៣៦.២៩៣** |
| **ថ្នាក់ក្រោមជាតិ រាជធានី-ខេត្ត** | | | | | | | |
| ១ | រាជធានីភ្នំពេញ | ២០ | ៥០២ | ៤១៥ | ១.៧៨៩ | ៦៣.៩៥៩ | ៣៧.៩១៧ |
| ២ | ខេត្តកណ្តាល | ១៥.០៩២ | ១.២៦៩.១៥៧ | ៥៩៣.៥៦១ | ១៥.៥៧៣ | ៨៩២.៣១៧ | ៣៤៩.៣៧៣ |
| ៣ | ខេត្តព្រៃវែង | ១.៤៨៤ | ១២៨.០៧៨ | ៦៣.២១២ | ២០៣ | ១០.១៧០ | ៥.៧៦៩ |
| ៤ | ខេត្តស្វាយរៀង | ៤.៥២៩ | ២៣០.៣៦៦ | ១២៧.៤៣៦ | ៣.៩០២ | ១៤០.៦៧៧ | ៧៨.៤៨៧ |
| ៥ | ខេត្តតាកែវ | ៣.៩៥០ | ១៤៥.៧២៨ | ៧៧.១១១ | ១.២១៦ | ៤២.៩៦២ | ២៣.៨២៣ |
| ៦ | ខេត្តកែប | ៣២០ | ៥៧.៨៧៨ | ២៩.៥១៦ | ៥៩៨ | ២៧.២២៧ | ១៥.២៨៦ |
| ៧ | ខេត្តកំពត | ១៣០ | ៤.៨១១ | ២.៩៩៥ | ១១២ | ២.៧៦១ | ១.៥៦២ |
| ៨ | ខេត្តព្រះសីហនុ | ៦៦៥ | ៣៤.០៩២ | ១៦.៤៥១ | ៧៦ | ៦.៦២៩ | ៣.៥៥៣ |
| ៩ | ខេត្តកោះកុង | ១.១០៥ | ២២.១៤០ | ១០.៩០៣ | ១.២១៦ | ២៥.០៤៣ | ១២.២៧៥ |
| ១០ | ខេត្តបន្ទាយមានជ័យ | ៩.៦៧៧ | ១៤៨.៩៤០ | ៨៤.០២៣ | ១.៥៦១ | ៤៥.៥២៧ | ២៦.៥៧៧ |
| ១១ | ខេត្តឧត្តរមានជ័យ | ១.៩១៨ | ១០៦.៩៦៦ | ៥៧.២៧៩ | ១៥៣ | ៧.១៨៦ | ៣.៧៣៩ |
| ១២ | ខេត្តបាត់ដំបង | ១០.៦១៧ | ៥៤១.២៣៧ | ២៨៨.៥០២ | ៧.៩៨៥ | ២៨២.៤៥៤ | ១៥១.៧៦៥ |
| ១៣ | ខេត្តប៉ៃលិន | ៨៤៨ | ១៥.៧១៥ | ៣.៧៣៤ | ៤៤៤ | ១៦.៨០៦ | ៤.១៧០៨ |
| ១៤ | ខេត្តពោធិ៍សាត់ | ៥.៧៩៧ | ៥៩៨.១៩៤ | ៣១៨.០២៦ | ២.០៧៧ | ៦៨.០៩៩ | ៣៤.៥២៨ |
| ១៥ | ខេត្តព្រះវិហារ | ១៦៨ | ៣៤.៥៧៥ | ២០.៥៤៨ | ៣៨ | ៣.២៧១ | ១.២៦២ |
| ១៦ | ខេត្តសៀមរាប | ៣.៧៤២ | ៣១៨.៧២៦ | ១៨៩.៥៥៦ | ១.៣០៨ | ៥១.៦៥៤ | ២៣.៤៩៦ |
| ១៧ | ខេត្តកំពង់ឆ្នាំង | ៩.៤១៦ | ២៥១.២៩៣ | ១១៩.៦២៩ | ៤.៤៥២ | ១១៤.៥១១ | ៦៤.៩៣៦ |
| ១៨ | ខេត្តកំពង់ស្ពឺ | ២.៩៨៥ | ១៧១.៩១៧ | ៨៧.៥២៧ | ២៥០ | ១២.៩៦០ | ៥.៦៣៥ |
| ១៩ | ខេត្តកំពង់ចាម | ២១.២១៨ | ១.២១៧.១៧៤ | ៦០៦.៥២៦ | ០៥ | ៣២៣ | ១៩៤ |
| ២០ | ខេត្តត្បូងឃ្មុំ | ១.៤៧២ | ១២៤.៣១៨ | ៩៥.៣៥៤ | ៨៩១ | ៥២.៧៧៤ | ៣៩.៧៥៧ |
| ២១ | ខេត្តកំពង់ធំ | ៥.១៨០ | ៦៨២.៥៣៤ | ៣៦២.២៩៥ | ៤១០ | ៣២.៨៦៨ | ១៤.៣១០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២២ | ខេត្តក្រចេះ | ២៧៦ | ២០.១៥៤ | ៨.១៥៤ | ១២៨ | ៥.៤៧៧ | ៣.៤៥៨ |
| ២៣ | ខេត្តស្ទឹងត្រែង | ២០ | ១.០១៤ | ៧៤០ | ០៥ | ៣៤៥ | ២៣៦ |
| ២៤ | ខេត្តរតនគិរី | ៤៧៥ | ២៤.៣០១ | ១១.៩៩៧ | ៣.៧២០ | ១៥៦.៥០៧ | ៧៩.៩៥៥ |
| ២៥ | ខេត្តមណ្ឌលគិរី | ១.១១៧ | ២១.១៦៧ | ១០.០៥១ | ២៨៣ | ៧.៥៧៥ | ៤.០៦៤ |
| **សរុប រាជធានី-ខេត្ត** | | **១០២.២២១** | **៦.១៧០.៩៧៧** | **៣.១៨៥.៥៤១** | **៤៨.៣៩៥** | **២.០៧០.០៨២** | **១.០២៣.៦១៥** |
| **សរុបរួម<br>ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត** | | **ចំនួន<br>១៥៩.៨៨៣ លើក** | | **ចំនួនមនុស្ស<br>៨.៦៨០.៧៦៧ នាក់** | | **ចំនួនស្ត្រី<br>៤.៤៣១.៥០១ នាក់** | |

### ១.១.៣. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) សហការជាមួយក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធបាន៖ ១-ផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០២២ និងទិសដៅអនុវត្តបន្ត ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ជាប្រធាន គ.ជ.ប.ជ**។ ២-បញ្ជ្រាប គុណធម៌ សីលធម៌ដោយផ្សារភ្ជាប់ព្រះពុទ្ធសាសនាទៅក្នុងសង្គម។ ៣-បញ្ជ្រាបផ្សព្វផ្សាយតាមការចាក់បញ្ចាំងភាពយន្ត និងសិល្បៈ ស្តីពីច្បាប់ទប់ស្កាត់អំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ។ ៤-ផ្សព្វផ្សាយ ស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន។ ៥-ផ្សព្វផ្សាយដល់ពលករវិលត្រឡប់ពីប្រទេសថៃ។ ៦-កម្មវិធីអបអរសាទរខួបលើកទី១១២ ទិវាអន្តរជាតិនារី ៨មីនា។ ៧-កម្មវិធីអបអរសាទរខួបទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា។ ៨-ផ្សព្វផ្សាយក្នុងពេលបើកបវេសនកាលឆ្នាំសិក្សាថ្មី។ ៩-ផ្សព្វផ្សាយក្នុងពេលចុះត្រួតពិនិត្យ នៅតាមគ្រឹះស្ថានសិក្សា រោងចក្រ សហគ្រាស និងនៅមណ្ឌលទទួលពលករ។ ១០-ផ្សព្វផ្សាយអនុក្រឹត្យ ស្តីពីការកំណត់បែបបទ និងនីតិវិធីរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរជាមួយជនបរទេស។ ១១- ផ្សព្វផ្សាយទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ នៅក្នុងវិស័យសិប្បកម្មឡឥដ្ឋ និងកសិឧស្សាហកម្ម។ សរុបចំនួន **២.២៧៧**លើក មានអ្នកចូលរួមចំនួន **២៨៦.៧៦៦**នាក់ ក្នុងនោះមានស្ត្រី **១០៩.៧៣០**នាក់ ដូចមានក្នុងតារាងខាងក្រោម៖

| **ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការដៃគូ** | **ចំនួនលើក** | **អ្នកចូលរួម** | **ស្រី** |
|---|---|---|---|
| **ថ្នាក់ជាតិ** | | | |
| គណៈកម្មាធិការជាតិ គ.ជ.ប.ជ | ០១ | ៣៦០ | ១៩៨ |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១៤ | ១.៤៨១ | ៧១៦ |
| ក្រសួងធម្មការ និងសាសនា | ៤០ | ២.៩០៤ | ១.៥៦៩ |
| ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ៣៣ | ៣៤.៨៥៤ | ១៥.៦១២ |
| កាកបាទក្រហមកម្ពុជា | ២២ | ១២.៩៧០ | ៩០៦ |
| **ថ្នាក់ក្រោមជាតិ** | | | |
| រាជធានីភ្នំពេញ | ៤៨៦ | ១.២៣១ | ៩៦៧ |
| ខេត្តបន្ទាយមានជ័យ | ៤៥ | ២.០៥៧ | ១.១០១ |
| ខេត្តបាត់ដំបង | ១០ | ៤១៤ | ១៣៣ |
| ខេត្តប៉ៃលិន | ០៦ | ៩៦៣ | ៦២០ |
| ខេត្តពោធិ៍សាត់ | ២៩ | ៥.៦៧៩ | ២.៨១២ |

| | | | |
|---|---|---|---|
| ខេត្តសៀមរាប | ១០៩ | ៣៤.៨០៤ | ១.៣០៣ |
| ខេត្តឧត្តរមានជ័យ | ០២ | ៣០៤ | ១៤៥ |
| ខេត្តកោះកុង | ៤៣ | ១៨៤ | ១៥៩ |
| ខេត្តកំពង់ធំ | ០៤ | ៤៩៩ | ២៣៤ |
| ខេត្តក្រចេះ | ២៥ | ៤.០៣៨ | ១.៣៥៣ |
| ខេត្តកំពង់ចាម | ៦២០ | ៣២.៥១៩ | ៨.១៨១ |
| ខេត្តត្បូងឃ្មុំ | ៧៩ | ៥.៦១១ | ៣.០៧៦ |
| ខេត្តកណ្ដាល | ២៣ | ២.៤៦៦ | ៦៧៨ |
| ខេត្តព្រៃវែង | ២០ | ៩.៣៦៩ | ៣.១១៨ |
| ស្វាយរៀង | ០៩ | ៩.២៧១ | ៥.៧១៤ |
| ខេត្តព្រះសីហនុ | ៦២ | ៣.៦១០ | ២.១៨៦ |
| ខេត្តតាកែវ | ២៨ | ១.១៩៤ | ១១៣ |
| ខេត្តកែប | ១៣ | ១៦៧ | ១៣៦ |
| ខេត្តរតនគិរី | ០៧ | ៧៧៦ | ២៦១ |
| ខេត្តមណ្ឌលគិរី | ១៦ | ៧៨៥ | ៥៧២ |
| ខេត្តកំពង់ឆ្នាំង | ៨៥ | ២១.២៩៣ | ១០.២២៧ |
| ខេត្តកំពង់ស្ពឺ | ២១៧ | ៥៨.១៤៨ | ២៨.៤៨៤ |
| **សរុប** | **២.០៤៨លើក** | **២៤៧.៩៩១នាក់** | **៩០.៥៧៤នាក់** |
| **អង្គការដៃគូ** | | | |
| អង្គភាពការពារកុមារ CPU (រាជធានីភ្នំពេញ) | ០៣ | ៣១៣ | ១៤០ |
| អង្គការតំណក់ទឹក(ខេត្តបន្ទាយមានជ័យ) | ១៥ | ៣៩៥ | ៣៥៧ |
| អង្គការកល្យាណមិត្ត(ខេត្តបន្ទាយមានជ័យ) | ១៩ | ២.៦៤៥ | ១.០៥៥ |
| អង្គការអន្តរ(IOM)(ខេត្តបន្ទាយមានជ័យ, ខេត្តសៀមរាប) | ១៩ | ៣.៧៣៣ | ១.៤២១ |
| អង្គការសាម៉ារីតាន់ភឺស (ខេត្តបន្ទាយមានជ័យ) | ១៥ | ១.៥៤៨ | ៨២៥ |
| អង្គការចិត្តសង្គមអន្តរវប្បធម៌(ខេត្តបន្ទាយមានជ័យ) | ២១ | ៩.១០៨ | ២.៩៨៥ |
| អង្គការ UNICEFF(ខេត្តរតនគិរី) | ០៥ | ៨.៤៥៤ | ៥.០៩៨ |
| អង្គការអន្តរជាតិ(ILO)(ខេត្តបាត់ដំបង, ខេត្តកំពង់ចាម) | ០៤ | ៥៤៣ | ១៨៦ |
| អង្គការការីតាសស្វីស (ខេត្តបាត់ដំបង) | ០១ | ៣៨៦ | ២៦៧ |
| អង្គការមូលនិធិអេ២១ (ខេត្តសៀមរាប) | ៦៥ | ៦.៨៤០ | ៣.៨២៧ |
| អង្គការជំហ៊ានដំបូងកម្ពុជា (ខេត្តសៀមរាប) | ០៦ | ១៥៦ | ៨៤ |
| អង្គការសកម្មភាពដើម្បីកុមារ (APLE) (ខេត្តសៀមរាប) | ១៥ | ១.៧២៧ | ១.០០៧ |
| អង្គការហោការអន្តរជាតិ(ខេត្តសៀមរាប) | ១៣ | ១.១៣២ | ៩១៧ |
| អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJM) (ខេត្តកំពង់ចាម) | ០១ | ៦០ | ២១ |
| អង្គការសម្ព័ន្ធចាប់ដៃ (ខេត្តកំពង់ចាម, ខេត្តត្បូងឃ្មុំ) | ០៦ | ៦៥៩ | ៤០៤ |
| អង្គការក្ដីស្រីដើម្បីអភិវឌ្ឍន៍(ខេត្តកំពង់ចាម) | ០៤ | ៣២១ | ២៣១ |
| អង្គការប្រភពទឹកនៃសេចក្ដីសង្ឃឹម | ០១ | ១៨៥ | ៤៩ |

| | | | |
|---|---|---|---|
| អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ និងអង្គការខេមរៈអភិវឌ្ឍសហគមន៍(ខេត្តកណ្ដាល, ខេត្តបន្ទាយមានជ័យ) | ១៥ | ៥១១ | ២៥៧ |
| អង្គការហ្វ្រីធូសាយ | ០១ | ៤៩ | ២៥ |
| **សរុប** | **២២៩លើក** | **៣៨.៧៧៥នាក់** | **១៩.១៥៦នាក់** |
| **សរុបរួម** | **២.២៧៧លើក** | **២៨៦.៧៦៦នាក់** | **១០៩.៧៣០នាក់** |

### ១.១.៤. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ

▪ **គណៈកម្មាធិការជាតិ គ.ជ.ប.ជ ៖** លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមជាវាគ្មិនកិត្តិយសៈ **១**-កម្មវិធីកិច្ចពិគ្រោះយោបល់លើកទី២ ជាមួយសង្គមស៊ីវិល ស្តីពីការតាមដានលើសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្ស លើរបាយការណ៍តាមកាលកំណត់លើកទី៣ រៀបចំដោយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងគណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ, **២**-ធ្វើបាឋកថា ក្នុងការចែករំលែកបទពិសោធន៍លើប្រធានបទ ស្តីពី «ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស នៅក្នុងប្រទេសកម្ពុជា» ដល់សិក្ខាកាមកម្រិត២ ជំនាន់ទី៤ មានចំនួន **៣៦១**នាក់ ស្រី **៥៧**នាក់, **៣**-កម្មវិធីសំឡេងពលរដ្ឋ នៅស្ថានីយវិទ្យុស្ត្រី ក្រោមប្រធានបទ ស្តីពី «ការទប់ស្កាត់អំពើជួញដូរស្ត្រី និងក្មេងស្រី», **៤**-សិក្ខាសាលា ស្តីពីតួនាទី នៃវិស័យវប្បធម៌ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រៀបចំដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** តំណាងក្រសួងបានចូលរួមជាវាគ្មិនៈ **១**-កម្មវិធីវិទ្យុលើប្រធានបទ «ការស្វែងរកការងារធ្វើក្រោយវិបត្តិកូវីដ-១៩» នៅស្ថានីយវិទ្យុស្ត្រី, **២**-ធ្វើបទបង្ហាញស្តីពី «ការស្នើសុំកូតាប្រើប្រាស់ហត្ថពលកម្មបរទេស និងប្រព័ន្ធគ្រប់គ្រងទិន្នន័យពលករបរទេសរបស់ប្រទេសកម្ពុជា» នៅ Singapore International Academy នៅកម្ពុជា, ៣-កម្មវិធីវិទ្យុវាយោ ក្រោមប្រធានបទ «ការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារនៅក្នុងវិស័យការងារ», ៤-សិក្ខាសាលាថ្នាក់ជាតិ សម្រាប់ប្រមូលធាតុចូលក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រង «ករណីសេវាសង្គម», ៥-សិក្ខាសាលាស្តីពី «ការលើកកម្ពស់ កិច្ចគាំពារសង្គម សម្រាប់ពលករចំណាកស្រុក», ៦-ធ្វើបទបង្ហាញអំពីបទប្បញ្ញត្តិ និងក្របខណ្ឌគោលនយោបាយ ក្នុងការការពារសិទ្ធិពលករទេសន្តប្រវេសន៍កម្ពុជា នៅក្នុងវេទិកាសង្គមស៊ីវិលថ្នាក់ជាតិស្តីពី«ការជ្រើសរើសប្រកបដោយក្រមសីលធម៌ និងការការពារសិទ្ធិពលករចំណាកស្រុកទេសន្តប្រវេសន៍កម្ពុជា», **៧**-ធ្វើបទបង្ហាញអំពីយន្តការក្នុងការទទួលពាក្យបណ្តឹងពលករទេសន្តប្រវេសន៍ នៅក្នុងកិច្ចពិគ្រោះយោបល់ស្តីពីការជំរុញឱ្យទទួលបានភាពយុត្តិធម៌ និងសំណងខូចខាតសម្រាប់ពលករទេសន្តប្រវេសន៍កម្ពុជា។

▪ **អគ្គលេខាធិការ គ.ជ.ប.ជ៖** ១-ប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះ បានចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុ FM 103.5 ក្រោមប្រធានបទវេទិកាស្ត្រីប្រចាំខែ ស្តីពីការទប់ស្កាត់អំពើជួញដូរ **២**-ប្រធានក្រុមជំនួយកិច្ចការអនុវត្តច្បាប់ បានចូលរួមជាវាគ្មិនក្នុងកិច្ចប្រជុំក្រុមការងារសហប្រតិបត្តិការអន្តរជាតិ និងក្រុមការងារខេមមីតកម្ពុជា ដោយបានធ្វើបទបង្ហាញ ស្តីពីស្ថានភាពបច្ចុប្បន្ននៃការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា, **៣**-ប្រធានក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ បានចូលរួមជាវាគ្មិន ដើម្បីចែករំលែកព័ត៌មាន គន្លឹះសំខាន់ៗជាចំណេះដឹង និងឆ្លើយតបនូវរាល់ចម្ងល់របស់អ្នកស្តាប់ ក្នុងកម្មវិធីសន្ទនាមតិ «ជីវិតយើង សង្គមយើង» នៅស្ថានីយវិទ្យុជាតិកម្ពុជា និងវិទ្យុវត្តភ្នំ ក្រោមប្រធានបទ ស្តីពី «សុវត្ថិភាពការធ្វើចំណាកស្រុកក្នុងស្រុករបស់កូនស្រី»។

▪ **ខេត្តក្រចេះ៖** តំណាងស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមជាវាគ្មិនធ្វើបទបង្ហាញលើប្រធានបទ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងកិច្ចការពារកុមារ ដល់នគរបាលជំនាន់ថ្មី ដែលទើបនឹងជ្រើសរើស ចំនួន **៧៤**នាក់ (ស្រី **២៣**នាក់)។

▪ **ខេត្តកំពង់ចាម៖** (ក)-តំណាងស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិ ក្រោមប្រធានបទស្តីពី៖ ១-ទប់ស្កាត់អំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមាតាមប្រព័ន្ធអ៊ីនធឺណែត, ២-ភាពគ្រោះថ្នាក់ក្នុងអំឡុងពេលចំណាកស្រុកដោយខុសច្បាប់, ៣-ការទប់ស្កាត់ភាពមិនប្រក្រតីក្នុងទិវាបុណ្យនៃក្តីស្រលាញ់, ៤-ការចូលរួមទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ, ៥-រួមគ្នាលុបបំបាត់ទប់ស្កាត់ការជួញដូរស្ត្រី និងកុមារគ្រប់រូបភាព, ៦-ការការពារ និងផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ (ខ)-តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួមជាវាគ្មិនកម្មវិធីសន្ទនាមតិ ក្រោមប្រធានបទស្តីពី៖ ១-ការធ្វើចំណាកស្រុកដោយសុវត្ថិភាព, ២-ការទប់ស្កាត់ពលករចំណាកស្រុក ទៅក្រៅប្រទេសដែលគ្មានឯកសារស្របច្បាប់, ៣-ការចូលរួមទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចំនួន ១០លើក។ (គ)-តំណាងមន្ទីរកិច្ចការនារីខេត្ត បានចូលរួមជាវាគ្មិន ក្រោមប្រធានបទ រួមគ្នាទប់ស្កាត់ និងលុបបំបាត់ការជួញដូរស្ត្រី និងកុមារគ្រប់រូបភាព។

▪ **ខេត្តកណ្តាល៖** ក្រុមការងារជំនាញនៃលេខាធិការដ្ឋាន គ.ខ.ប.ជ បានធ្វើជាវាគ្មិន ក្នុងវេទិកាផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងកិច្ចការពារជនរងគ្រោះ និងផលប៉ះពាល់នៃការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ចំនួន ១១លើក។

▪ **ខេត្តព្រៃវែង៖** តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរកិច្ចការនារីខេត្ត បានចូលរួមជាវាគ្មិនធ្វើបទបង្ហាញ ស្តីពី «ច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា», «កិច្ចការពារជនរងគ្រោះ និងផលប៉ះពាល់នៃអំពើជួញដូរមនុស្ស» និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ព្រមទាំងគោលនយោបាយប្រាក់សោធន ចំនួន ០៨លើក មានអ្នកចូលរួមសរុប ២៨០នាក់ (ស្រី ១៣៣នាក់)។

▪ **ខេត្តបាត់ដំបង៖** តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួមធ្វើជាវាគ្មិន៖ ១-វេទិកាផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ចំនួន ០៣លើក មានអ្នកចូលរួមចំនួន ១១៦នាក់ (ស្រី ៦៨នាក់), ២-កម្មវិធីសន្ទនាមតិ ស្តីពីការទប់ស្កាត់ការចំណាកស្រុកស្វែងរកការងារដោយខុសច្បាប់ និងស្តីពីការអន្តរាគមន៍សម្រួលដល់ពលករចំណាកស្រុកដែលចង់វិលមកចូលរួមពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរ នៅវិទ្យុជាតិចំការចេក, ៣-ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើការជួញដូរមនុស្ស និងការសម្ភាសបែបកោសល្យវិច័យ មានអ្នកចូលរួមចំនួន ៥៦នាក់ (ស្រី ៣០នាក់)។

▪ **ខេត្តព្រះវិហារ៖** តំណាងស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមជាវាគ្មិនក្នុងកម្មវិធីតាមបណ្តាញសង្គមហ្វេសប៊ុក ស្តីពីការទប់ស្កាត់អំពើកេងប្រវ័ញ្ចផ្លូវភេទ រៀបចំឡើងដោយអង្គការអាជ្រា។

▪ **ខេត្តប៉ៃលិន៖** តំណាងស្នងការដ្ឋាននគរបាល និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួមជាវាគ្មិនក្នុងវេទិកាសាធារណៈ ស្តីពីហិង្សាផ្លូវភេទ អំពើជួញដូរមនុស្ស និងសុវត្ថិភាពចំណាកស្រុក ចំនួន ០២លើក អ្នកចូលរួមចំនួន ១២០នាក់ (ស្រី ៧៣នាក់)។

▪ **ខេត្តកំពង់ធំ៖** ក្រុមការងារជំនាញនៃលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិ ស្តីពីការផ្សព្វផ្សាយច្បាប់ការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ នៅវិទ្យុជាតិ FM 98.3 MHz។

### ១.១.៥. ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC)

▪ **ក្រសួងអប់រំ យុវជន និងកីឡា** បានផលិតវីដេអូ និងការបង្រៀន មេរៀន ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស កម្រិតមធ្យមសិក្សាបឋមភូមិ ដែលមានចំនួន ១៩មេរៀន។

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានផ្សព្វផ្សាយ និងចែកខិត្តបណ្ណព័ត៌មាន ស្តីពីការធ្វើទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាពដល់ពលករទេសន្តរប្រវេសន៍ និងប្រជាពលរដ្ឋដែលមានបំណងធ្វើ

ទេសន្តរប្រវេសន៍ការងារ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច តាមរយៈមណ្ឌលធនធានពលករ (MRC) ខេត្តសៀមរាប កំពង់ធំ បាត់ដំបង កំពត និងខេត្តពោធិ៍សាត់។

▪ **ក្រសួងកិច្ចការនារី** បានផ្តល់រូបភាពសន្លឹកផ្ទាត់ ស្តីពី «ការលើកកម្ពស់សុវត្ថិភាពសម្រាប់ពលករចំណាកស្រុកជាស្ត្រី តាំងពីមុនចេញដំណើរ» ចំនួន ០៤ឈុត ដល់មន្ត្រីកិច្ចការនារីខេត្តប៉ៃលិន កំពង់ឆ្នាំង ខេត្តមណ្ឌលគិរី និងកំពង់ធំ ដើម្បីផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យបានយល់ដឹងពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងសេវាគាំទ្រផ្សេងៗ។

▪ **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** នាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌៖ ១-បញ្ចូលសារអប់រំពាក់ព័ន្ធការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ចំនួន **១៤៣**សារ ទៅក្នុងចម្រៀង និងខ្សែភាពយន្ត(CD, VCD, DVD) ស្មើនឹង **១៤៣**ទិដ្ឋាការ។ ២-ណែនាំចាងហ្វាងផលិតកម្មភាពយន្តឯកជន ឱ្យដំឡើងសារអប់រំ ស្តីពីផលប៉ះពាល់នៃអំពើជួញដូរផ្លូវភេទ ទេសន្តរប្រវេសន៍ខុសច្បាប់ អំពើពពោះជំនួស និងការជួញដូរសរីរាង្គ ទៅក្នុងផលិតផលខ្សែភាពយន្ត ចម្រៀងកាយវិការ និងចម្រៀងខារ៉ាអូខេបានចំនួន **១០៣**ផលិតកម្ម និង**២៣**ក្រុមហ៊ុន។ ៣-ផ្សព្វផ្សាយខ្សែភាពយន្តអប់រំខ្លីរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានចំណងជើងថា "Can You See Me?" នៅលើ Facebook Page របស់ក្រសួង បន្ទាប់ពីបានចូលរួមកម្មវិធីសម្ពោធខ្សែភាពយន្តនេះ ដោយទទួលបាន Viewer ចំនួន **២.២០០**, **១៩៧** Like, **៥៥** Share។

▪ **ក្រសួងព័ត៌មាន** បានសហការជាមួយក្រសួងធម្មការ និងសាសនា បញ្ច្រាបការផ្សព្វផ្សាយបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈការផលិត៖ **(១)**-DVDចំនួន **៧៥**បន្ទះជូនថ្នាក់ដឹកនាំ, **(២)-៥២៥** CDសម្លេង ជូនស្ថានីយ៍វិទ្យុ និងទូរទស្សន៍ចាក់ផ្សាយចំនួន **៣៥**ស្ថានីយ៍, **(៣)-៦៩០** DV Cams ជូនស្ថានីយ៍។

▪ **កាកបាទក្រហមកម្ពុជា** បានចែកខិត្តប័ណ្ណ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ចំនួន **១៨.៣៧០**សន្លឹក ដល់ប្រជាពលរដ្ឋនៅតាមបណ្តារាជធានី-ខេត្ត។

▪ **លេខាធិការដ្ឋាន គ.ខ.ប.ជ (ខេត្តសៀមរាប បន្ទាយមានជ័យ ឧត្តរមានជ័យ បាត់ដំបង ប៉ៃលិន ព្រះវិហារ ក្រចេះ កំពង់ចាម ត្បូងឃ្មុំ កណ្តាល ស្វាយរៀង កំពង់ធំ កំពង់ស្ពឺ ព្រៃវែង ស្ទឹងត្រែង និងខេត្តមណ្ឌលគិរី)** បានធ្វើការផ្សព្វផ្សាយអប់រំ ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំអំពើជួញដូរមនុស្សដល់ប្រជាពលរដ្ឋ នៅក្នុងពិធីបុណ្យអុំទូក អកអំបុក និងសំពះព្រះខែ ដោយបានចងបដាសរុបចំនួន **១៩៨**ផ្ទាំង ផ្ទាំងរូបភាពចំនួន **១៨២**សន្លឹក និងអាវចំនួន **២០០**អាវ។

▪ **ខេត្តសៀមរាប៖** បានចែកខិតប័ណ្ណ និងចងបដាផ្សព្វផ្សាយ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដូចជា៖ ១-លេខាធិការដ្ឋាន គ.ខ.ប.ជ, រដ្ឋបាលស្រុកពួក រដ្ឋបាលស្រុកអង្គរធំ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចែកខិតប័ណ្ណ បានចំនួន **២១.៦៧២**សន្លឹក មានអ្នកទទួល ប័ណ្ណចំនួន **១៩.៦៧៧**នាក់(ស្រី **៥.៦៤៥**នាក់) ផ្តល់ខិតប័ណ្ណព័ត៌មានតាមទូរស័ព្ទក្នុងការទំនាក់ទំនងសុំកិច្ចអន្តរគមន៍ បានចំនួន **១៧២**សន្លឹក និងផ្តល់សៀវភៅកម្រងព័ត៌មានសេវា ស្តីពីអំពើហិង្សាលើពលករចំណាកស្រុកជាស្ត្រីនៅអាស៊ាន (កម្មវិធីសុវត្ថិភាពនិងយុត្តិធម៌) ដល់រដ្ឋបាលស្រុកពួក បានចំនួន **៥០០**ក្បាល។ ២-អង្គការអេ២១ ចែករំលែកសម្ភារទាក់ទងក្នុងកម្មវិធី បានចំនួន **៤៣៥**ខិតប័ណ្ណ មនុស្សចូលរួម **៤៣៥**នាក់។ ៣-អង្គការទេសន្តរប្រវេសន៍ (IOM) បានចែកខិតប័ណ្ណ ចំនួន **១.២៥៦**សន្លឹក។

▪ **ខេត្តបន្ទាយមានជ័យ៖** លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរអង្គភាពពាក់ព័ន្ធ អាជ្ញាធរ ក្រុង ស្រុក បានសហការជាមួយអង្គការដៃគូ ផ្តល់ការអប់រំ និងចែកខិត្តប័ណ្ណផ្សព្វផ្សាយច្បាប់ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ និងតាមរយៈការចងបដា ដូចជា៖ ១-អង្គការសាម៉ារីតាន់ភឺស (Samaritan Purse) បានចែកខិត្តប័ណ្ណចំនួន **១១.៧៣៧**សន្លឹក មានអ្នកទទួលចំនួន **១១.៧៣៧**នាក់(ស្រី **៥.០០១**នាក់) កុមារ **៧៤៨**នាក់។ ២-អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) បានចែកខិត្តប័ណ្ណសរុបចំនួន **៥.៥៣០**សន្លឹក មានអ្នកទទួលចំនួន **៥.៥៣០**នាក់ (ស្ត្រី **២.១៣៤**នាក់)

កុមារ **៣៥៦**នាក់(កុមារី **១៧៥**នាក់)។ **៣**-អង្គការតំណក់ទឹក បានចុះធ្វើបណ្ណាល័យចល័ត ដើម្បីអប់រំដល់ក្រុមយុវជន និងគ្រួសារ ស្តីពីចំណាក ស្រុកប្រកបដោយសុវត្ថិភាព អ្នកចូលរួម **៤៣៥**នាក់ ស្រី **២២៣**នាក់។ **៤**-អង្គការ UNFPA ចែកខិត្តប័ណ្ណផ្សព្វផ្សាយ និងចែកកញ្ចប់យីត ចំនួន **៣.៦៧៨**យីតដល់ពលករ។ **៥**-អង្គការ UN WOMEN និងអង្គការ CWCC ចែកខិត្តប័ណ្ណផ្សព្វផ្សាយ និងចែកកញ្ចប់យីតចំនួន **៥៨៤**កញ្ចប់ដល់ពលករ។

▪ **ខេត្តបាត់ដំបង៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយអង្គការដៃគូរៀបចំកាផ្សព្វផ្សាយច្បាប់ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព កិច្ចការពារការរំលោភបំពានកុមារតាមប្រព័ន្ធអនឡាញ និងឱកាសការងារតាមរយៈចែកខិត្តប័ណ្ណ ដូចមាន៖ **១**-អង្គការសាម៉ារីតាន់ភីស៖ បានចែកខិត្តប័ណ្ណចំនួន **១៦.៨៣៩**សន្លឹក មានអ្នកទទួលចំនួន **៥.២៣០**នាក់ (ស្រី **៣.៣០០**នាក់), ចែកអាវយឺតចំនួន **២៨៣**នាក់ (ស្រី ៨៨នាក់) និងបានសហការជាមួយក្រុមយុវជន និងយុវនារី ធ្វើយុទ្ធនាការសម្តែងរឿងអប់រំខ្លីៗ ស្តីពីការចំណាកស្រុកដោយសុវត្ថិភាព ការទប់ស្កាត់ជួញដូរមនុស្ស មានអ្នកចូលរួមសរុបចំនួន **២.០៨៧**នាក់ (ស្រី **១.៤២៩**នាក់)។ **២**-អង្គការសកម្មភាពដើម្បីកុមារ (Aple) បានចែកសៀវភៅគោលការណ៍ប្រតិបត្តិបែបកុមារមេត្រីសម្រាប់សម្ភាស និងគាំទ្រកុមាររងគ្រោះ ដោយអំពើរំលោភបំពានកេងប្រវ័ញ្ចផ្លូវភេទ ចំនួន **៣២២**ក្បាល ដល់មន្ត្រីប៉ុស្តិ៍នគរបាលរដ្ឋបាល ចំនួន **២២៦**នាក់ (ស្រី **៥២**នាក់)។

▪ **ខេត្តកំពង់ចាម៖** អង្គការសម្ព័ន្ធចាប់ដៃ បានចែកខិតប័ណ្ណ ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចែកខិតប័ណ្ណចំនួន ៨០០សន្លឹក ដល់សិក្ខាកាមក្នុងវគ្គសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល។

▪ **ខេត្តត្បូងឃ្មុំ៖** ១-លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ ផ្សព្វផ្សាយខ្លឹមសារពាក់ព័ន្ធទៅនឹងការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សតាមរយៈចែកខិតប័ណ្ណចំនួន **១.៤៩៨**សន្លឹក។

▪ **ខេត្តកណ្តាល៖** គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានផ្សព្វផ្សាយខ្លឹមសារពាក់ព័ន្ធទៅនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ ក្នុងកម្មវិធីតាំងពិព័រណ៍អប់រំវិទ្យាសាស្រ្ត នៅសាលាអន្តរជាតិ វេស្ទលែនដ៍ សាខាមាត់ទន្លេតាខ្មៅ សរុបមានអ្នកចូលរួម **៤.៤៥១**នាក់ (ស្រី **២.០៩៣**នាក់)។

▪ **អង្គការជំហានដំបូងកម្ពុជា** (គម្រោងកិច្ចការពារជំនាន់ថ្មី) តាមរយៈការរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងបានបង្កើតរឿងខ្លី បានចំនួន០២លើក និងផ្សព្វផ្សាយតាមផ្ទាំងរូបភាពបានចំនួន 0៤ ស្តីពីរបៀបការពារខ្លួនពីការរំលោភបំពានផ្លូវភេទ មានអ្នកចូលរួមសរុប **១៣២**នាក់ (ស្រី **៧៣**នាក់)។

### ១.២. ការផ្សព្វផ្សាយអប់រំដោយប្រយោល

#### ១.២.១. ការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយ(វិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក)

▪ **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិ គ.ជ.ប.ជ៖**

– បានផ្តល់បទសម្ភាសន៍នៅស្ថានីយ៍ទូរទស្សន៍បាយ័ន ដោយ លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដើម្បីផលិតបទយកការណ៍ សម្រាប់ការរៀបចំទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស ថ្ងៃទី២០ខែសីហា ឆ្នាំ២០២៣ ធ្វើឡើងក្រោមប្រធានបទ «មនុស្សមានសីលធម៌ សង្គមមានសុវត្ថិភាព គ្មានអំពើជួញដូរមនុស្ស» ក្នុងគោលបំណងក្រើនរំឭកពលរដ្ឋឱ្យប្រកាន់ខ្ជាប់ក្រមសីលធម៌ និងរួមគ្នាប្រឆាំងការជួញដូរមនុស្ស និងចូលរួមផ្តល់បទសម្ភាសន៍ជាបន្តបន្ទាប់។

– ចូលរួមដឹកនាំផលិតភាពយន្តអប់រំខ្លីចំនួន០២៖ (១)រឿង «សន្យា»(PROMISED) ជារឿងអប់រំស្តីពីហានិភ័យអំពាហ៍ពិពាហ៍ទៅបរទេស និង (២) រឿង «ស្នេហាតាមអិនធ័រណេត» (LOST INNOCENT) ស្តីពីការបោកបញ្ឆោតតាមការអូសទាញរបស់ជនល្មើស កេងប្រវ័ញ្ច រំលោភបំពាន តាមប្រព័ន្ធអ៊ិនធ័រណេត ដើម្បីចូលរួមក្នុងយុទ្ធនាការ អន្តរជាតិ ប្រឆាំងការជួញដូរមនុស្ស របស់អង្គការ A21 ឈ្មោះថា "Can you See ME?" និងបានដាក់សម្ពោធផ្សព្វផ្សាយជាសាធារណៈនៅរោងភាពយន្តមួយក្នុងរាជធានីភ្នំពេញ បាន

ផ្សព្វផ្សាយក្នុងកម្មវិធី ១២ធ្នូ ឆ្នាំ២០២៣ តាមបណ្តាញផ្សព្វផ្សាយសង្គមជាច្រើន Channels និងនៅតាមវគ្គបណ្តុះបណ្តាលនានា ។

– ផលិតបទចំរៀង ចំនួន ០២បទ (បទកុំប្រថុយអី និងបទជីវិតទាសករនេសាទ) ពាក់ព័ន្ធនឹងជីវិតពលករងគ្រោះដោយត្រូវបានគេជួញដូរលើទូកនេសាទ និងបានសម្តែង នៅទិវា ១២ធ្នូ ឆ្នាំ២០២៣ និងបានផ្សព្វផ្សាយតាមបណ្តាញសង្គម ជាច្រើន Channels។
– បានផលិតសារ និងបញ្ជូនទៅតាមបណ្តាខេត្ត ឲ្យធ្វើការផ្សព្វផ្សាយតាមស្ថានីយ៍ផ្សព្វផ្សាយសាធារណៈនិងឯកជន និងបណ្តាញផ្សព្វផ្សាយសង្គម និងផលិតជាបដា សម្រាប់ការផ្សព្វផ្សាយក្នុងពិធីបុណ្យអុំទូកនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។
– ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់៖ ក/-ផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមរយៈគេហទំព័រហ្វេសប៊ុក មានការទស្សនាចំនួន ៣៤.៥២០ដង។ ខ/-សហការជាមួយនិយ័តករទូរគមនាគមន៍កម្ពុជា(TRC) ជម្រុញក្រុមហ៊ុនទូរស័ព្ទបញ្ជូនសារអប់រំ(SMS) ទៅកាន់ទូរស័ព្ទចល័ត ដើម្បីចូលរួមអបអរសាទរ៖ (១).ទិវាកុមារអន្តរជាតិ ០១មិថុនា ដែលមានខ្លឹមសារ «រាល់ទម្រង់រំលោភបំពាន និងការជួញដូរកុមារជាបទល្មើសឧក្រិដ្ឋ», (២).ទិវាជាតិអន្តរសាសនា ដែលមានខ្លឹមសារ «ទោះបីជាសាសនិកសាសនាណាក៏អាចក្លាយជាជនរងគ្រោះដោយអំពើជួញដូរមនុស្សបាន សូមកុំធ្វេសប្រហែស», (៣).ទិវាជាតិ ១២ធ្នូ ដែលមានខ្លឹមសារ «បច្ចេកវិទ្យាជាមធ្យោបាយដើម្បីអភិវឌ្ឍន៍ជាតិ មិនមែនដើម្បីជួញដូរមនុស្ស»។

▪ **ក្រសួងព័ត៌មាន៖** មន្ទីរព័ត៌មានខេត្តកំពង់ចាម បានផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើកេងប្រវ័ញ្ចរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណេត ភាពគ្រោះថ្នាក់នៃការធ្វើចំណាកស្រុកដោយខុសច្បាប់ តាមរយៈវិទ្យុជាតិភ្នំប្រុស ភ្នំស្រី និងទូរទស្សជាតិខេត្ត ហ្វេសប៊ុកផេករបស់មន្ទីរព័ត៌មាន AKP ខេត្ត។

▪ **ខេត្តឧត្តរមានជ័យ៖** មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយសារអប់រំតាមវិទ្យុបារាយណ៍អណ្តែត ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន **១២**លើក ក្នុង១ខែ។

▪ **ខេត្តសៀមរាប៖** មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុជាតិនគរភ្នំ និងទូរទស្សន៍ជាតិខេត្តសៀមរាប ស្តីពីកិច្ចការពារជនរងគ្រោះ វិធានការទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត ការស្វែងរកការងារក្នុងស្រុកជាជាងការចំណាកដោយប្រថុយប្រថាន ការស្វែងរកជំនួយពីអាជ្ញាធរ និងអង្គការសង្គមស៊ីវិល ចំនួន **១.០០៥**លើក (ផ្សាយផ្ទាល់ **៣៧០**លើក ចាក់ផ្សាយឡើងវិញ **៦៣៥**លើក)។

▪ **ខេត្តប៉ៃលិន៖** បានផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈវិទ្យុ និងទូរទស្សន៍ចំនួន **២.៩៧៦** លើក។

▪ **ខេត្តព្រៃវែង៖** មន្ទីរព័ត៌មាន បានធ្វើការផ្សព្វផ្សាយសារអប់រំតាមវិទ្យុបារាយណ៍អណ្តែត ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន **៦០០**លើក។

▪ **ខេត្តកំពង់ឆ្នាំង៖** ១-មន្ទីរអប់រំ យុវជន និងកីឡា បានបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សតាមរយៈការប្រជុំតាមប្រព័ន្ធ Telegram ឬ Google Meet ទៅដល់ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង/ស្រុកទាំង៨ ដើម្បីធ្វើការផ្សព្វផ្សាយបន្តទៅដល់ នាយក នាយិកា សិស្សានុសិស្ស នៅពេលគោរពទង់ជាតិមុនចូលរៀន និងក្នុងម៉ោងសិក្សាចំពោះមេរៀនដែលពាក់ព័ន្ធ ចំនួន **២៦**លើក។ ២-មន្ទីរកិច្ចការនារី បានធ្វើសារអប់រំ ស្តីពីការបញ្ឈប់អំពើហិង្សាក្នុងគ្រួសារ កិច្ចការពារជនរងគ្រោះ និងអំពើជួញដូរមនុស្ស តាមរយៈចាក់ផ្សាយនៅប៉ុស្តិ៍វិទ្យុព័ត៌មាន ១ថ្ងៃ/សប្តាហ៍ និង ២លើក/ថ្ងៃ។

▪ **ខេត្តកំពង់ចាម៖** លេខាធិការដ្ឋាន គ.ខ.ប.ជ ផ្សព្វផ្សាយតាមប៉ុស្តិ៍វិទ្យុ ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ២១លើក ។

▪ **ខេត្តត្បូងឃ្មុំ៖** បានធ្វើការផ្សព្វផ្សាយតាមវិទ្យុជាតិត្បូងឃ្មុំ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ចំនួន ១.៨៦០លើក។

▪ **ខេត្តព្រះសីហនុ៖** ១-ក្រុមលេខាធិការដ្ឋាន ដែលមានមន្ទីរកិច្ចការនារី សហការជាមួយក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្រុង/ស្រុក បានចុះផ្សព្វផ្សាយ ស្តីពីសុវត្ថិភាពកុមារនៅលើប្រព័ន្ធអនឡាញ ក្រោមប្រធានបទ «ស្វែងយល់ពីការប្រើប្រាស់អ៊ិនធើណែតរបស់កុមារកម្ពុជា» ចំនួន ០២លើក ដែលមានអ្នកចូលរួម ១០៦នាក់ ស្រី ៧៩នាក់។ ២-បានផ្សព្វផ្សាយតាមវិទ្យុជាតិកំពង់សោម និងវិទ្យុសឹងមាស ចំនួន ៣៦០លើក។

▪ **អង្គការមូលនិធិអេ២១** បានសហការជាមួយអង្គការ IJM ផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងតាមរយៈកម្មវិធីវិទ្យុ ស្តីពីចំណាកស្រុកប្រកបដោយសុវត្ថិភាព ចំនួន ០១លើក ដែលមានអ្នកចូលរួមស្តាប់ ចំនួន ២២០នាក់។

## ២. ការបង្ក្រាទប់ស្កាត់តាមវិធានការជំនាញ

### ២.១. វិធានការបង្ការ ទប់ស្កាត់ ដោយការគ្រប់គ្រងចំណាកស្រុកខុសច្បាប់

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ៖** កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលចំនួន ០៦ខេត្ត បានធ្វើការទប់ស្កាត់ពលករចំណាកស្រុកខុសច្បាប់ នៅតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងវៀតណាមចំនួន **២៦**លើក មនុស្សចំនួន **៦៦៤**នាក់ (ស្រី **២៥៨**នាក់) អនីតិជន **២៧**នាក់ បានធ្វើកិច្ចសន្យាការអប់រំណែនាំកុំឱ្យចំណាកស្រុកខុសច្បាប់ទៅក្រៅប្រទេសទៀត ក្នុងនោះមាន៖

- ខេត្តបន្ទាយមានជ័យ ចំនួន **១៥**លើក មនុស្សចំនួន **២២៣**នាក់ (ស្រី **៩៤**នាក់)អនីតិជន **១៨**នាក់។
- ខេត្តកោះកុង ចំនួន **០៤**លើក មនុស្សចំនួន **២២**នាក់ (ស្រី **០៩**នាក់)អនីតិជន **០៩**នាក់។
- ខេត្តបាត់ដំបង ចំនួន **០៤**លើក មនុស្សចំនួន **១៥១**នាក់ (ស្រី **៣៩**នាក់)
- ខេត្តព្រះវិហារ ចំនួន **០១**លើក មនុស្សចំនួន **០៥**នាក់ (ស្រី **០២**នាក់)
- ខេត្តត្បូងឃ្មុំ ចំនួន **០១**លើក មនុស្សចំនួន **០១**នាក់។
- ខេត្តកែប ចំនួន **០១**លើក មនុស្សចំនួន **២៦២**នាក់(ស្រី **១១៤**នាក់)

▪ **ការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ នៃគណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ** បានធ្វើការសហការ និងសម្របសម្រួលជាមួយអាជ្ញាធរថៃ ដែលបពលរដ្ឋខ្មែរឆ្លងដែនធ្វើការនៅប្រទេសថៃចំនួន **១៣០**នាក់( ស្រី **៧១**នាក់) ឱ្យបានចូលប្រទេសកម្ពុជាវិញ ដើម្បីបោះត្រាបើកប័ណ្ណព្រំដែនចេញទៅធ្វើការនៅប្រទេសថៃ។

### ២.២. ការធ្វើអធិការកិច្ច និងពង្រឹងប្រសិទ្ធភាពលើការអនុវត្តការងារ

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានត្រួតពិនិត្យលក្ខខណ្ឌការងារ និងកំណត់អត្តសញ្ញាណកម្មករនិយោជិតវ័យក្មេង តាមការស្នើសុំរបស់ក្រុមហ៊ុនចំនួន ០៩លើក ដែលមានការប្រើប្រាស់កម្មករនិយោជិតវ័យក្មេង សរុបចំនួន **៦៥**នាក់ (ស្រី **៤៧**នាក់)។

▪ **ក្រសួងអប់រំ យុវជន និងកីឡា** បានត្រួតពិនិត្យ និងតាមដាននូវការប្រើប្រាស់សៀវភៅបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស នៅវិទ្យាល័យចំនួន ០៣ មាន៖ វិទ្យាល័យ ១០មករា ១៩៧៩ វិទ្យាល័យរុនតាឯក និងវិទ្យាល័យអង្គរជំ ខេត្តសៀមរាប។

### ២.៣. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក និងចំណូលស្រុក

#### ២.៣.១. ការគ្រប់គ្រងស្ថិតិពលករខ្មែរ៖ បច្ចុប្បន្នភាពចំណាកស្រុក និងចំណូលស្រុក

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** យោងតាមតាមរបាយការណ៍ ឆ្នាំ២០២៣នេះ ពលករខ្មែរ ដែលបានបញ្ជូនទៅធ្វើការនៅបរទេស តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន និងតាមរយៈប្រព័ន្ធអនុគ្រោះមុខរបរ Employment Permit System(EPS) របស់រាជរដ្ឋាភិបាល មានចំនួនសរុប **៦០.៤៦៧**នាក់( ស្រី **២៥.២២៦**នាក់) ក្នុងនោះមាន៖

- ប្រទេសថៃ ចំនួន ៤៣.២៩១នាក់ (ស្រី ១៩.២៩១នាក់)
- សាធារណរដ្ឋកូរ៉េ ចំនួន ៩.៧៧៨នាក់ (ស្រី ២.៧១៩នាក់)
- ប្រទេសជប៉ុន ចំនួន ៧.៣០៦នាក់ (ស្រី ៣.១២៤នាក់)
- ប្រទេសសិង្ហបុរី ចំនួន ៣២នាក់ (ស្រី ៣២នាក់)
- ប្រទេសអារ៉ាប៊ីសាអូឌីត ចំនួន ៥៥នាក់ (ស្រី ៥៥នាក់)
- តំបន់រដ្ឋបាលពិសេសហុងកុង ចំនួន ០៥នាក់ (ស្រី ០៥នាក់)។

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ៖**

• **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុក ទៅក្រៅប្រទេសទាំងស្របច្បាប់ មិនស្របច្បាប់ និងដាច់ការទាក់ទងសរុប **១៨១,១៦២**នាក់(ស្រី **៨០,៣៦៧**នាក់) អនីតិជន **៣,៤៨៦**នាក់(ស្រី **១,២៧៧**នាក់)ក្នុងនោះមាន៖

- ស្របច្បាប់ **១៤០,៧៥០**នាក់(ស្រី **៦៤,៦៥១**នាក់) អនីតិជន **៣០៦**នាក់(ស្រី **៩៣**នាក់)។
- មិនស្របច្បាប់ **៣៩,៧៣៦**នាក់(ស្រី **១៥,៤២៧**នាក់)អនីតិជន **៣,០៤៥**នាក់(ស្រី **១,១៤៤**នាក់)។
- ពលករដាច់ការទាក់ទង **៦៧៦**នាក់(ស្រី **២៨៩**នាក់) អនីតិជន **១៣៥**នាក់(ស្រី **៤០**នាក់) ។

• **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ទាំង២៥** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់មកវិញដោយខ្លួនឯងពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន **៥៩.២៨៧**នាក់ (ស្រី**២៩.៩៤០**នាក់) អនីតិជន **២៣៣**នាក់ (ស្រី **៨៩**នាក់)។

### ២.៤. ការគ្រប់គ្រងស្ថិតិជនបរទេស បច្ចុប្បន្នភាពចំណូលស្រុក

▪ **អគ្គនាយកដ្ឋានអន្តោប្រវេសន៍៖**

**១-ការគ្រប់គ្រងស្ថិតិជនបរទេសចូលមកកម្ពុជាស្របច្បាប់**

**ក-គ្រប់គ្រងជនបរទេសអន្តោប្រវេសន្ត** ក្នុងឆ្នាំ២០២៣នេះ អគ្គនាយកដ្ឋានបានទទួលពាក្យ និងចេញប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ដល់ជនអន្តោប្រវេសន្តពីស្នងការដ្ឋាននគរបាលរាជធានី-ខេត្តជាបន្តបន្ទាប់ ចំនួន **២៥.៨៧៣**ច្បាប់ (ស្រី **១២.៣១៩**នាក់) ក្នុងនោះស្នើសុំប័ណ្ណលើកដំបូងចំនួន **២.១៨៣**ច្បាប់(ស្រី **១.០០៨**នាក់) បន្តលើកទី១ចំនួន **១៥.៨២៥**ច្បាប់ លើកទី២ចំនួន **៥.៦៧២**ច្បាប់ លើកទី៣ចំនួន **២.១៦១**ច្បាប់ លើកទី៤ ចំនួន **៣០**ច្បាប់ និងលើកទី ៥ ចំនួន **០២**ច្បាប់។

<u>**កត់សម្គាល់**</u>៖ បានប្រគល់ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ ជូនទៅស្នងការដ្ឋាននគរបាលចំនួន **២៥**រាជធានី-ខេត្ត សរុបចំនួន **៣៤.៧៣៥**ប័ណ្ណ (ស្រី **១៦.៦២៥**នាក់) ក្នុងនោះ៖ ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកដំបូង ចំនួន **២.៤៩៦**ប័ណ្ណ(ស្រី **១.១៨៩**នាក់)បន្តលើកទី១ ចំនួន **២២.០៣១**ប័ណ្ណ(ស្រី **១០.៦៥៥**នាក់), បន្តលើកទី២ ចំនួន **៧.៧២៧**ប័ណ្ណ(ស្រី **៣.៦១៦**នាក់), បន្តលើកទី៣ ចំនួន **២.៤៤៤**ប័ណ្ណ(ស្រី **១.១៤៩**នាក់) ,បន្តលើកទី៤ ចំនួន **៣១**ប័ណ្ណ(ស្រី **១៣**នាក់) និងបន្តលើកទី៥ ចំនួន **០៦**ប័ណ្ណ (ស្រី **០៣**នាក់)។

**ខ-គ្រប់គ្រងជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន និងហត្ថពលករបរទេស** តាមរបាយការណ៍របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) គិតត្រឹមខែធ្នូ ឆ្នាំ២០២៣ ក្រុមហ៊ុនវិនិយោគបរទេសដែលបានចុះបញ្ជីចំនួនសរុប **៣.១៣៩**ក្រុមហ៊ុន មាន៤៤សញ្ជាតិ ប្រៀបធៀបនឹងឆ្នាំ២០២២ កើនឡើងចំនួន **៩៣**ក្រុមហ៊ុន ស្មើនឹង **២,៧០%** រួមមាន៖ វិស័យកសិកម្មចំនួន **២៥៨**ក្រុមហ៊ុន មាន**១៩**សញ្ជាតិ វិស័យទេសចរណ៍ចំនួន **១២៦**ក្រុមហ៊ុន មាន **១៧**សញ្ជាតិ វិស័យហេដ្ឋារចនាសម្ព័ន្ធចំនួន **១៦២**ក្រុមហ៊ុន មាន**១៧**សញ្ជាតិ និងវិស័យរោងចក្រសហគ្រាសចំនួន **២.៥៩៣**ក្រុមហ៊ុន មាន **៤០**សញ្ជាតិ ដោយមានទុនវិនិយោគសរុបចំនួន **៤៤.៩០៦.១១៣.១៩៤**ដុល្លារ និងផ្តល់ការងារដល់ពលករ

បរទេស-ខ្មែរ សរុប ៣.២០៥.៨៧១កន្លែង។ ប្រទេសដែលមកដាក់ទុន វិនិយោគច្រើនជាងគេមានដូចជា៖ ប្រទេសចិន ចំនួន ១.៩៣១ក្រុមហ៊ុន កូរ៉េខាងត្បូង ២២៥ក្រុមហ៊ុន សិង្ហបុរី ១៤៧ក្រុមហ៊ុន និងម៉ាឡេស៊ី ១៣៥ក្រុមហ៊ុន...។

ដោយឡែកការងារអធិការកិច្ចហត្ថពលកម្មបរទេស ក្រុមការងារអធិការកិច្ចពលកម្មបរទេស នៅតាមបណ្ដាក្រុមហ៊ុន រោងចក្រសហគ្រាសនានា ក្រុមការងារទើបដំណើរការចុះនៅដើមខែឧសភា ឆ្នាំ២០២៣ប៉ុណ្ណោះ និងដោយទុកពេលវេលាឱ្យជនបរទេសទៅធ្វើប័ណ្ណការងារ។ ជាលទ្ធផលត្រួតពិនិត្យបានចំនួន ៣.៤៣៥គោលដៅ មានពលករបរទេសចំនួន ៤២.៨២៥នាក់ រកឃើញពុំមានប័ណ្ណការងារចំនួន ១៦៤នាក់ ផាកបាន ៨២.000.000រៀល។

**គ-ជនបរទេសមិនមែនអន្តោប្រវេសន្ត និងបច្ចេកវិទ្យា** ដើម្បីធានាដល់ការគ្រប់គ្រងវត្តមានជនបរទេសឱ្យកាន់តែមានប្រសិទ្ធភាព និងទទួលបាននូវប្រសិទ្ធផលស្របតាមផែនការ និងទិសដៅការងារកំណត់ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានចាត់តាំងអនុវត្តសេចក្តីណែនាំលេខ ០២៨ ស.ណ.ន របស់ក្រសួងមហាផ្ទៃ ស្តីពីការរាយការណ៍វត្តមានស្នាក់នៅរបស់ជនបរទេសតាមមូលដ្ឋាន ដោយបានខិតខំប្រឹងប្រែងរៀបចំប្រមូលផ្តុំវិធានការ ឱ្យកាន់តែមានប្រសិទ្ធភាពតាមរយៈការពិនិត្យស្នើឱ្យបំពេញអាសយដ្ឋានច្បាស់លាស់នៅក្នុងសលាកបត្រពេលមកដល់ ការពង្រឹងសំណុំឯកសារបែបបទពេលមកស្នើសុំបន្តទិដ្ឋាការស្នាក់នៅបណ្ដោះអាសន្ន និងរៀបចំប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់ជនបរទេសដោយក្នុងនោះបានផ្តល់ទិដ្ឋាការ៖ ១-ចូលប្រទេសពេលមកដល់ចំនួន ១.១៥៤.៧១៥នាក់(ក្នុងនោះទិដ្ឋាការពិសេសប្រភេទ K ចំនួន ៤០.០៣៣នាក់ ជូនពលរដ្ឋខ្មែរដែលកាន់លិខិតឆ្លងដែនបរទេស) និងផ្តល់ទិដ្ឋាការចូលតាមប្រព័ន្ធអេឡិចត្រូនិក (e_Visa) ចំនួន ៤២១.៨៥៨នាក់។ ២-ចេញចំនួន ៤.៩៣៥នាក់ (ក្នុងនោះ ទិដ្ឋាការពិសេសប្រភេទ K ចំនួន ៧១៤នាក់ ជូនពលរដ្ឋខ្មែរដែលកាន់លិខិតឆ្លងដែនបរទេស)។ ៣-បន្តរយៈពេលស្នាក់នៅបណ្តោះ អាសន្នចំនួន ៦២៦.៤៤៦នាក់។

ដោយឡែក ចំពោះអ្នកស្នាក់នៅហួសរយៈពេលកំណត់ក្នុងឆ្នាំ២០២៣នេះ មានចំនួន ២.៩២៩នាក់ មាន ៧២សញ្ជាតិ បានធ្វើការផាកពិន័យសរុបជាទឹកប្រាក់ចំនួន ៤៧២.៥៩០ដុល្លារ សម្រាប់បង់ចូលថវិកាជាតិ។

ចំពោះការងារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន អគ្គនាយកដ្ឋានបានម្ចាស់ការកសាងដោយជោគជ័យលើការងារគ្រប់គ្រងវត្តមានជនបរទេសស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហៅកាត់ថា (FPC)និងបានដាក់ឱ្យប្រើប្រាស់ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០។ ជាលទ្ធផលក្នុងឆ្នាំ២០២៣នេះ ជនបរទេសបានរាយការណ៍ពីវត្តមានស្នាក់នៅព្រះរាជាណាចក្រកម្ពុជានៅក្នុងប្រព័ន្ធ សរុបចំនួន ៧៨៥.៦៨៥នាក់(ស្រី ២៦៥.៤២១នាក់)។

**២-ការគ្រប់គ្រងស្ថិតិជនបរទេសខុសច្បាប់ និងការបង្ក្រាបបទល្មើស៖** មន្ត្រីនគរបាលអន្តោប្រវេសន៍ប្រចាំច្រកទ្វារអន្តរជាតិ រកឃើញអ្នកដំណើរមិនប្រក្រតី មានបទល្មើសសរុបចំនួន ៣.៤០៨លើក ជនល្មើសចំនួន ៤.៤១៩នាក់ ក្នុងនោះ៖

- **បទល្មើសអន្តោប្រវេសន៍** សរុបចំនួន ៣.៣៤៩លើក ជនល្មើសចំនួន៤.៣១៤នាក់ រួមមានបទល្មើស៖
  - លួចឆ្លងដែនដោយខុសច្បាប់ ១៧៩លើក ជនល្មើស ៣៥៩នាក់ មាន ១៦សញ្ជាតិ
  - ស្នាក់នៅ និងធ្វើការខុសច្បាប់ ២៤១លើក ជនល្មើស ១.០២៦នាក់ មាន ៣៤សញ្ជាតិ
  - ស្នាក់នៅលើសទិដ្ឋាការកំណត់ ២.៩២៩លើក ជនល្មើស ២.៩២៩នាក់ មាន ៧២សញ្ជាតិ។
- **បទល្មើសព្រហ្មទណ្ឌ** ចំនួន ៥៩លើក ជនល្មើសចំនួន ១០៥នាក់ ក្នុងនោះ៖
  - ឆបោកតាមប្រព័ន្ធអ៊ីនធឺណែត ៤៣លើក ជនល្មើស ៧៨នាក់ មាន ៥សញ្ជាតិ
  - ចាប់ជម្រិតមនុស្ស ០៩លើក ជនល្មើស ១៨នាក់ សញ្ជាតិ ចិន១៤នាក់ វៀតណាម ០៤នាក់
  - ជួញដូរមនុស្ស ០៤លើក ជនល្មើស ០៦នាក់ សញ្ជាតិចិន។
  - អំពើអាសលើអនិតិជន ០៣លើក ជនល្មើស ០៣នាក់ សញ្ជាតិ អាមេរិក ០២នាក់ ចិន ០១នាក់។

**៣-ការឃាត់ខ្លួន និងការបណ្តេញជនបរទេសល្មើសច្បាប់៖** បានឃាត់ខ្លួនជនបរទេស និងរៀបចំតាមនីតិវិធីបណ្តេញចេញជនបរទេសល្មើសច្បាប់ ពីព្រះរាជាណាចក្រកម្ពុជា មានចំនួន ៥១២លើក ជនល្មើសចំនួន ២.១៥៩នាក់

មាន ៣៩សញ្ជាតិ (ច្រើនជាងគេគឺជនជាតិចិន ១.០១១នាក់, ឥណ្ឌូនេស៊ី ២៦៧នាក់, វៀតណាម ៥០៧នាក់ថៃ ៦០នាក់ ,ឥណ្ឌា ៧៧នាក់, ជប៉ុន ៥៣នាក់, នីហ្សេរីយ៉ា ៣៣នាក់, ម៉ាឡេស៊ី ៣២នាក់ ,តៃវ៉ាន់ ២៤នាក់, កូរ៉េខាងត្បូង ២០នាក់ ហ្វីលីពីន ១៦នាក់, អាមេរិក ១៤នាក់ , អង់គ្លេស ១៤នាក់ និង ២៦សញ្ជាតិទៀត មានពី ០១ ដល់ ០៨នាក់)។ គិតចាប់ពីបង្កើតអគ្គនាយកដ្ឋានអន្តោប្រវេសន៍ឆ្នាំ២០១៤ មកដល់ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៣នេះ បានបណ្តេញចេញជនបរទេសខុសច្បាប់ចំនួន ២៧.៧៣៨នាក់ មានចំនួន ១០៧សញ្ជាតិ។

### ២.៥.វិធានការគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ** ៖ ស្នងការដ្ឋាននគរបាល និងកងរាជអាវុធហត្ថរាជធានី-ខេត្ត បានល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ បានចំនួន ៣១៥លើក និងធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម ដល់ម្ចាស់ជាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សាខារ៉ាអូខេ ជាប្រចាំ បានចំនួន ១.៥២០គោលដៅ មានចំនួនមនុស្សសរុប ៨.៥៦៤នាក់(ស្រី ៥.៩៥០នាក់)។

### ២.៦.ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

▪ **ក្រសួងមហាផ្ទៃ** នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើសម្ភាសពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ចំនួន ២.០០៨នាក់ ក្នុងនោះ(ស្ត្រីខ្មែរ ១.៨៤០នាក់ និងស្ត្រីបរទេស ១៦៨នាក់) មាន៣៧សញ្ជាតិ និងបានប្រមូលព័ត៌មានពីការសួរសុខទុក្ខនារីខ្មែរ ដែលរៀបការទៅរស់នៅក្រៅប្រទេសតាមរយៈទូរស័ព្ទចំនួន ៥៩នាក់ (ស្រី ៥១នាក់) មានប្រទេសកូរ៉េខាងត្បូងចំនួន ៥១នាក់(ស្រី ៤៣នាក់) និងប្រទេសចិន ០៨នាក់(ស្រី) ពួកគាត់សុខសប្បាយធម្មតាទេ។

## ៣. កិច្ចការពារកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្ម

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** ៖ (១)-បានអនុវត្តកិច្ចអន្តរាគមន៍ស្ទូលដកហូត ទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងកសិឧស្សាហកម្ម ចំនួន ៤០០ករណី និងបានបន្តនិន្តភាពកុមារ ក្នុងគម្រោងដកហូតទប់ស្កាត់ពលកម្មកុមារ ចំនួន ២០០នាក់ (ស្រី ១០០នាក់), (៤)-បានលើកបដាដែកទំហំ ៤ម x ១.៥ម ស្តីពីការហាមក្មេងចូលក្នុងបរិវេណខ្សែសង្វាក់ផលិតកម្មនៃសិប្បកម្មផលិតឥដ្ឋ នៅខេត្តកណ្តាល និងខេត្តកំពង់ធំ។

▪ **ក្រសួងឧស្សាហកម្មវិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍** បានផ្សព្វផ្សាយការទប់ស្កាត់ពលកម្មកុមារនៅក្នុងវិស័យផលិតកម្ម និងអាជីវកម្មនានា ដល់មន្ត្រីក្រោមឱវាត ដើម្បីបានផ្សព្វផ្សាយបន្តទូទាំងរាជធានី-ខេត្ត ដែលមានអ្នកចូលរួមចំនួន ៥០នាក់(ស្រី ១២នាក់)។

▪ **ខេត្តបាត់ដំបង** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត៖ ១-សហការជាមួយ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ បានបញ្ជ្រាបការផ្សព្វផ្សាយការលុបបំបាត់ពលកម្មកុមារ ក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ តាមរយៈកម្មវិធីចែកកង់ និងសម្ភារសិក្សាដល់កុមារ មានអ្នកចូលរួមចំនួន ៥២០នាក់(ស្រី ១១៣នាក់) ក្នុងនោះមានកុមារក្នុងមុខរបរផលិតកម្មដំឡូងមីចំនួន ១១១នាក់ (ស្រី ៤៨នាក់)។ ២-ចុះធ្វើបច្ចុប្បន្នភាពទិន្នន័យសិប្បកម្មផលិតឥដ្ឋបានចំនួន ១៤ សិប្បកម្មផលិតឥដ្ឋ ក្នុងស្រុក(មោងឫស្សី, ថ្មគោល, សង្កែ និងក្រុងបាត់ដំបង) ដែលមានកម្មករនិយោជិត ៤៧៥នាក់ (ស្រី ១៥៩ នាក់) ហើយមានកុមារស្នាក់នៅក្នុងសិប្បកម្មផលិតឥដ្ឋ ១៥៦ នាក់ (កុមារី ៦២នាក់) ក្នុងនោះក៏បានដកហូតកម្លាំពលកម្មកុមារ ចំនួន ០៤នាក់(កុមារី ០១នាក់)។

▪ **ខេត្តប៉ៃលិន** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត៖ ១-ចុះអធិការកិច្ចនៅតាមសហគ្រាស គ្រឹះស្ថានដែលមានការប្រើប្រាស់កម្លាំងពលកម្មដូចជា៖ សៅឡ៍ ឡឥដ្ឋ កាស៊ីណូ ភោជនីយដ្ឋាន និងអាហារដ្ឋាន ដើម្បីទប់ស្កាត់ និងលុបបំបាត់នូវពលទម្រង់ធ្ងន់ធ្ងរលើពលកម្មកុមារ បានចំនួន ១៦លើក មានកម្មករនិយោជិតសរុបចំនួន ៤៤៨នាក់ ស្រី២៤៩នាក់។ ២-បានចុះស្រង់ស្ថិតិបច្ចុប្បន្នភាពកម្មករនិយោជិតវ័យក្មេងនៅតាមសិប្បកម្មឡឥដ្ឋ និងសហគ្រាស

កសិកម្ម-ឧស្សាហកម្មបានចំនួន ០៧សហគ្រាស មានកម្មករនិយោជិតចំនួន ៤៨៧នាក់ (ស្រី ២៦៨នាក់) និងមិនបានរកឃើញកម្លាំងពលកម្មកម្មករនិយោជិតវ័យក្មេងទេ។

▪ **ខេត្តសៀមរាប៖** ១-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះផ្សព្វផ្សាយតាមដានត្រួតពិនិត្យ និងទប់ស្កាត់ពលកម្ម កុមារងាយរងគ្រោះ តាមស្រុកគោលដៅ ក្នុងវិស័យឧស្សាហកម្ម (ចំការដំឡូងមី និងសិប្បកម្មផលិតឥដ្ឋ) បានចំនួន ១៤លើកនៅតាមកសិឧស្សាហកម្មចំការដំឡូងមី និងចំការស្វាយចន្ទី ចំនួន ០៥កន្លែង ដែលមានកម្មករសរុប ៧៨នាក់ (ស្រី ៣៤នាក់) នៅសិប្បកម្មផលិតឥដ្ឋ ចំនួន ៣០កន្លែង ដែលមានកម្មករសរុប ១.៤៧៣នាក់ (ស្រី ៧០១នាក់) ក្នុងនោះកុមារដែលបានដកហូត និងធ្វើការទប់ស្កាត់សរុប ៩០នាក់ (ស្រី ៤២នាក់) ដោយបានជួយឧបត្ថម្ភសម្ភារសិក្សា សម្លៀកបំពាក់ និងកង់ ដល់កុមារមានលទ្ធភាពបន្តសិក្សា ដើម្បីទប់ស្កាត់ការបង់បង់បោះការសិក្សា និងផ្តល់ជំនាញវិជ្ជាជីវៈផ្នែកសំអាងការ ព្រមទាំងបានធ្វើកិច្ចសន្យាជាមួយអាណាព្យាបាលរបស់កុមារទាំង៩០គ្រួសារ (ទាំងគ្រួសារទប់ស្កាត់ និងគ្រួសារកុមារដកហូត)។ ២-រដ្ឋបាលស្រុកអង្គរជុំ បានសហការជាមួយអង្គការជំហ៊ានដំបូង ធ្វើការផ្សព្វផ្សាយដល់ក្លិបកុមារ ស្តីពីផលប៉ះពាល់នៃការរៀបការវ័យក្មេង ចំនួន ០២លើក មានអ្នកចូលរួមសរុប ២៤៧នាក់ ស្រី១៦២នាក់។ ៣-រដ្ឋបាលស្រុកអង្គរធំ បានចុះផ្សព្វផ្សាយអំពីផលប៉ះពាល់នៃការរៀបការវ័យក្មេង ការឧត្តម្ភសាច់ប្រាក់អត្រាថ្មីដល់ស្ត្រីមានផ្ទៃពោះ និងកុមារក្រោមអាយុ២ឆ្នាំ បានចំនួន ០២លើក មានអ្នកចូលរួមសរុប ១២៧នាក់ (ស្រី ១១០នាក់)។

▪ **ខេត្តព្រះសីហនុ៖** ផ្នែកការពារសុវត្ថិភាពកុមារ អង្គការម្លប់តាប៉ាង បានដាក់បណ្តាញម៉ូតូឌុប និងក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ បណ្តាញតាមសហគមន៍ ផ្នែកភ្នាក់ងារទេសចរណ៏សរុបចំនួន ១.១៣៣នាក់។

▪ **ខេត្តបន្ទាយមានជ័យ** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ផ្សព្វផ្សាយ៖ ១-ការទប់ស្កាត់ពលកម្មកុមារ ដល់គោលដៅ ក្រុងប៉ោយប៉ែត សួនឧស្សាហ៍កម្មក្រុងសិរីសោភ័ណ កាស៊ីណូ និងសហគ្រាស ចំនួន១៨៥កន្លែង ២-ចងបដាដែលមានខ្លឹមសារ (ហាមក្មេងចូលទៅក្នុងបរិវេណខ្សែសង្វាក់ផលិតកម្ម និងការប្រើប្រាស់ពលកម្មកុមារនៅសិប្បកម្មផលិតឥដ្ឋ គឺអាចប្រឈមនឹងទទួលខុសត្រូវចំពោះមុខច្បាប់ និងហាមឃាត់ដាច់ខាតរាល់ទម្រង់នៃការកេងប្រវ័ញ្ចពលកម្មលើកុមារ និងការបង្ខំឱ្យកុមារធ្វើការដើម្បីដោះបំណុល។

▪ **ខេត្តក្រចេះ៖** មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ខេត្ត បានបញ្ជ្រាបការផ្សព្វផ្សាយការលុបបំបាត់ពលកម្មកុមារ និងការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ នៅតាមបណ្តារោងចក្រសិប្បកម្ម ទឹកពិសារដបស្អានីយ៍ប្រេងឥន្ធនៈបានចំនួន ៧៩មូលដ្ឋាន មានបុគ្គលិកចំនួន២២៩នាក់ (ស្រី ៩៤នាក់)។ ២-មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ បានផ្សព្វផ្សាយ ស្តីពីការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមគ្រប់រូបភាព នៅតាមប្រព័ន្ធអនឡាញដល់មន្ត្រីនៅមន្ទីរប្រៃសណី និងទូរគមន៍ តាមរយៈការរៀបចំសិក្ខាសាលា, និងអាជីវករបញ្ញើប្រៃសណីយ៍ និងអាជីវករលក់ទូរស័ព្ទ សរុបបានចំនួន០៥លើក។

▪ **ខេត្តត្បូងឃ្មុំ៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយនាយកដ្ឋានការពារកុមារ បានបញ្ជ្រាបការផ្សព្វផ្សាយការលុបបំបាត់ពលកម្មកុមារ ក្នុងវិស័យសិប្បកម្មផលិត ឥដ្ឋ និងវិស័យកសិឧស្សាហកម្ម តាមរយៈកម្មវិធីចែកកង់ និងសម្ភារសិក្សាជូនដល់កុមារក្នុងគម្រោងដកហូត ទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ចំនួន ៧០នាក់ មានអ្នកចូលរួមចំនួន ២២០នាក់។

▪ **ខេត្តមណ្ឌលគិរី៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានផ្សព្វផ្សាយការលុបបំបាត់ពលកម្មកុមារ ក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងវិស័យកសិឧស្សាហកម្ម បានចំនួន ០៣ទីតាំង មានអ្នកចូលរួមចំនួន ១៣៥នាក់ (ស្រី ៥៦នាក់)។

## ៤. ការលើកកម្ពស់ជីវភាព និងការផ្ដល់ឱ្យមានអាជីពការងារ និងវិជ្ជាជីវៈ សម្រាប់ទីផ្សារការងារ

### ៤.១. ការផ្ដល់ព័ត៌មានការងារ និងបង្កើតកម្មវិធីសិក្សា សម្រាប់អាជីពការងារ និងវិជ្ជាជីវៈ

❖ **ថ្នាក់ជាតិ៖**

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** ៖ បានពង្រឹង និងបង្កើនការផ្សព្វផ្សាយអំពីវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ៖ (១)-រៀបចំវគ្គណែនាំតម្រង់ទិសពលករមុនពេលចេញដំណើរ ទៅបរទេស ចំនួន ១ ៣២៨លើក ដែលមានពលករចំនួន **៥២.១៨៤**នាក់ (ស្រី **២១.៩៧៨**នាក់), (២)-ប្រមូល និងផ្សព្វផ្សាយព័ត៌មានជ្រើសរើសកម្លាំងពលកម្មចំនួន **១៧២.៩៥២**កន្លែង និងវគ្គអប់រំបណ្តុះបណ្តាល និងអាហារូបករណ៍ចំនួន **១.៥៣៩**វគ្គពីគ្រប់ប្រភព, (៣)-រៀបចំវគ្គបណ្តុះបណ្តាលស្តីពីជំនាញទន់ចំនួន **៩១**វគ្គ ដែលមានអ្នកចូលរួមចំនួន **២.៤២៥**នាក់, ផ្តល់សេវាប្រឹក្សាយោបល់ អំពីអាជីពការងារ និងវិជ្ជាជីវៈដល់អ្នកមកទទួលសេវាចំនួន **១២.២៦៧**នាក់, (៤)-ផ្តល់កម្មវិធីតម្រង់ទិសវិជ្ជាជីវៈនៅតាមសាលាមធ្យមសិក្សាចំណេះទូទៅ **៥៧៩**សាលា ដែលមានសិស្សសរុបចំនួន **៨២.៩៣៧**នាក់ (ស្រី **៤១.៩៧៧**នាក់), (៥)-រៀបចំពិព័រណ៍ការងារចល័តចំនួន **២៣៥**ដង ដែលមានអ្នកចូលរួមចំនួន **៤៨.៥៩៩**នាក់, (៦)-រៀបចំកម្មវិធីវេទិកាការងារចំនួន **៦០**ដង ដែលមានអ្នកចូលរួមចំនួន **៥.០១២**នាក់, (៧)-ផ្សព្វផ្សាយតាមប្រព័ន្ធ Online ចំនួន **៣៣.៤១៦**ដង, (៨)-ចងក្រង និង ផលិតស្ពតផ្សព្វផ្សាយចំនួន **១០៨**ដង, (៩)-ធ្វើកម្មវិធី Roadshow និងផ្សព្វផ្សាយនៅតាមសហគមន៍ ចំនួន **២៧០**ដង ដែលមានសិស្សចំនួន **៣៦.៨៣៦**នាក់ (ស្រី **១៥.៩១៦**នាក់), (១០)-គេហទំព័រការងារទីភ្នាក់ងារជាតិមុខរបរ និងការងារ មានអ្នកចូលប្រើប្រាស់ចំនួន **៦៥៩.២០២**លើក, (១១)-គេហទំព័រ Facebook អ្នកទទួលបានព័ត៌មានអំពីទីផ្សារការងារចំនួន **៣៧៩.១៤៨**នាក់, (១២)-កម្មវិធីស្វែងរកការងារលើទូរស័ព្ទឆ្លាតវៃមានអ្នកប្រើប្រាស់សេវាចំនួន **៨.៨៣២**នាក់, (១៣)-ដាក់ឱ្យដំណើរការជាផ្លូវការប្រព័ន្ធជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈពីចម្ងាយ ឬតាមអនឡាញ (National TVET E-learning Platform)។

❖ **ថ្នាក់ក្រោមជាតិ៖**

▪ **ខេត្តបន្ទាយមានជ័យ (អង្គការអន្តរជាតិទេសន្តរប្រវេសន៍ IOM)៖** ១-បើកវគ្គតម្រង់ទិស ស្តីពីធ្វើការសម្រេចចិត្តដែលប្រកបដោយសុវត្ថិភាព ដើម្បីណែនាំដល់ពលករវិលត្រឡប់មកពីថៃ និងម៉ាឡេស៊ី ចំនួន **៨.០៧៥**នាក់ (ស្រី **២.៦៦៩**នាក់), ២-ប្រឹក្សាយោបល់ដោយផ្ទាល់ជាលក្ខណៈឯកជនជាមួយពលករវិលត្រលប់មកវិញ៖ ១-ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព ដែលមានពលករវិលត្រឡប់ និងនៅសហគមន៍សរុប **១.០៥៧**នាក់ (ស្រី **៤៩០**នាក់), ២-ឱកាសទទួលបានការងារក្នុងស្រុកសរុប **២០៨**នាក់ (ស្រី **៤៦**នាក់), ៣- ពលករបានទទួលការប្រឹក្សាជាលក្ខណៈឯកជនភាពតាមរយៈទូរស័ព្ទ និងប្រព័ន្ធបណ្តាញសង្គម ចំនួន **៦៦**នាក់ (ស្រី **២០**នាក់)។

▪ **ខេត្តបាត់ដំបង (អង្គការសាម៉ារីតាន់ភឺស)៖** បានធ្វើការបណ្តុះបណ្តាល ស្តីពីបំណិនជីវិត(វិជ្ជាជីវៈគ្រប់ជំនាញ) ដល់យុវជន អាណាព្យាបាល នៅក្នុងសហគមន៍សរុបចំនួន **១.៩១២**នាក់ (ស្រី **១.១៤១**នាក់)។

▪ **ខេត្តសៀមរាប៖** មជ្ឈមណ្ឌលការងារខេត្ត បានទទួលចុះឈ្មោះអ្នកស្វែងរកការងារធ្វើចំនួន **១១៥**នាក់ ស្រី**៥១**នាក់, បានធ្វើការផ្គូរផ្គងនិងបញ្ជូនអ្នកស្វែងរកការងារធ្វើទៅឱ្យអ្នកនិយោជក បានចំនួន **៥១**នាក់ (ស្រី **៣៦**នាក់) ក្នុងនោះអ្នកទទួលបានការងារធ្វើសរុបចំនួន **១៤**នាក់ (ស្រី **០៧**នាក់), បានផ្តល់ការប្រឹក្សាយោបល់អំពីអាជីពការងារនឹងវិជ្ជាជីវៈទៅអ្នកស្វែងរកការងារធ្វើ បានចំនួន **៤៥**នាក់ (ស្រី **៣០**នាក់), និងអ្នកទទួលបានពត៌មានទីផ្សារការងារតាមរយៈខិតប័ណ្ណ/កម្មវិធី បានចំនួន **៥០០**នាក់ (ស្រី **២០០**នាក់)។

▪ **ខេត្តព្រៃវែង៖** មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានធ្វើការបណ្តុះបណ្តាល ស្តីពីបំណិនជីវិត(វិជ្ជាជីវៈគ្រប់ជំនាញ) ដល់គ្រូបង្រៀន យុវជន អាណាព្យាបាល និងកុមារ នៅក្នុងសហគមន៍សរុបចំនួន **២០៣**នាក់ (ស្រី **៤៣**នាក់ កុមារា **២២**នាក់ កុមារី **១២៨**នាក់)

▪ **ខេត្តមណ្ឌលគិរី៖** មន្ទីរកិច្ចការនារី និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានវគ្គបណ្តុះបណ្តាលស្តីពីបំណិនជីវិត(វិជ្ជាជីវៈគ្រប់ជំនាញ)ជូនដល់ស្ត្រីក្រីក្រ ស្ត្រីមេម៉ាយ ក្មេងកំព្រា និងក្មេងស្រីបានបោះបង់ការសិក្សាដែលឧបត្ថម្ភដោយរាជរដ្ឋាភិបាលតាមរយៈក្រសួងកិច្ចការនារី មានចំនួន០៨ ជំនាញ ដែលមានសិស្សសរុបចំនួន **២៨៨**នាក់ ស្រី **៨២**នាក់។

ក្រសួងអភិវឌ្ឍន៍ជនបទ តាមរយៈការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ នៃគម្រោងឥណទានជនបទរបស់ក្រសួង មានទ្រព្យសកម្មសរុបចំនួន **សរុបចំនួន ២.៣០១.៧៩១.១៨៥រៀល សម្រាប់ផ្ដល់ឥណទាន ដល់ប្រជាជននៅតំបន់ជនបទ មានអ្នកខ្ចីសរុបចំនួន ៨១៧នាក់ នៅភូមិ គោលដៅចំនួន ៨១ភូមិ ៤១ឃុំ ២៣ស្រុក ក្នុងខេត្តគោលដៅចំនួន ០៩ខេត្ត** ខេត្តកំពង់ចាម ត្បូងឃ្មុំ តាកែវ បាត់ដំបង កំពង់ធំ ស្ទឹងត្រែង ព្រះសីហនុ កំពង់ស្ពឺ និងកំពង់ឆ្នាំង។ បានជួយផ្ដល់នូវជំនាញវិជ្ជាជីវៈដល់ប្រជាពលរដ្ឋក្នុងសហគមន៍ តាមរយៈវគ្គបណ្ដុះបណ្ដាលចិញ្ចឹមត្រី មាន់ ជ្រូក បណ្ដុះផ្សិត ដាំដំណាំគ្រួសារ អនុវត្តកម្មវិធីផ្គត់ផ្គង់ទឹកជនបទ កម្មវិធីថែទាំសុខភាព និងអនាម័យ ជនបទ កម្មវិធីអភិវឌ្ឍផ្លូវជនបទ។ ពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ(គ.អ.ភ) ការអភិវឌ្ឍភូមិ ចម្រុះ ការលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ ការបណ្ដុះបណ្ដាលជំនាញមូលដ្ឋាន ក្នុងការលើកកម្ពស់កម្រិតជីវភាពរបស់ប្រជពលរដ្ឋនៅជនបទ ដើម្បីកាត់បន្ថយប្រជាពលរដ្ឋចំណាកស្រុក។



## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### ១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

#### ១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន **១៦៤**ករណី(ធៀបនឹង ឆ្នាំ២០២២ មានចំនួន **១៦៦**ករណី ថយចុះចំនួន **០២**ករណី) ស្មើនឹង **១,២០%** ៖

- ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន **១៩៤**នាក់/**២០២**នាក់ (ស្រី **៣៥**នាក់) អនីតិជន **២៧**នាក់(ស្រី **០២**នាក់)។ ក្នុងនោះជនសង្ស័យបរទេសចំនួន **១១**នាក់ មានជនជាតិ(ចិន **០៣**នាក់ ហ្វីលីពីន **០១**នាក់ អាមេរិក**០១**នាក់ ជនជាតិវៀតណាម **០៤**នាក់ ស្វីស **០១**នាក់ និងប៉ាគីស្ថាន **០១**នាក់)។
- សង្គ្រោះជនរងគ្រោះ ចំនួន **៤៧៦**នាក់/**៣៥៨**នាក់(ស្រី **៣៤៦**នាក់) ក្នុងនោះ អាយុក្រោម១៥ឆ្នាំ **១៣៥**នាក់(ស្រី) អាយុ១៥-១៧ឆ្នាំ **៤៧**នាក់(ស្រី **៤៤**នាក់) និងអាយុពី១៨ឆ្នាំឡើង **២៩៤**នាក់(ស្រី **១៦៧**នាក់)(ប្រគល់ឱ្យមន្ទីរសង្គមកិច្ច **១៦២**នាក់ និងប្រគល់ឱ្យគ្រួសារ **៣១៤**នាក់) ក្នុងនោះចែកជា៖

**១. ករណីអំពើជួញដូរមនុស្ស**

បង្ក្រាបបាន **២៤**ករណី/**៣៦**ករណី(ថយចុះ **១២**ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន **៣៤**នាក់ (ស្រី **០៧**នាក់) អនីតិជន **០១**នាក់(ស្រី) ជនបរទេស **០៧**នាក់(ស្រី **០១**នាក់) មានជនជាតិ ចិន **០៣**នាក់ ហ្វីលីពីន **០១**នាក់ អាមេរិក **០១**នាក់ ស្វីស **០១**នាក់ និងប៉ាគីស្ថាន **០១**នាក់។ សង្គ្រោះជនរងគ្រោះចំនួន **២០៤**នាក់(ស្រី **៧៨**នាក់) ក្នុងនោះ អាយុក្រោម១៥ឆ្នាំ **១០**នាក់(ស្រី) អាយុ១៥-១៧ឆ្នាំ **១០**នាក់(ស្រី **០៨**នាក់) និងអាយុ១៨ឆ្នាំឡើង **១៨៤**នាក់(ស្រី **៦០**នាក់) ប្រគល់ឱ្យមន្ទីរសង្គមកិច្ចចំនួន **២៤**នាក់ និងប្រគល់ឱ្យគ្រួសារ **១៨០**នាក់។

### *តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | មាត្រា | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|---|
| -ការនាំយកអនីតិជន ដាអាទ៏ចេញដោយមិនស្របច្បាប់ | ៩ | ០១ | ០១ | ០១ | ចិន ០១ |
| -ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ១០ | ០៤ | ០៤ | ០៥ | |
| -ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ២០ | ០១ | ០១ | ០២ | |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ១១ | ០៨ | ១៤៩ | ១២ | |
| -ការជ្រើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ១២ | ០២ | ៣៦ | ០៣ | ប៉ាគីស្ថាន០១<br>ចិន ០២ |
| -អំពើលក់ដូរមនុស្ស | ១៤ | ០១ | ០១ | ០១ | ហ្វីលីពីន០១ |
| -អំពើលក់ដូរមនុស្សដោយមានគោលដៅ | ១៥ | ០១ | ០១ | ០៣ | |
| -អំពើលក់ដូរមនុស្សសម្រាប់ឆ្លងដែន | ១៦ | ០១ | ០៦ | ០២ | |
| -ការទិញបេស្យាចារកុមារ | ៣៤ | ០៥ | ០៥ | ០៥ | អាមេរិក០១,ស្វីស ០១ |
| *សរុប* | | *២៤ករណី* | *២០៤នាក់* | *៣៤នាក់* | *០៧នាក់* |

## ២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន **១៤០**ករណី/**១៣០**ករណី(កើន **១០**ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន **១៦០**នាក់(ស្រី **២៨**នាក់) អនីតិជន **២៦**នាក់(ស្រី **០១**នាក់) និងជនជាតិវៀតណាម **០៤**នាក់។ សង្គ្រោះជនរងគ្រោះចំនួន **២៧២**នាក់(ស្រី **២៦៨**នាក់) មាន: អាយុក្រោម១៥ឆ្នាំ **១២៥**នាក់(ស្រី) អាយុ១៥-១៧ឆ្នាំ **៣៧**នាក់(ស្រី **៣៦**នាក់) និងអាយុ១៨ឆ្នាំឡើង **១១០**នាក់ (ស្រី **១០៧**នាក់) (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច **១៣៨**នាក់ និងប្រគល់ឱ្យគ្រួសារ **១៣៤**នាក់)។

### *តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | មាត្រា | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|---|
| -ស្ថានទម្ងន់ទោស(ការចាប់ពង្រត់ ការឃុំឃាំង) | ២២ | ០១ | ០២ | ០១ | វៀតណាម០១ |
| -សញ្ញារកម្ម | ២៦ | ០៤ | ៣៩ | ០៧ | |
| -ស្ថានទម្ងន់ទោសនៃសញ្ញារកម្ម | ២៧ | ០៨ | ៥១ | ១៣ | |
| -សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ | ២៨ | ១០ | ៤៩ | ១៣ | វៀតណាម០១ |
| -បទល្មើសទាក់ទងនឹងពេស្យាចារកុមារ | ៣៣ | ០១ | ០៣ | ០២ | |
| -រូបភាព និងសម្ភារៈអាសអាភាស | ៣៩ | ១០ | ១១ | ១១ | វៀតណាម០១ |
| -រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ៤១ | ០៣ | ០៣ | ០៣ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ៤២ | ៧៣ | ៧៣ | ៧៩ | វៀតណាម០១ |
| -អំពើអាសអាភាសនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ៤៣ | ៣០ | ៤១ | ៣១ | |
| *សរុប* | | *១៤០ករណី* | *២៧២នាក់* | *១៦០នាក់* | *០៤នាក់* |




➢ មានតារាងលម្អិតនៅក្នុង(ឧបសម្ព័ន្ធ ១)

## ២-កិច្ចការយុត្តិធម៌

### ២.១.ចំណាត់ការផ្ដន្ទាទោស

ទិន្នន័យទទួលបានពីក្រុមការងារជំនាញកិច្ចការយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ជាលទ្ធផលតាមដំណាក់កាលទាំង៣ នៃនីតិវិធីតុលាការ មានដូចខាងក្រោម៖

**១. ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត៖**

សំណុំរឿងសរុបមានចំនួន **៣៧១** (ក្នុងនោះសំណុំរឿងចាស់មានចំនួន **១៧**)

-ជនរងគ្រោះសរុបមានចំនួន **៣២១**នាក់ (ស្រី **១២៤**នាក់) ក្នុងនោះអនីតិជន **១៩០**នាក់ (ស្រី **៩០**នាក់) និងជនបរទេស **២៤**នាក់ (ស្រី **០៣**នាក់)។

-ជនល្មើសសរុបមានចំនួន **៦០០**នាក់ (ស្រី **២៦**នាក់) ក្នុងនោះអនីតិជន **៤៤**នាក់ (ស្រី គ្មាន) និង ជនបរទេស **១៧៨**នាក់(ស្រី **០៧**នាក់)។

❖ **សំណុំរឿងចាត់ការរួចៈ ២៧៥**សំណុំរឿង មានដូចជា៖ បញ្ជូនទៅស៊ើបសួរ **២៣៦** សំណុំរឿង បញ្ជូនរឿងទៅជម្រះ **២** សំណុំរឿង នីតិវិធីបង្ហាញខ្លួនភ្លាម **២** សំណុំរឿង តម្កល់រឿងទុកឥតចាត់ការ **៣២** សំណុំរឿង បញ្ចូលសំណុំរឿង (**០៣**) ផ្ទេរសមត្ថកិច្ច(**គ្មាន**) និងកំពុងចាត់ការ **៩៦** សំណុំរឿង។ ដូចមានតារាងលម្អិតខាងក្រោម៖

| ចំនួនសំណុំរឿង | ចំនួនជនរងគ្រោះ | | | | | | ចំនួនជនល្មើស | | | | | | | សំណុំរឿងចាត់ការរួចការ | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | ជនបរទេស | | នីតិជន | | អនីតិជន | | ជនបរទេស | | អញ្ញាតជន | បញ្ជូនទៅស៊ើបសួរ | បញ្ជូនរឿងទៅជម្រះ | នីតិវិធីបង្ហាញខ្លួនភ្លាម | តម្កល់រឿង ទុកឥតចាត់ការ | បញ្ចូលសំណុំរឿង | ផ្ទេរសមត្ថកិច្ច | រឿងកំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | | | | | | |
| ៣៧១ | ៧៦ | ៣១ | ១០០ | ៩០ | ២១ | ០៣ | ៣៥៩ | ១៩ | ៤៤ | ០ | ១៧១ | ០៧ | ០ | ២៣៦ | ០២ | ០២ | ៣២ | ០៣ | ០ | ៩៦ |
| សរុប | ១០៧ នាក់ | | ១៩០នាក់ | | ២៤នាក់ | | ៣៧៨នាក់ | | ៤៤នាក់ | | ១៧៨នាក់ | | | | | | | | | |
| សរុបរួម | ៣២១ នាក់ | | | | | | ៦០០នាក់ (រួមទាំងអញ្ញាតជនគ្មាន) | | | | | | | ២៧៥ សំណុំរឿង | | | | | | ៩៦ សំណុំរឿង |

**២. ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្តៈ**

សរុបមានចំនួន **៣៥៧** សំណុំរឿង (ក្នុងនោះសំណុំរឿងចាស់មានចំនួន ៨៤)

-ជនរងគ្រោះសរុបមានចំនួន **៣២២**នាក់ (ស្រី **១០៦**នាក់) ក្នុងនោះអនីតិជន **១១០**នាក់ (ស្រី **៤៩**នាក់) និងជនបរទេស **៩១**នាក់(ស្រី **២០**នាក់)

-ជនត្រូវចោទសរុបមានចំនួន **៤៩៨**នាក់ (ស្រី **៥៨**នាក់) ក្នុងនោះអនីតិជន **៣៨**នាក់ (ស្រី **០១**នាក់) និងជនបរទេស **១៣២**នាក់ (ស្រី **២៦**នាក់) និងអញ្ញាតជន គ្មាន ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ០រឿង មនុស្សស្រី គ្មាន។

❖ **ប្រភេទចំណាត់ការរួចៈ ១៤៣** សំណុំរឿង មានដូចជាៈ បានបញ្ជូនរឿងទៅជម្រះចំនួន**១៣៧**សំណុំរឿង លើកលែងចោទ(**០៦**) ផ្ទេរសមត្ថកិច្ច(គ្មាន) បណ្តឹងឧទ្ធរណ៍(គ្មាន) និងកំពុងចាត់ការចំនួន **២១៤** សំណុំរឿង។ ដូចមានតារាងលម្អិតខាងក្រោមៈ

| ចំនួនសំណុំរឿង | ចំនួនជនរងគ្រោះ | | | | | | ចំនួនជនត្រូវចោទ | | | | | | | | | ប្រភេទចំណាត់ការរួច | | | បណ្តឹង ឧទ្ធរណ៍ | កំពុងចាត់ការ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | ជនបរទេស | | នីតិជន | | អនីតិជន | | ជនបរទេស | | ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ | | អញ្ញាតជន | បញ្ជូនរឿងទៅជម្រះ | លើកលែងបទចោទ | ផ្ទេរសមត្ថកិច្ច | | |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ចំនួនរឿង | មនុស្ស | | | | | | |
| ៣៥៧ | ៨៤ | ៣៧ | ៦១ | ៤៩ | ៧១ | ២០ | ៣០២ | ២៦ | ៣៧ | ០១ | ១០៦ | ២៦ | ០ | ០ | ០ | ១៣៧ | ០៦ | ០ | ០ | ២១៤ |
| សរុប | ១២១នាក់ | | ១១០នាក់ | | ៩១នាក់ | | ៣២៨នាក់ | | ៣៨នាក់ | | ១៣២នាក់ | | ០ | | | | | | | |
| សរុបរួម | ៣២២នាក់ | | | | | | ៤៩៨ នាក់ ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ០រឿង មនុស្សស្រី គ្មាន, អញ្ញាតជន (គ្មាន) | | | | | | | | | ១៤៣ សំណុំរឿង | | | | |

**៣. ដំណាក់កាលចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី-ខេត្តៈ**

សរុបមានចំនួន **៣០៧** សំណុំរឿង (ក្នុងនោះសំណុំរឿងចាស់មានចំនួន ១០០)

-ជនរងគ្រោះសរុបមានចំនួន **៣៨៨**នាក់ (ស្រី **១៥២**នាក់) ក្នុងនោះអនីតិជន **១២៥** នាក់(ស្រី **៩៦**នាក់) និងជនបរទេស **២៣**នាក់ (ស្រី ០១នាក់)។

-ជនជាប់ចោទសរុបមានចំនួន **៥១៨**នាក់ (ស្រី **៥២**នាក់) ក្នុងនោះអនីតិជន **៣៤** នាក់(ស្រីគ្មាន) ជនបរទេស **៧០**នាក់(ស្រី ០១នាក់) និងអញ្ញាតជន ០១នាក់។

❖ **សំណុំរឿងចាត់ការរួចៈ** សរុបទាំងអស់ចំនួន **១៤៦**សំណុំរឿង (គឺជំនុំជម្រះ **១៤៦**សំណុំរឿង និងផ្ទេរសមត្ថកិច្ច **គ្មាន** សំណុំរឿង) ដូចជា ៖**១-ប្រកាសសាលក្រម** ឱ្យរួចផុតពីបទចោទ **១១**សំណុំរឿង មនុស្សចំនួន ០៨ នាក់ (ស្រី ០១នាក់), **២-ផ្តន្ទាទោស** ពិន័យជាប្រាក់ ០១សំណុំរឿង ដាក់ពន្ធនាគារ **៩៩**សំណុំរឿង មនុស្សចំនួន **៩៥** នាក់ (ស្រី ០៩នាក់), **៣-ព្យួរទោស៖**ព្យួរទោសសាកល្បង ០១ សំណុំរឿង ព្យួរទោសធម្មតា ០៩ សំណុំរឿង មាន

មនុស្សចំនួន ១០នាក់ (ស្រី ០២នាក់), **៤-បណ្តឹងឧបាស្រ័យ:** បណ្តឹងជំទាស់ គ្មានសំណុំរឿង បណ្តឹងឧទ្ធរណ៍ គ្មានសំណុំរឿង និងកំពុងចាត់ការ **១៦១** សំណុំរឿង។ ដូចមានតារាងលម្អិតខាងក្រោម៖

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | | | ចំនួនជនជាប់ចោទ | | | | | | | សំណុំរឿងចាត់ការរួច | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | និតិជន | | អនីតិជន | | ជនបរទេស | | និតិជន | | អនីតិជន | | ជនបរទេស | | អត្ត | បញ្ជូនទៅជំនុំ | ផ្ញើរសមត្ថកិច្ច | ប្រកាសសាលក្រម: រួចផុតបទចោទ | | | ប្រកាសសាលក្រម: ផ្តន្ទាទោស | | | | ប្រកាសសាលក្រម: ទោសព្យួរ | | | | បណ្តឹងឧបាស្រ័យ | | | |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | | សំណុំរឿង | ចំនួនមនុស្ស: សរុប | ចំនួនមនុស្ស: ស្រី | ពិន័យជាប្រាក់ | ដាក់ពន្ធនាគារ | ចំនួនមនុស្ស: សរុប | ចំនួនមនុស្ស: ស្រី | ទោសព្យួរសាកល្បង | ទោសព្យួរផ្នែក | ចំនួនមនុស្ស: សរុប | ចំនួនមនុស្ស: ស្រី | បណ្តឹងទាស់ | បណ្តឹងឧទ្ធរណ៍ | សរុបចាត់ការរួច | រឿងកំពុងចាត់ការ |
| សរុប ៣០៧ | ១៨៥ | ៥៥ | ២៩ | ៩៦ | ២២ | ០១ | ៣៦២ | ៥១ | ៣៤ | ០ | ៦៩ | ០១ | ០១ | ១៤៦ | ០ | ១១ | ០៨ | ០១ | ០១ | ៩៩ | ៩៩ | ០៩ | ០១ | ០៩ | ១០ | ០២ | ០ | ០ | ១៤៦ | ១៦១ |
| | ២៤០ | | ១២៥ | | ២៣ | | ៤១៣ | | ៣៤ | | ៧០ | | ១ | | | | | | | | | | | | | | | | | |
| | ៣៨៨ នាក់ | | | | | | ៥១៨នាក់ រួមអញ្ញតជន ១នាក់ | | | | | | | | | | | | | | | | | | | | | | ១៤៦ | ១៦១ |

➢ (មានតារាងលំអិតនៅក្នុងឧបសម្ព័ន្ធ ២)




## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

១.១. ការទទួល និងសម្ភាសពលរដ្ឋខ្មែរបញ្ជូនត្រឡប់ តាមផ្លូវគោក និងផ្លូវអាកាស

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានសហការជាមួយ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ, អគ្គស្នងការដ្ឋាននគរបាលជាតិ, អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា សរុបចំនួន **២៣.៦០១**នាក់(ស្រី **១១.១១៤**នាក់) ក្នុងនោះកុមារ **២.៣៦២**នាក់(កុមារី **១.១០០**នាក់) មានសកម្មភាពដូចជា៖

**១-នាយកដ្ឋានគាំពារជនរងគ្រោះ** នៃក្រសួង ស.អ.យ បានទទួល ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានាតាមផ្លូវអាកាស សរុប ៣៤២នាក់

(ស្រី **៣២៩**នាក់ កុមារី**០៧**នាក់) មកពីប្រទេសចិន **៣២២**នាក់ (ស្រី **៣១១**នាក់ កុមារ **០៣**នាក់), ម៉ាឡេស៊ី **១៤**នាក់(ស្រី **១០**នាក់), ឡាវ ០៦នាក់(ស្រី ០២នាក់ កុមារ ០៤នាក់)។ ក្នុងនេះបានសម្ភាសកំណត់អត្តសញ្ញាណបឋមរក ជនដែលសង្ស័យថារងគ្រោះ ដោយអំពើជួញដូរមនុស្ស/អំពើធ្វើអាជីវកម្មផ្លូវភេទរួមទាំងអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ/បង្ខំ ២៨៣នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម ២៣នាក់ និងងាយរងគ្រោះ ៣៦នាក់ មុននឹងបញ្ជូនទៅនគរបាលយុត្តិធម៌ដើម្បីកំណត់អត្តសញ្ញាណបញ្ជាក់បន្ថែម។ ជនទាំងនោះត្រូវបានបញ្ជូន ទៅទទួលសេវាបន្តនៅអង្គការដៃគូ។

២-មណ្ឌលសំចតប៉ោយប៉ែត បានទទួលពលករចំណាកស្រុកពីប្រទេសថៃតាមផ្លូវគោកចំនួន **១៦.៣៤៩**នាក់ (ស្រី ៨.០៤៥នាក់) កុមារ **១.៤៥៥**នាក់(កុមារី **៦៩៣**នាក់) ក្នុងនោះបានសម្ភាសអត្តសញ្ញាណរកមុខសញ្ញាជនរងគ្រោះ និងងាយរងគ្រោះ ចំនួន **៤៦**នាក់ (ស្រី **១០**នាក់ កុមារ **១១**នាក់) ក្នុងនោះ កេងប្រវ័ញ្ចកម្លាំងពលកម្ម ចំនួន **៤២**នាក់ (ស្រី **១០**នាក់ កុមារ **០៨**នាក់) រំលោភបំពានផ្លូវភេទចំនួន **០៣**នាក់(កុមារី) និងជួញដូរកម្លាំងពលកម្ម ចំនួន **០១**នាក់ និងរកឃើញថាជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន **២៣៧**នាក់ (ស្រី **៥៦**នាក់ កុមារ **១១៥**នាក់)។ ជនរងគ្រោះចំនួន **៤៦**នាក់ខាងលើ បញ្ជូនទៅទទួលសេវាពីអង្គការរតនៈអ៊ិនធើណេណលចំនួន **២២**នាក់ អង្គការតំណក់ទឹកចំនួន **១៣**នាក់ អង្គការIJM ចំនួន **០៧**នាក់ និងសហគមន៍ចំនួន **០៤**នាក់។

៣-**មណ្ឌលទទួលពលករកំរៀង របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានទទួលពលករសរុបចំនួន **៣.៦៨៧**នាក់ (ស្រី **១.៥៩៥**នាក់) ក្នុងនោះ កុមារ **៤២៥**នាក់(កុមារី **១៨៥**នាក់) ស្ត្រីមានកូនតូច **៧៨**នាក់ ស្ត្រីមានផ្ទៃពោះ **៩១**នាក់ និងជនពិការ **២៥**នាក់ (ស្រី **០៥**នាក់)។

៤-**អគ្គស្នងការដ្ឋាននគរបាលជាតិ** មានស្នងការដ្ឋាននគរបាលខេត្ត ចំនួន **០៦** បានទទួល និងសម្ភាសពលករ និងពលរដ្ឋខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ក្នុងនោះមាន(ច្រកចាំយាម ច្រកធម្មជាតិ) និងច្រកទ្វារព្រំដែនអន្តរជាតិ កម្ពុជា-វៀតណាម បានចំនួន **២១៩**លើក សរុបមនុស្សចំនួន **៣.២២៣**នាក់(ស្រី **១.១៤៥**នាក់ កុមារ **៤៧៥**នាក់ (កុមារី **២១៥**នាក់) ក្នុងនោះមាន៖

- ខេត្តបន្ទាយមានជ័យ ចំនួនៈ **១៤៧**លើក មនុស្សចំនួនៈ២,៨៣១នាក់(ស្រី **៩៥៨**នាក់) កុមារ **៣២៤**នាក់(កុមារី **១៣៤**នាក់)
- ខេត្តព្រះវិហារ ចំនួន **០១**លើក មនុស្សចំនួន **០៤**នាក់ (ស្រី **០១**នាក់)
- ខេត្តកោះកុង ចំនួន **៤៩**លើក មនុស្សចំនួន **១១៦**នាក់(ស្រី **១៨**នាក់ កុមារ **០១**នាក់)
- ខេត្តស្វាយរៀង ចំនួន **១៨**លើក មនុស្សចំនួន **២៦៣**នាក់(ស្រី **១៦២**នាក់) កុមារ **១៥០**នាក់ (កុមារី **៨១**នាក់)
- ខេត្តត្បូងឃ្មុំ ចំនួន **០៣**លើក មនុស្សចំនួន **០៣**នាក់។
- ខេត្តស្ទឹងត្រែង ចំនួន **០១**លើក មនុស្សចំនួន **០៦**នាក់(ស្រី)។

➢ **ដោយឡែក៖** ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស បានទទួលពីកម្លាំងនគរបាលនៅក្នុងស្រុក និងបានសហការជាមួយអង្គការដៃគូ សរុបចំនួន **១៣៧**នាក់(ស្រី **៤៥**នាក់ កុមារ **០២**នាក់ ) ក្នុងនោះជនជាតិខ្មែរចំនួន **៣៩**នាក់(ស្រី **១៥**នាក់ កុមារ **០២**នាក់)(ជាករណីអំពើជួញដូរមនុស្ស បម្រុងឆ្លងដែនទៅធ្វើការនៅប្រទេសគោលដៅ) និងជនបរទេសចំនួន **៩៨**នាក់ ស្រី **៣០**នាក់ មានជនជាតិ៖ ថៃ **០៥**នាក់(ស្រី), វៀតណាម **៣៥**នាក់ (ស្រី **១០**នាក់) ឥណ្ឌា **០៣**នាក់(ស្រី **០១**នាក់) ឥណ្ឌូនេស៊ី ចំនួន **២៨**នាក់ (ស្រី **០៥**នាក់) និងជនជាតិហ្វីលីពីន **២៧**នាក់(ស្រី **១២**នាក់)(ជាករណីជួញដូរកម្លាំងពលកម្ម)។

## ២. កិច្ចការពារជនរងគ្រោះ ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

### ២.១.កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវា

នៅក្នុងឆ្នាំ២០២៣ ដោយយោងតាមច្បាប់ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ, នៃក្រមព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា គ.ជ.ប.ជ និង គ.រ.ប.ជ/គ.ខ.ប.ជ បានសហការជាមួយអង្គភាពពាក់ព័ន្ធ និង អង្គការដៃគូ បានផ្តល់សេវាផ្នែកច្បាប់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយរៀបចំបណ្តឹងទាមទារសំណង ដល់ជនរងគ្រោះចំនួន **១៣**នាក់ សរុបជាទឹកប្រាក់ទទួលបានសំណងចន្លោះពី**១២.០០០.០០០**រៀល( ដប់ពីរលានរៀល ) ស្មើនឹង **៣.០០០**ដុល្លារ (បីពាន់ដុល្លារសហរដ្ឋអាមេរិកគត់ ) ទៅ **១៣០.០០០.០០០**រៀល( មួយរយសាមសិបលានរៀលគត់ ) ទៅ **២១.២៥០**ដុល្លារ( ពីរម៉ឺនមួយពាន់ពីររយហាសិបដុល្លារសហរដ្ឋអាមេរិកគត់ ) ដែលអង្គការដៃគូសហការគាំទ្រ និងផ្តល់សេវាផ្នែកច្បាប់រួមមាន៖

- **អង្គការសកម្មភាពដើម្បីកុមារ (APLE) ៖**

១-ជនល្មើសចំនួន **០៣**នាក់ ជនជាតិខ្មែរ ត្រូវបានតុលាការសាលាដំបូង សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ ចន្លោះពី ២ ឆ្នាំ ដល់ ១៦ ឆ្នាំ ពីបទល្មើស ក្នុងករណីការនាំចេញដោយមិនស្របច្បាប់, ការផលិតរូបភាពអាសអាភាសនៃកុមារ និងការបង្ខាំមនុស្ស ដោយខុសច្បាប់។ ត្រូវបានបង្គាប់បង់សំណងជម្ងឺចិត្តដល់កុមារជាជនរងគ្រោះ ចំនួន **០៣**នាក់ នូវទឹកប្រាក់ ចន្លោះពី **៤.០០០,០០០** រៀល ( ស្មើនឹង **១.០០០** ដុល្លា ) និង **៥០.០០០,០០០** រៀល ( ស្មើនឹង **១.២៥០**ដុល្លា ) ។

២-ជនល្មើសចំនួន **០២**នាក់ ជាជនជាតិអាមេរិក ត្រូវបានសាលាឧទ្ធរណ៍ និងតុលាការកំពូល សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ ១២ឆ្នាំ ក្រោមបទចោទប្រកាន់នៃពីបទល្មើស ក្នុងករណីទិញពេស្យាចារកុមារ និងរួមភេទជាមួយអានីតិជនក្រោមអាយុ១៥ឆ្នាំ។ ត្រូវបានបង្គាប់បង់សំណងជម្ងឺចិត្តដល់កុមារជាជនរងគ្រោះចំនួន **០៨**នាក់ នូវទឹកប្រាក់ចន្លោះ **៨.០០០,០០០** រៀល ( ស្មើនឹង **២.០០០** ដុល្លា ) និង **៨០.០០០,០០០** រៀល ( ស្មើនឹង **២០.០០០** ដុល្លា )។

- **អង្គការសម្ព័ន្ធចាប់ដៃ៖** ជនល្មើសជាមេខ្យល់ចំនួន **០១**នាក់ ជនជាតិខ្មែរ ត្រូវបានចៅក្រមស៊ើបសួរនៃចំណាត់ការរបស់អយ្យការអមសាលាដំបូង ក្នុងករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ/បង្ខំ ត្រូវបានបង្គាប់ឱ្យមេខ្យល់បង់សំណងជម្ងឺចិត្តដល់ជនរងគ្រោះ **០២**នាក់ ទទួលបានប្រាក់ចំនួន **២០០០**ដុល្លារ។

### ២.២. ការស្តារនីតិសម្បទាដល់ជនរងគ្រោះ

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ទៅស្តារនីតិសម្បទានៅមណ្ឌលរបស់អង្គការដៃគូ សរុប **៤៣៦**នាក់( ប្រុស **៧១**នាក់ ស្រី **៣៥៦**នាក់ កុមារា **០១**នាក់ កុមារី **០៨**នាក់ ) ក្នុងនោះមានករណី( អាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ/បង្ខំ **២៨៤**នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម **៨៦**នាក់ និងងាយរងគ្រោះ **៦៦**នាក់ )។ ក្នុងនោះបញ្ជូនទៅអង្គការដៃគូចំនួន **៤៨៦**នាក់ មានអង្គការការីតាសកម្ពុជា, សមាគម ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា( អាដហុក ), អង្គការរតនៈអ៊ិនធើណេណល, អង្គការបេសកម្មយុត្តិធ៌មអន្តរជាតិIJM, អង្គការមូលនិធិហាការអន្តរជាតិ, អង្គការសម្ព័ន្ធចាប់ដៃ, អង្គការមូលនិធិ A21, អង្គការកម្ពុជាដើម្បីស្ត្រីមានវិបត្តិ CWCC, អង្គការសង់ត្រាល់ និងអង្គការស្ពានក្តីសង្ឃឹម។

### ៣.ការធ្វើសមាហរណកម្ម ពលរដ្ឋខ្មែរដែលជាជនរងគ្រោះ និងងាយរងគ្រោះ

#### ៣.១. ការធ្វើសមាហរណកម្ម

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ សមាហរណកម្មជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងរំលោភបំពានផ្លូវភេទ ត្រឡប់ទៅសហគមន៍វិញសរុប ២៨៣នាក់(ប្រុស ៣៧នាក់ ស្រី ២៤៦នាក់) ក្នុងនោះករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទះ/បង្ខំ ១៣២នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម ២៧នាក់ ជួញដូរ និង រំលោភបំពានផ្លូវភេទ ១១០នាក់ និងងាយរងគ្រោះ ១៤នាក់ ដោយមានការចូលរួមសហការគាំទ្រពីអង្គការដៃគូ។

➢ និងបានធ្វើមាតុភូមិនិវត្តន៍ ទៅប្រទេសដើមវិញ ចំនួន ៩០នាក់(ស្រី ចំនួន ៣៧នាក់) ជាករណីជួញដូរកម្លាំងពលកម្ម ជនរងគ្រោះជនជាតិ ឥណ្ឌូនេស៊ី ចំនួន ២៨នាក់ (ស្រី ០៥នាក់) វៀតណាមចំនួន ៣៥នាក់(ស្រី ១០នាក់) និងជនជាតិហ្វីលីពីន ២៧នាក់(ស្រី ១២នាក់)។

➢ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ៣០០នាក់(ប្រុស ៤១នាក់ ស្ត្រី ២៥៩នាក់ ) កេងប្រវ័ញ្ចកម្លាំងពលកម្ម ១០៤នាក់ អាពាហ៍ពិពាហ៍ផ្ទុយពីធន្ទះ/បង្ខំ ២១នាក់ ជួញដូរ និង រំលោភបំពានផ្លូវភេទ ១៧១នាក់ និង ងាយរងគ្រោះ ០៤នាក់ ត្រូវបានបន្តតាមដានក្រោយពីធ្វើសមាហរណកម្មរួច ដោយមានកិច្ចសហការជាមួយអង្គការដៃគូ។

#### ៣.២. ការបិទករណី

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** សហការជាមួយអង្គការដៃគូ បានបិទករណី នៃការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ១៥៣នាក់(ស្ត្រី ១៣៤នាក់) មាន: (ករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទះ/បង្ខំ ១២នាក់ ជួញដូរ និងរំលោភបំពានផ្លូវភេទ ៥៥នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម ៤៤នាក់ និងងាយរងគ្រោះ ៤២នាក់។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ១. ការងារបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស

#### ១.១ ការងារបណ្តុះបណ្តាលក្នុងប្រទេស

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ជាតិ ក្រសួង ស្ថាប័ន និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត(គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយ អង្គការដៃគូពាក់ព័ន្ធ រៀបចំបើកវគ្គបណ្តុះបណ្តាលចំនួន ៣៨២វគ្គ មានសិក្ខាកាមចូលរួមចំនួន ១៤.៧០៤នាក់ ក្នុងនោះមានស្ត្រី ៦.៤២២នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តច្បាប់ និងសមាជិក គ.រ.ប.ជ/គ.ខ.ប.ជ ដូចមានក្នុងតារាងខាងក្រោម៖

- (១)បណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីជួរមុខ ឲ្យយល់ដឹងអំពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដល់ខេត្តចំនួន ៥ មានខេត្តប៉ៃលិន កំពង់ចាម កំពត ព្រៃវែង និងខេត្តកំពង់ធំ, (២)បណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់មន្ត្រីគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញ ដូរមនុស្សខេត្ត (គ.ខ.ប.ជ) ស្តីពីរចនាសម្ព័ន្ធ របៀបបែបការងារ និងទម្រង់ធ្វើរបាយការណ៍ បាន ៤ខេត្ត ដូចជាខេត្តប៉ៃលិន ស្ទឹងត្រែង រតនគិរី និងខេត្តមណ្ឌលគិរី, (៣)រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីយន្តការបញ្ជូនថ្នាក់ជាតិ សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស, (៤)រៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការវាយតម្លៃអនុវត្តផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំ ២០១៩-២០២៣ និងការបង្កើតផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំ (២០២៤-២០២៨) ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស, (៥)កិច្ចប្រជុំពិភាក្សាជាមួយអន្តរក្រសួងពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាពលករដែល

កំពុងស្នាក់នៅគ្មានឯកសារ និងកំពុងប្រើប្រាស់ឯកសារធ្វើការងារដែលផុតសុពលភាពនៅប្រទេសថៃ, (១០)រៀបចំកិច្ចប្រជុំពិភាក្សាការងាររបាយការណ៍ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សង្ខេបឆ្លើយតបទៅនឹងអនុសាសន៍ របស់ក្រសួងការបរទេសអាមេរិកជាមួយអគ្គរដ្ឋទូតអាមេរិកប្រចាំនៅកម្ពុជា, (១១) រៀបចំកិច្ចប្រជុំថ្នាក់ក្រោមជាតិ ស្ដីពីរបាយការណ៍ ១០ខែ នៃការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានសហការជាមួយអង្គការដៃគូ បានរៀបចំបើកវគ្គបណ្ដុះបណ្ដាលទាំងទ្រឹស្ដី និងការអនុវត្តកសាងសមត្ថភាពដោយផ្ទាល់ និងតាមប្រព័ន្ធ Zoom ស្ដីពី៖ ១-ការណែនាំតម្រង់ទិសពលករមុនពេលចេញដំណើរទៅបរទេស។ ២-ជំនាញទន់ និងការត្រៀមលក្ខណៈសម្បត្តិក្នុងការស្វែងរកការងារធ្វើ។ ៣-ការណែនាំតម្រង់ទិសពលករមុនពេលចេញដំណើរទៅបរទេស។ ៣-នីតិវិធីនៃការចុះយុទ្ធនាការផ្សព្វផ្សាយទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងកសិឧស្សាហកម្ម។ ៤-ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងកម្លាំងពលកម្ម ការធ្វើចំណាកស្រុកខុសច្បាប់ និងកិច្ចការពារកុមារផ្លូវច្បាប់សម្រាប់ស្ត្រី និងកុមារ។ ៥-ការមិនបង្កហានិភ័យ និងការគ្រប់គ្រងករណីសម្រាប់ពលករនៅតាមភូមិ/ឃុំ/ស្រុក។ ៦-កិច្ចការពារកុមារ ការទប់ស្កាត់ការធ្វើអាជីវកម្មផ្លូវភេទលើកុមារ និងច្បាប់ស្ដីពីយុត្តិធម៌អនីតិជន។ ៧-នីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការសម្ភាសបែបកោសល្យវិច័យ។ ៨-ការវាយតំលៃ តាមដានការចល័តរបស់ជនទេសន្តរប្រវេស្តន៍ តាមព្រំដែនកម្ពុជា-ឡាវ។ ៩-នីតិវិធីគ្រប់គ្រងករណី និងការស្វែងយល់ពីការប៉ះទង្គិចផ្លូវចិត្តជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ១០-តួនាទី និងរបៀបរបបការងារ ក្នុងរចនាសម្ព័ន្ធ គ.ខ.ប.ជ។ ១០-"យន្តការក្នុងការដោះស្រាយបណ្ដឹងពលករទេសន្តរប្រវេសន៍ ដោយផ្ដោតលើវិស័យនេសាទ និងកែច្នៃអាហារសមុទ្រ"។

| សកម្មភាពរៀបចំវគ្គបណ្ដុះបណ្ដាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| **ថ្នាក់ជាតិ** | | | |
| ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | ៧៨ | ២.៥២៦ | ៥៣៦ |
| ក្រសួងកិច្ចការនារី សហការជាមួយអង្គការ (UN WOMEN ) | ០៤ | ២២៣ | ១៥៨ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាសហការជាមួយអង្គការ (ASEAN-ACT), អង្គការរតនៈ, អង្គការអាស៊ានអេច និងអង្គការអេ២១ | ០៤ | ១៧២ | ៧៥ |
| ក្រសួងធម្មការ និងសាសនា សហការជាមួយក្រសួងព័ត៌មាន | ០៣ | ៦៣៥ | ១៥៦ |
| ក្រសួងអភិវឌ្ឍន៍ជនបទ | ២៧ | ៤៧៩ | ៨៩ |
| សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងការអភិវឌ្ឍន៍ថ្នាក់កណ្ដាល | ០២ | ៨១ | ២៩ |
| អគ្គស្នងការដ្ឋាន សហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ | ០២ | ៦៨ | ៥៥ |
| អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សហការជាមួយអង្គការដៃគូ អង្គការការីតាស អង្គការអេ២១ អង្គការ IOM និងអង្គការហាការ | ១៤ | ៧៨០ | ២៣១ |
| កាកបាទក្រហមកម្ពុជា | ០១ | ២៥ | ០៩ |
| ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី | ០២ | ១២៣ | ១១០ |
| អង្គការសកម្មភាពដើម្បីកុមារ (APLE) (ខេត្តក្រចេះ និងខេត្តកណ្ដាល) | ០២ | ២១២ | ៥៥ |
| អង្គការសម្ព័ន្ធចាប់ដៃ(ខេត្តកំពង់ចាម) | ០២ | ៥២ | ៣៩ |
| អង្គការLSCW និងអង្គការភ្លើស្រីដើម្បីអភិវឌ្ឍន៍(ខេត្តកំពង់ចាម) | ០១ | ៤៦ | ០៨ |
| អង្គការជំនួយផ្លូវច្បាប់ស្ត្រីនិងកុមារ(ខេត្តកំពង់ចាម) | ០១ | ៤០ | ២៤ |
| អង្គការសម្ព័ន្ធចាប់ដៃ(ត្បូងឃ្មុំ) | ០២ | ៣៥ | ២៣ |

| | | | |
|---|---|---|---|
| អង្គការ IJM(ខេត្តបន្ទាយមានជ័យ, ខេត្តកំពត, ខេត្តព្រះសីហនុ, ត្បូងឃ្មុំ និងខេត្តស្វាយរៀង) | ០៥ | ២៧២ | ៧២ |
| អង្គការមូលនិធិអេ២១ (ខេត្តបាត់ដំបង) | ០៥ | ១០៩ | ៩៨ |
| អង្គការសាម៉ារីតាន់ភីស (ខេត្តបាត់ដំបង) | ១៨ | ១,៦១២ | ៩៨៦ |
| អង្គការការីតាស់ស្វីស(ខេត្តបាត់ដំបង) | ០៣ | ៦១ | ៣៣ |
| អង្គការកល្យាណមិត្ត (ខេត្តសៀមរាប) | ០៣ | ៦៨ | ១៨ |
| អង្គការម្លប់ឫស្សី (ខេត្តកំពង់ឆ្នាំង) | ០១ | ៥៤ | ៤៩ |
| អង្គការ UNFPA (ខេត្តព្រះវិហារ) | ១០ | ៣៤ | ១៦ |
| អង្គការ ADRA (ខេត្តព្រះវិហារ) | ០១ | ១៨១ | ២៩ |
| អង្គការយូនីសេហ្វ (ខេត្តកណ្ដាល) | ០១ | ៧៦ | ៣២ |
| អង្គការមូលនិធិហាកា(ខេត្តតាកែវ) | ០២ | ៨៨ | ៥០ |
| អង្គការជីវិតថ្លៃថ្នូរ(ខេត្តកំពង់ស្ពឺ) | ០២ | ៣៨ | ១៣ |
| អង្គការមូលនិធិហាកា សហការជាមួយក្រុមប្រឹក្សាជាតិដើម្បីកុមារ | ៥៤ | ១.៨៨៨ | ៩៩៩ |
| **សរុប** | **២៥០វគ្គ** | **៩.៩៧៨នាក់** | **៣.៩៩២នាក់** |
| **ថ្នាក់ក្រោមជាតិ** | | | |
| ខេត្តសៀមរាប សហការជាមួយអង្គការអេ២១, អង្គការ(IJM) និងអន្តរជាតិហាការ | ១៥ | ៩៨៥ | ៣៧៨ |
| ខេត្តបន្ទាយមានជ័យ សហការជាមួយអង្គការ MOI | ០១ | ២៩ | ១៧ |
| ខេត្តបាត់ដំបង | ០៥ | ២៩១ | ១១៦ |
| ខេត្តព្រះវិហារ | ០២ | ២១៥ | ៦៥ |
| ខេត្តបន្ទាយមានជ័យ | ០២ | ៩៦ | ១១ |
| ខេត្តប៉ៃលិន | ០១ | ២៥ | ១៣ |
| ខេត្តសៀមរាប | ០៤ | ១៦១ | ៧៨ |
| ខេត្តកំពង់ធំ សហការជាមួយអង្គការមូលនិធិហាការ | ០២ | ១១៧ | ៥១ |
| ខេត្តពោធិ៍សាត់ | ០១ | ៣៥ | ២០ |
| ខេត្តកោះកុង | ០១ | ៥០ | ១៧ |
| ខេត្តស្វាយរៀង | ៥៣ | ១.០៤៩ | ៦៣១ |
| ខេត្តស្ទឹងត្រែង | ០៧ | ២១៩ | ១៣៨ |
| ខេត្តក្រចេះ | ០៣ | ២៣៣ | ១២៩ |
| ខេត្តកំពង់ចាម | ០៩ | ២៨៧ | ២៨២ |
| ខេត្តរតនគិរី | ០១ | ៥៩ | ៥៣ |
| ខេត្តមណ្ឌលគិរី សហការជាមួយអង្គការមូលនិធិហាការ | ០១ | ៤២ | ៣៤ |
| ខេត្តព្រៃវែង | ០៧ | ១៩២ | ១០៦ |
| ខេត្តតាកែវ | ០២ | ៦៥ | ៤២ |
| ខេត្តព្រះសីហនុ | ០៥ | ១៧៣ | ១១២ |

| | | | |
|---|---|---|---|
| ខេត្តកោះកុង | ០២ | ១១០ | ២៨ |
| ខេត្តកំពង់ឆ្នាំង សហការជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី | ០៨ | ២៩៣ | ១០៩ |
| **សរុប** | **១៣២វគ្គ** | **៤.៧២៦នាក់** | **២.៤៣០នាក់** |
| **សរុបរួម** | **៣៨២វគ្គ** | **១៤.៧០៤នាក់** | **៦.៤២២នាក់** |

### ១.២. ការចូលរួមបណ្តុះបណ្តាលក្រៅប្រទេស

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** (១)-បានរៀបចំវគ្គបណ្តុះបណ្តាលរួមគ្នាដល់មន្ត្រីអនុវត្តជួរមុខក្នុងការជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលស្ថិតជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ នៅខេត្តស្រះកែវប្រទេសថៃ, (២)-បានបញ្ជូនមន្ត្រីជំនាញចំនួន ១៥នាក់ ទៅបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងករណី ប្រឹក្សាយោបល់ នៅប្រទេសថៃ។

▪ **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖** អគ្គលេខាធិការរងទទួលបន្ទុកកិច្ចការអនុវត្តច្បាប់ និង ប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានចូលរួមសិក្ខាសាលា ស្តីពី «ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស» ដែលរៀបចំដោយក្រុមការងារចំពោះកិច្ចអន្តរស្ថាប័នប្រឆាំងការជួញដូរមនុស្សសិង្ហបុរី (SINGAPORE INTER-AGENCY TASKFORCE ON TRAFFICKING IN PERSON) ក្រោមកិច្ចសហការគាំទ្រដោយកម្មវិធីបណ្តុះបណ្តាលប្រទេសទី៣ ក្រៅពីសិង្ហបុរី និងសហរដ្ឋអាមេរិក (SINGAPORE-UNITED STATES THIRD COUNTRY TRAINNING PROGRAMME) នៅប្រទេសសិង្ហបុរី ។

▪ **ខេត្តស្វាយរៀង៖** ស្នងការដ្ឋាននគរបាលខេត្ត ដឹកនាំក្រុមការងារជំនាញ ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលា(ILEA)ប្រទេសថៃ អ្នកចូលរួមចំនួន ៤៨នាក់(ស្រី ២៥នាក់)។

## ២. សិក្ខាសាលា

### ២.១. សិក្ខាសាលាក្នុងប្រទេស

ក្រសួង ស្ថាប័នដែលជាសមាជិក គ.ជ.ប.ជ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយអង្គការដៃគូពាក់ព័ន្ធ រៀបចំសិក្ខាសាលាដើម្បីពង្រឹងសមត្ថភាពដល់មន្ត្រីអនុវត្តច្បាប់ និងសមាជិក គ.រ.ប.ជ/គ.ខ.ប.ជ បានចំនួន **៤៥៦**វគ្គ មានសិក្ខាកាមចូលរួមចំនួន **២៣.៣១៩**នាក់ ក្នុងនោះមានស្ត្រី **១១.៥៥៧**នាក់ ដូចមានក្នុងតារាងខាងក្រោម៖

| |
|---|
| ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានសហការជាមួយអង្គការដៃគូ បានរៀបចំសិក្ខាសាលា ដើម្បីពង្រឹងសមត្ថភាពការងារដល់មន្ត្រីពាក់ព័ន្ធ (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) ស្តីពី៖ ការរៀបចំសៀវភៅផែនការសកម្មភាពប្រចាំឆ្នាំ ដើម្បីសុខភាពជនទេសន្តរប្រវេសន៍ ២០២៣-២០២៥ ១-«សាសនិកចូលរួមប្រឆាំងអំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើប»។ ២-«ការគូសផែនទីប្រជាជនបំលាស់ចល័ត» ដើម្បីងាយស្រួលលក្នុងការគ្រប់គ្រងប្រជាជនបំលាស់ទីធ្វើចំណាកស្រុក ផែនការអាជីព និងជ្រើសរើសជំនាញការងារសម្រាប់សិស្សមធ្យមសិក្សាទុតិយភូមិ និងនិស្សិតនៅគ្រឹះស្ថានអប់រំ។ ៣-សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍។ ៤-ការជំរុញការចូលរួមរបស់ក្រុមហ៊ុនបច្ចេកវិទ្យាក្នុងកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ។ ៥-បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។ ៦-លើកកម្ពស់សិទ្ធិការងាររបស់ពលករចំណាកស្រុកកម្ពុជា ដែលមានជំនាញទាបនៅក្នុងប្រទេសថៃ។ ៧-សិទ្ធិកុមារ និងច្បាប់នានាដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស។ ៨-កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ៩-ស្តីពីការផ្សព្វផ្សាយលើការវាយតម្លៃស្ថានភាពកុមារ និងក្មេងជំទង់នៅកម្ពុជា និងការអន្តរាគមន៍ដ៏មានសក្តានុពល ១០-បង្កើតធាតុចូលលើឧបសម្ព័ន្ធ នៃផែនការសកម្មភាពនៃនីតិវិធីប្រតិបត្តិបទដ្ឋាន សម្រាប់ការគ្រប់គ្រងករណីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស។ ១១-ការវាយតម្លៃអនុវត្តផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំ (២០១៩-២០២៣) និងការបង្កើតផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំ (២០២៤-២០២៨)។ ១២-នីតិវិធីប្រតិបត្តិការបទដ្ឋាន(sop)ក្នុងការកំណត់អត្តសញ្ញាណនិងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ១៣-យន្តការណ៍បញ្ជូនបន្តថ្នាក់ជាតិសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ១៤-តួនាទីនៃវិស័យវប្បធម៌ក្នុងការប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្ស។ |

| សកម្មភាពរៀបចំសិក្ខាសាលា<br>ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការដៃគូ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្រី |
|---|---|---|---|
| **ថ្នាក់ជាតិ** | | | |
| គណៈកម្មាធិការជាតិ គ.ជ.ប.ជ សហការជាមួយអន្តរក្រសួង និងអង្គការដៃគូ IJM, USIAD, UNISEF, UNDP ASEAN-ACT, IOM, Caritas Cambodia, Caritas Swiss, ERIK Development Partner, MARICI, Hagar, A21, Chab Dai, Winrock International, Terre des Hommes, AIM, APLE, Cambodia-ACT, CPU, UN-Woman, CWCC, ILO Cambodia, CARE, Rattanak Internationnal and Plan International , SAMICA | ០៤ | ២៨២ | ១០៣ |
| ក្រសួងយុត្តិធម៌ សហការជាមួយអង្គការអាស៊ាន-អូស្រ្តាលី | ០១ | ៤៥ | ១២ |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយអង្គការ( LSCW), DFAT , GAC និងអង្គការពលកម្មអន្តរជាតិ (ILO) | ៤១៣ | ២១.០៨៩ | ១០.៦៨២ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយអង្គការ IOM, អង្គការតេនៈអ៊ីនធើណេសិនណល, អង្គការ (JICA),អង្គការ APLE និងអង្គការអាស៊ាន-អូស្រ្តាលី | ០៥ | ១៥៥ | ៧៩ |
| ក្រសួងសុខាភិបាលសហការជាមួយអង្គការ IOM | ០១ | ៦៧ | ២៤ |
| ក្រសួងអប់រំ យុវជន និងកីឡា | ០៣ | ៨៩ | ២៨ |
| ក្រសួងទេសចរណ៍ | ០៣ | ២០០ | ៧៣ |
| ក្រសួងព័ត៌មាន បានសហការជាមួយគណៈកម្មាធិការជាតិ គ.ជ.ប.ជ | ០១ | ១៣៨ | ៤៥ |
| ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ០៦ | ២៣៤ | ៩៨ |
| ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ០១ | ១៨០ | ៤៨ |
| អង្គការ ILO (ខេត្តសៀមរាប) | ០៥ | ១៧២ | ៨៤ |
| អង្គការហោការ(ខេត្តសៀមរាប) | ០១ | ៤០ | ២២ |
| អង្គការជេហានថ្មីដំបូងកម្ពុជា(ខេត្តសៀមរាប) | ០៣ | ១១៤ | ៥៤ |
| អង្គការសម្ព័ន្ធចាប់ដៃ(ខេត្តកំពង់ចាម) | ០១ | ៤៣ | ១៥ |
| អង្គការ UNICEF | ០១ | ៧០ | ២៣ |
| សរុប | ៤៤៩លើក | ២២.៩១៨នាក់ | ១១.៣៩០នាក់ |
| **ថ្នាក់ក្រោមជាតិ** | | | |
| ខេត្តបន្ទាយមានជ័យ សហការជាមួយអង្គការបេសកកម្មអន្តរជាតិ IJM | ០១ | ១០៧ | ៣៥ |
| ខេត្តពោធិ៍សាត់ សហការជាមួយអង្គការអង្គការម្លប់ឬស្សី | ០១ | ៤០ | ២៥ |
| ខេត្តកណ្តាល សហការជាមួយអង្គការក្តីសង្ឃឹម និងយុត្តិធម៌ | ០៤ | ១៧៤ | ៧២ |
| ខេត្តស្វាយរៀង | ០១ | ៨០ | ៣៥ |
| សរុប | ០៧លើក | ៤០១នាក់ | ១៦៧នាក់ |
| សរុបរួម | ៤៥៦លើក | ២៣.៣១៩នាក់ | ១១.៥៥៧នាក់ |

### ២.២. សិក្ខាសាលាក្រៅប្រទេស

▪ **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖** អគ្គលេខាធិការរង ទទួលបន្ទុកកិច្ចសហប្រតិបត្តិការអន្តរជាតិ បានដឹកនាំប្រតិភូអញ្ជើញចូលរួមសិក្ខាសាលាពិគ្រោះយោបល់ (Consultation Workshop on Standard procedures and criteria for victim verification and identification) ស្តីពីនីតិវិធីស្តង់ដារ និងលក្ខណៈវិនិច្ឆ័យសម្រាប់ការផ្ទៀងផ្ទាត់ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដែលរៀបចំដោយ COMMIT វៀតណាម ដែលមាន ៦ប្រទេសចូលរួម ចំនួន ៣៤នាក់ ដូចជាប្រទេស (កម្ពុជា វៀតណាម ឡាវ ថៃ មីយ៉ាន់ម៉ា និងប្រទេសចិន) ក្នុងនោះមានការចូលរួមពីអង្គការ ILO និងអង្គការ IOM នៅក្រុងហាណូយ សាធារណៈរដ្ឋវៀតណាម។

## ខ. កិច្ចប្រជុំ សន្និសីទ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ១. កិច្ចប្រជុំក្នុងប្រទេស និងក្រៅប្រទេស

### ១.១. កិច្ចប្រជុំក្នុងប្រទេស

សមាជិកនៃគ.ជ.ប.ជ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយអង្គការដៃគូពាក់ព័ន្ធ រៀបចំកិច្ចប្រជុំដើម្បីពង្រឹងសមត្ថភាព ដល់មន្ត្រីពាក់ព័ន្ធ សរុបចំនួន **៧១៤**លើក មានអ្នកចូលរួមចំនួន **១៣.៧៥៣**នាក់ ក្នុងនោះមានស្ត្រី **៦.៧៧២**នាក់ដូចមានក្នុងតារាងខាងក្រោម៖

ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានសហការជាមួយអង្គការដៃគូ បានរៀបចំកិច្ចប្រជុំពិភាក្សា ដោយផ្ទាល់ និងតាមប្រព័ន្ធ Zoom ដើម្បីពង្រឹងសមត្ថភាពការងារដល់មន្ត្រីពាក់ព័ន្ធ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្តីពី៖ **១**-លើផែនការសកម្មភាពសម្រាប់អនុវត្ត «នីតិវិធីប្រតិបត្តិស្តង់ដា ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ និងពិនិត្យឡើងវិញនូវឧបសម្ព័ន្ធ ដែលបានពិភាក្សារួច នៃផែនការសកម្មភាពនៃនីតិវិធីប្រតិបត្តិបទដ្ឋាន (SOP) សម្រាប់ការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស»។ **២**-ការពិនិត្យនិងពិភាក្សារបាយការណ៍សិក្សារៀបចំដោយវិទ្យាស្ថានអភិវឌ្ឍន៍បរទេស (ODI) តាមប្រព័ន្ធអនឡាញ។ **៣**-ការកែសម្រួលរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងទិសដៅឆ្នាំ២០២៣។ **៤**-ពិភាក្សាអំពីផែនការសកម្មភាពដែលត្រូវអនុវត្តដោយអង្គការដៃគូលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៣។ **៥**-កិច្ចសហការ សម្រាប់ការអនុវត្តគម្រោងបង្ការទប់ស្កាត់ភាពងាយរងគ្រោះនៃអំពើជួញដូរមនុស្ស។ ១២-វាយតម្លៃពាក់កណ្តាលអាណត្តិ ពីលទ្ធផលការងារ បញ្ហាប្រឈម និងលើកផែនការបន្តឆ្នាំ២០២៣។ **៦**-បូកសរុបរបាយការណ៍ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ២០២២។ **៧**-ការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ ការធ្វើអាជីវកម្មផ្លូវភេទ។ **៨**-ពិនិត្យវឌ្ឍនភាព នៃការគ្រប់គ្រងមណ្ឌលទទួលពលករកំរៀង។ **៩**-លទ្ធផល នៃការសិក្សាស្រាវជ្រាវ និងវិភាគអំពីស្ថានភាពអាជីវកម្មផ្លូវភេទលើកុមារ។ **១០**-ត្រៀមរៀបចំបូកសរុបរបាយការណ៍ឆមាសទី១ និងលើកទិសដៅឆមាសទី២ ឆ្នាំ២០២៣។ **១១**-ការត្រៀមរៀបចំទិវាជាតិអន្តរសានាប្រឆាំងការជួញដូរមនុស្សលើកទី៧ ឆ្នាំ២០២៣។ ១២-សម្រាប់ការគ្រប់គ្រងករណីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស។ **១២**-ដើម្បីដោះស្រាយបញ្ហាពលករដែលកំពុងស្នាក់នៅដែលគ្មានឯកសារ និងកំពុងប្រើប្រាស់ឯកសារធ្វើការងារដែលផុតសុពលភាព នៅប្រទេសថៃ។ **១៣**-ការពិនិត្យនិងសម្រេចផែនការជាតិសម្រាប់ការអនុវត្តកតិកាសញ្ញាពិភពលោក និងស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់។ **១៤**-ការរៀបចំរបាយការណ៍សង្ខេបឆ្លើយតបទៅនឹងអនុសាសន៍របស់ស្ថានទូតអាមេរិកប្រចាំកម្ពុជា។ ១៥-ការត្រៀមរៀបចំទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៣។ "ការសម្របសម្រួលរួមរបស់គំពោងអភិវឌ្ឍន៍សមត្ថភាពសម្រាប់ជួយដល់ជនរងគ្រោះដែលរួចផុតពីការជួញដូរមនុស្ស"។

| សកម្មភាពរៀបចំកិច្ចប្រជុំរបស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការដៃគូ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្រី |
|---|---|---|---|
| **ថ្នាក់ជាតិ** | | | |

| | | | |
|---|---|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សការជាមួយអង្គការ AIM, ASEAN-Act, Caritas Cambodia, Chab Dai, CWCC, ERIKS, IJM, IOM, LSCW, និង អង្គការ Marici | ១៥០ | ១.០៩០ | ៦១០ |
| ក្រសួងកិច្ចការនារីសហការជាមួយអង្គការ (UNDP, &IOM) | ០៦ | ៣៩៧ | ១៧២ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយអង្គការ IOM និងអង្គការ JICA | ០២ | ៦៣ | ១៩ |
| ក្រសួងអប់រំ យុវជន និងកីឡា | ០៦ | ១១៣ | ៣៦ |
| អង្គការ IOM(ខេត្តបន្ទាយមានជ័យ) | ០១ | ៣៥ | ១១ |
| អង្គការ ILO (ខេត្តបាត់ដំបង) | ០១ | ៤៤ | ២២ |
| អង្គការ IOM សហការជាមួយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | ០២ | ៩៧ | ២៩ |
| អង្គការ Terre des Hommed សហការជាមួយគណៈកម្មធិការជាតិ គ.ជ.ប.ជ និងអង្គការ UNFPA | ០១ | ២៦ | ០៩ |
| អង្គការ IJM សហការជាមួយក្រសួង ស.អ.យ | ០២ | ២៨ | ០៩ |
| អង្គការសម្ព័ន្ធចាប់ដៃ(ខេត្តកំពង់ចាម) | ០២ | ៦១ | ០៤ |
| **សរុប** | **១៧៣លើក** | **១.៩៥៤នាក់** | **៩២១នាក់** |
| **ថ្នាក់ក្រោមជាតិ** | | | |
| ខេត្តបន្ទាយមានជ័យ | ១៣ | ២៦៥ | ១០០ |
| ខេត្តបាត់ដំបង | ០៩ | ២៣៩ | ៨២ |
| ខេត្តសៀមរាប | ៨៤ | ២.២០២ | ៩៧១ |
| ខេត្តឧត្តរមានជ័យ | ០៥ | ៨៦៦ | ៣៨២ |
| ខេត្តព្រះវិហារ | ០២ | ៥៥ | ២០ |
| ខេត្តប៉ៃលិន | ០៥ | ២៦២ | ៥៧ |
| ខេត្តកំពង់ធំ | ០៤ | ៩០ | ៥២ |
| ខេត្តស្ទឹងត្រែង | ០៧ | ២០៩ | ១៥៩ |
| ខេត្តក្រចេះ | ០២ | ១៩ | ១១ |
| ខេត្តកំពង់ចាម | ០៧ | ៦៩ | ៣៧ |
| ខេត្តត្បូងឃ្មុំ | ២៥ | ២.១៦៩ | ១.៣៦១ |
| ខេត្តស្វាយរៀង | ២៧ | ១៣៧ | ៨៩ |
| ខេត្តកណ្ដាល | ៨៣ | ១.៩៦៦ | ១.១១៥ |
| ខេត្តព្រៃវែង | ១១ | ៤៨១ | ១៦២ |
| ខេត្តកំពង់ស្ពឺ | ១៤ | ២០៨ | ៨៨ |
| ខេត្តតាកែវ | ១៤៧ | ៨៦៤ | ៤៥៧ |
| ខេត្តកែប | ០៣ | ៣៦ | ១៨ |
| ខេត្តកំពត | ៤៩ | ៥៨២ | ៣០២ |

| | | | |
|---|---|---|---|
| ខេត្តកំពង់ឆ្នាំង | ៣៧ | ៧៥៤ | ២១១ |
| ខេត្តរតនគិរី | ០១ | ១៤ | ០៥ |
| ខេត្តមណ្ឌលគិរី | ០៤ | ១៩០ | ៧៩ |
| ខេត្តកោះកុង | ០២ | ១២២ | ៩៣ |
| **សរុប** | **៥៤១លើក** | **១១.៧៩៩នាក់** | **៥.៨៥១នាក់** |
| **សរុបរួម** | **៧១៤លើក** | **១៣.៧៥៣នាក់** | **៦.៧៧២នាក់** |

## ១.២. កិច្ចប្រជុំនៅក្រៅប្រទេស

❖ **ថ្នាក់ជាតិ**

▪ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖**

– លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំគណៈប្រតិភូ អញ្ជើញចូលរួមកិច្ចប្រជុំ៖ (១)-បច្ចេកទេស និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីកិច្ច នៃសន្និសីទ Bali Process ដែលមានវេទិការដ្ឋាភិបាល និងវិស័យឯកជន ពិភាក្សាអំពីទម្រង់ថ្មី នៃអំពើរត់ពន្ធមនុស្ស ការប្រពលកម្មដោយបង្ខំ និងអំពើជួញដូរមនុស្ស (Bali process Conference: the government and Business Forum on People Smuggling Forced Labor and Drafficking in persens) ដែលផ្សារភ្ជាប់ជាមួយនឹងការប្រើប្រាស់បច្ចេកវិទ្យាពត៌មានទំនើប និងពិបាកស្វែងរកជនល្មើសដើម្បីផ្តន្ទាទោស ដែលធ្វើឡើងនៅប្រទេសអូស្ត្រាលី, (២)-ថ្នាក់តំបន់ ស្តីពីអំពើពុករលួយពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស (TiP) និងអំពើរត់ពន្ធជនទេសន្តរប្រវេសន៍ (SOM) នៅទីក្រុងបាងកក ប្រទេសថៃឡង់ដ៍ ដែលរៀបចំដោយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC)។

▪ **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ៖**

– អគ្គលេខាធិការ បានដឹកនាំគណៈប្រតិភូមួយរូប អញ្ជើញទស្សនកិច្ចមជ្ឈមណ្ឌលអូស្ត្រាលីប្រឆាំងការកេងប្រវ័ញ្ចកុមារ(ACCCE) នៅប្រទេសអូស្ត្រាលី ដើម្បីសិក្សាស្វែងយល់អំពីមជ្ឈមណ្ឌលនេះ ដែលប្រតិបត្តិការដោយនគរបាលសហព័ន្ធអូស្ត្រាលី(AFP) គឺជាស្ថាប័នថ្នាក់ជាតិមួយធ្វើការងារផ្តោតលើការប្រឆាំងរាល់ទម្រង់នៃការកេងប្រវ័ញ្ចកុមារ និងមានគាំទ្រដោយស្ថាប័នមានសមត្ថកិច្ច ក្នុងការអនុវត្តសកម្មភាពបញ្ឈប់ និងផ្តន្ទាទោសបទល្មើសកេងប្រវ័ញ្ចកុមារ និងសង្គ្រោះជនរងគ្រោះឱ្យផុតពីគ្រោះថ្នាក់។

– អគ្គលេខាធិការរង ទទួលបន្ទុកកិច្ចសហប្រតិបត្តិការអន្តរជាតិ បានដឹកនាំប្រតិភូអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សា៖ (១)-ថ្នាក់តំបន់ ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការ ដើម្បីបង្ការអំពើជួញដូរមនុស្ស បណ្តាលមកពីការរំលោភបំពាន តាមប្រព័ន្ធបច្ចេកវិទ្យា នៅសណ្ឋាគារ Pullman ទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី។ កិច្ចប្រជុំនេះរៀបចំប្រទេសឥណ្ឌូនេស៊ី សហការជាមួយអង្គការ IOM មានសមាសភាពចូលរួមសរុប ៧០នាក់(ស្រី ១២នាក់) មកពីប្រទេសចិន ស្រីលង្កា ឥណ្ឌា អាមេរិក អូស្ត្រាលី និងប្រទេសកេនយ៉ា, (២)-ស្តីពីតួនាទីនៃបច្ចេកវិទ្យា ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការរត់ពន្ធជនចំណាកស្រុក នៅក្នុងទីក្រុងម៉ានីល ប្រទេសហ្វីលីពីន រៀបចំដោយស្ថាប័ន Regional Support Office (RSO) សហការជាមួយ Inter-Agency Council Against Trafficking (IACAT) ក្រោមជំនួយឧបត្ថម្ភរបស់ IOM មានសមាសភាពចូលរួមសរុប ៤៣នាក់(ស្រី ២២នាក់, (៣)-ក្នុងកម្មវិធីសុវត្ថិភាព និងតម្លាភាពស្តីពីការសម្រេចសិទ្ធិ និងឱកាសរបស់ពលករទេសន្តរប្រវេសន៍ជាស្ត្រី នៅក្នុងតំបន់អាស៊ាន ២០១៨ - ២០២៣ នៅប្រទេសថៃឡង់ដ៍ ដែលរៀបចំដោយអង្គការ UN Women គាំទ្រដោយសភាអ៊ឺរ៉ុប EU និងអង្គការ ILO ដែលមានសមាសភាពចូលរួមពី បណ្តាប្រទេសរួមមាន កម្ពុជា ថៃ វៀតណាម ឡាវ ម៉ាឡេស៊ី ហ្វីលីពីន និងលេខាធិការដ្ឋានអាស៊ាន ដែលមានអ្នកចូលរួមសរុបចំនួន ១០០នាក់។

– អគ្គលេខាធិការរង ទទួលបន្ទុកកិច្ចការទេសន្តរប្រវេសន៍ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានដឹកនាំប្រតិភូអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពី "កិច្ចប្រជុំឆ្លងកាត់ព្រំដែនដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកសុខភាពជនទេសន្តរប្រវេសន៍ រវាង ព្រះរាជាណាចក្រថៃ-ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមេនិតឡាវ" នៅខេត្ត អ៊ូ ប៊ុន ប្រទេសថៃឡង់ដ៍។

– អគ្គលេខាធិការរង ទទួលបន្ទុកកិច្ចការអនុវត្តច្បាប់ បានអញ្ជើញចូលរួមវេទិកាអាស៊ាន ស្តីពីសិទ្ធិមនុស្សក្នុងលំហសមុទ្រ (ជានាឱ្យមានការងារសមរម្យចំពោះពលករនេសាទ ជាពិសេសជនចំណាកស្រុកជាពលករនេសាទ)។ដោយមានការចូលរួមពីបណ្តាប្រទេសក្នុងអាស៊ាន ដូចជាប្រទេសថៃ កម្ពុជា វៀតណាម ឡាវ មីយ៉ាន់ម៉ា ម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងប្រទេសហ្វីលីពីន ក្នុងនោះតំណាងAICHR លេខាធិការអាស៊ាន វិស័យឯកជន ព្រមទាំងអង្គការ IOM និងIJM សរុប៤៦នាក់ ស្រី១៨នាក់ នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី។

❖ ថ្នាក់ក្រោមជាតិ

▪ **ខេត្តបន្ទាយមានជ័យ៖** ប្រធានគណៈកម្មាធិការ (គខបជ) បានដឹកនាំក្រុមការការងារចូលរួមប្រជុំពិភាក្សាការងារជាមួយភាគីថៃ ស្តីពី៖ (១)-ការស្វែងរកដំណោះស្រាយលើបញ្ហាប្រឈមនានានៅតាមព្រំដែន, (២)-នីតិវិធីបទដ្ឋានមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ, (៣)-ការបន្តលើឧបសម្ព័ន្ធ នៃផែនការសម្មភាពនីតិវិធីប្រតិបត្តិបទដ្ឋានសម្រាប់ការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ។

▪ **ខេត្តព្រះវិហារ៖** ប្រធានគណៈកម្មាធិការ គ.ខ.ប.ជខេត្ត បានចូលរួមប្រជុំពិភាក្សាជាមួយក្រុមការងារជាមួយភាគីថៃ នៅច្រកព្រំដែនអានសេះ ស្តីពីកិច្ចសហប្រតិបត្តិការល្អក្នុងកាបង្ការទប់ស្កាត់បទល្មើសឆ្លងដែនខុសច្បាប់។

▪ **ខេត្តមណ្ឌលគិរី៖** (១)-ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ដោយមានកិច្ចសហប្រតិបត្តិការការងារ គណៈចលនាមហាជនបានទៅចូលរួមប្រជុំពិភាក្សា រវាងខេត្តមណ្ឌលគិរី និងខេត្តដាក់ណុង ប្រទេសវៀតណាម ដើម្បីរឹតចំណងការកសាងខ្សែបន្ទាត់ព្រំដែនសន្តិភាព ពិសេសបន្តរួមគ្នាផ្សព្វផ្សាយទប់ស្កាត់អំពើជួញដូរមនុស្ស ពិសេសស្ត្រី និងកុមារ និងបទល្មើសឆ្លងដែនខុសច្បាប់គ្រប់ប្រភេទ ខេត្តដាក់ណុង ប្រទេសវៀតណាម, (២)-ក្រុមការងារយេនឌ័រដឹកនាំដោយស្នងការរងខេត្ត បានចូលរួមប្រជុំពិភាក្សាជាមួយក្រុមការងារយេនឌ័រនៅខេត្តដាក់ឡាក់ ប្រទេសវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការល្អក្នុងកាបង្ការទប់ស្កាត់បទល្មើសជួញដូរមនុស្ស និងការរំលោភបំពានលើស្ត្រី និងកុមារ។

## ២. ទស្សនកិច្ច

❖ ថ្នាក់ជាតិ

▪ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំក្រុមការងារអគ្គលេខាធិការ គ.ជ.ប.ជ, ប្រធានអង្គការការីតាស់ស្វីស ព្រមទាំងសហការី និងប្រតិភូមកពីប្រទេសស្វីសទៅធ្វើទស្សនកិច្ចនៅមណ្ឌលកំរៀង និងច្រកទ្វារព្រំដែនអន្តរជាតិដូង ដើម្បីសិក្សាស្វែងយល់អំពីពលរដ្ឋខ្មែរ និងថៃ ដែលបានធ្វើដំណើរចេញ និងចូលតាមច្រកព្រំដែននេះ។

❖ ថ្នាក់ក្រោមជាតិ

▪ **ខេត្តបន្ទាយមានជ័យ៖** ក្រុមការងារគណៈកម្មការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដឹកនាំសម្របសម្រួល ចុះបំពេញទស្សនកិច្ចដើម្បីត្រួតពិនិត្យសំភារៈសោតទស្សន៍ ដែលបានផ្តល់ជូនកន្លែងមកនៅច្រកចេញចូលតែមួយ មណ្ឌលសំចតប៉ោយប៉ែត ច្រកទ្វាព្រំដែនបឹងត្រកួន សរុបសមាសភាពចំនួន ១០នាក់ ស្រី ០២នាក់។

### ៣. ជំនួបពិភាក្សាការងារ

❖ **ថ្នាក់ជាតិ**

▪ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** ក/-លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំក្រុមការងារជំនាញនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ទទួលជួបពិភាក្សាការងារជាមួយ៖ (១)-លោកស្រីបណ្ឌិត Brandais York ទីប្រឹក្សានៃអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) ដើម្បីសំណេះសំណាល អំពីព័ត៌មានពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស, (២)-អង្គការទេសន្តរប្រវេសន៍អន្តរជាតិ និងអង្គការ IJM លើកម្មវិធីបណ្តុះបណ្តាលការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប, (៣)-អង្គការការីតាសស្វីស និងសំណេះសំណាល ស្តីពីការងារពាក់ព័ន្ធនឹងការប្រឆាំងការជួញដូរមនុស្ស ជាពិសេសគម្រោងសុវត្ថិភាពទេសន្តរប្រវេសន៍នៅកម្ពុជា, (៤)-អង្គការអេ២១ ស្តីពីគម្រោងថតវីដេអូឯកសារអប់រំ ពាក់ព័ន្ធស្ថានភាពរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស, (៥)-លោកស្រី Emelita S. Goddard នាយកអង្គការ World Hope International ប្រចាំនៅកម្ពុជា និងលោក Sam Schleipman ប្រធានផ្នែកអភិវឌ្ឍន៍និងកិច្ចសហប្រតិបត្តិការ ដើម្បីពិភាក្សាអំពីការងារប្រឆាំងការជួញដូរមនុស្ស, (៦)-តំណាងអង្គការវីនរ៉ក់អន្តរជាតិ ដើម្បីពិភាក្សាអំពីកិច្ចសហការរវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការវីនរ៉ក់អន្តរជាតិ ក្នុងអាណត្តិថ្មីនៃរាជរដ្ឋាភិបាលកម្ពុជា, (៧)-តំណាងអង្គការអាស៊ានអាក់ (ASEAN ACT) ដើម្បីពិភាក្សាអំពីកិច្ចសហការរវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការអាស៊ានអាក់ ក្នុងអាណត្តិថ្មីនៃរាជរដ្ឋាភិបាលកម្ពុជា, (៨)-ជាមួយក្រុមការងារបច្ចេកទេសនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីពិភាក្សាអំពីការរៀបចំយន្តការបញ្ជូនជនរងគ្រោះថ្នាក់ជាតិ, (៩)-តំណាង អង្គការ IJM អំពីវគ្គបណ្តុះបណ្តាលបែបបទនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពីការផ្សព្វផ្សាយរបាយការណ៍ស្រាវជ្រាវរបស់អង្គការ IJM, (១០)-តំណាងផ្នែកគោលនយោបាយ នៃស្ថានទូតអាមេរិក ប្រចាំនៅកម្ពុជា អំពីរបៀបវារៈដែលភាគីស្ថានទូតអាមេរិក ស្នើដាក់បញ្ចូលសម្រាប់កិច្ចប្រជុំរវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងស្ថានទូតអាមេរិក ស្តីពីរបាយការណ៍ប្រឆាំងការជួញដូរមនុស្សរបស់សហរដ្ឋអាមេរិក (US TIP Report), (១១)-កញ្ញា **គ្រីស្ទីន** នាយិកាអង្គការមូលនិធិអេ២១ ដើម្បីពិនិត្យខ្សែភាពយន្តអប់រំ ក្រោមចំណងជើងថា "តើអ្នកឃើញខ្ញុំទេ? Can you see me!" ក្នុងគោលបំណងប្រមូលមតិយោបល់ត្រឡប់ ដើម្បីសម្រេចបញ្ចប់ផលិតកម្ម និងចាក់ផ្សាយជាសាធារណៈ, (១២)-លោកជំទាវ **Cyndy Dyer** ឯកអគ្គរដ្ឋទូតជាន់ខ្ពស់នៃសហរដ្ឋអាមេរិក ទទួលបន្ទុកកិច្ចការប្រឆាំងការជួញដូរមនុស្ស ដើម្បីសិក្សាបន្ថែមអំពីបទពិសោធការងាររបស់ គ.ជ.ប.ជ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស, (១៣)-ឯកឧត្តម **ហ៊ុន សារឿន** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព ប្រចាំនៅព្រះរាជាណាចក្រថៃ និងជាមួយតំណាងទូតថៃ ដើម្បីធ្វើការសិក្សាស្វែងយល់ និងទទួលព័ត៌មាននូវកិច្ចដំណើរការ ផ្តល់សេវានានា ជូនដល់ពលករ ពលរដ្ឋខ្មែរផងដែរ, (១៤)-តំណាងស្ថាប័ន កម្មវិធីធានារ៉ាប់រងសុខភាព (Migration-Fund (M-Fund)ដែលមានការិយាល័យ នៅប្រទេសថៃ ដែលជាគម្រោងធានារ៉ាប់រង សុខភាពស្ម័គ្រចិត្ត ដែលមានតំលៃទាប និងមិនស្វែងរកប្រាក់ចំណេញ សម្រាប់ជនចំណាកស្រុកដែលកំពុងប្រតិបត្តិការនៅតាមព្រំដែន, (១៥)-គណៈប្រតិភូអង្គការ សហប្រជាជាតិ ឯកឧត្តម Joseph Scheuer តំណាងអង្គការសហប្រជាជាតិ, លោកស្រី Roueida El Hage តំណាងឧត្តមស្នងការសិទ្ធិមនុស្ស OHCHR, លោកស្រី Alissa Chaker តំណាងអង្គការ UNDP និងលោកស្រី Kristin Parco ប្រធានបេសកកម្មអង្គការ IOM ដែលប្រចាំនៅកម្ពុជា ស្តីពី បញ្ហា នៃអំពើជួញដូរមនុស្សនៅកម្ពុជា(ដោយផ្តោតលើរបាយការណ៍របស់ គ.ជ.ប.ជ ដែលត្រូវធ្វើការកែលម្អនីតិវិធីនៃការផ្សព្វផ្សាយទិន្នន័យ), និង ការពិនិត្យជំហានបន្ទាប់ លើអនុសាសន៍ ដើម្បីបន្តពង្រឹងកិច្ចសហការឱ្យកាន់តែប្រសើរ។

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានទទួលជួបពិភាក្សាការងារជាមួយ៖ (១)- ប្រធានអង្គការវីនរ៉ក់អន្តរជាតិនៅកម្ពុជា លើកិច្ចសហប្រតិបត្តិការក្នុងការអនុវត្តផែនការសកម្មភាពនៃអនុស្សរណៈយោគយល់គ្នា រវាង

ព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស, (២)-ប្រធានអង្គការអន្តរជាតិទេសន្តរប្រវេសន៍(IOM)ប្រចាំតំបន់អាស ប៉ាស៊ីហ្វិកថ្មីស្ដីពីការអនុវត្តគម្រោងកាត់បន្ថយភាពក្រីក្រតាមរយៈការធ្វើចំណាកស្រុកដោយសុវត្ថិភាព ការកសាងជំនាញនិងលើកកម្ពស់ការរកការងារឱ្យធ្វើនៅបរទេស (PROMISE) ដំណាក់កាលទី១ និងដំណាក់កាលទី២, (៣)-តំណាងអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ស្ដីពីកិច្ចអន្តរាគមន៍ជួយជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចកម្លាំងពលកម្មក្នុងស្រុក និងឆ្លងដែន, (៤)-អ្នកសម្របសម្រួលថ្នាក់ជាតិនៃអង្គការ ILO ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការក្នុងការងារទេសន្តរប្រវេសន៍ការងារ ដូចជាការរៀបចំគោលនយោបាយជាតិ ស្ដីពីទេសន្តរប្រវេសន៍ការងារ ការពិនិត្យលើតម្លៃសេវាជ្រើសរើសពលករទៅធ្វើការនៅប្រទេសថៃ និងការបន្តពិភាក្សាជាមួយភាគីថៃ ដើម្បីរៀបចំកិច្ចព្រមព្រៀងទាក់ទងនឹងពលករផ្នែកនេសាទ។

▪ **ក្រសួងកិច្ចការនារី៖** លោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងជាអនុប្រធាន គ.ជ.ប.ជ បានដឹកនាំក្រុមការងារ និងមានសហការទទួលជួបពិភាក្សាការងារជាមួយ៖ (១)-លោកសាស្ត្រាចារ្យ Sheldon Zhang នាយកមហាវិទ្យាល័យផ្នែកឧក្រិដ្ឋកម្ម និងយុត្តិធម៌នៃសាកលវិទ្យាល័យ University of Massachusetts និងលោកស្រី Rumi Kato Price សាស្ត្រាចារ្យមហាវិទ្យាល័យចិត្តវិទ្យា នៃមហាវិទ្យាល័យសុខាភិបាល សាកលវិទ្យាល័យ Washington University in St. Louis. ក្នុងការប្រមូលទិន្នន័យដើម្បីរៀបចំគម្រោងស្នើសុំថវិកាពីរដ្ឋាភិបាលសហរដ្ឋអាមេរិកពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ និងការប្រែប្រួលអាកាសធាតុនៅកម្ពុជា និងពិនិត្យលទ្ធភាពក្នុងការបង្កើតនូវប្រព័ន្ធត្រៀមបម្រុងទុកមុន ដើម្បីឆ្លើយតបនឹងអំពើជួញដូរមនុស្សនៅពេលមានវិបត្តិដូចជាគ្រោះមហន្តរាយ និងការរីករាលដាលនៃជំងឺឆ្លងជាដើម ដោយជ្រើសរើសយកខេត្តស្ថិតនៅជុំវិញបឹងទន្លេសាបជាខេត្តគោលដៅ, (២)-ជាមួយ**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** បានដឹកនាំក្រុមការងារជំនាញអន្តរក្រសួងស្ថាប័នដែលជាសមាជិកនៃគ.ជ.ប.ជ ជួបពិភាក្សាការងារជាមួយ ឯកឧត្តម W. Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការ និងបង្កើនប្រសិទ្ធភាព នៃការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា នឹងការអនុវត្តអនុសាសន៍របស់សហរដ្ឋ អាមេរិកដែលបានដាក់ជូនមករាជរដ្ឋាភិបាលកម្ពុជា។ (៣)-ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងក្រុមការងារខេមមីតកម្ពុជា ក្នុងគោលបំណងផ្សព្វផ្សាយលទ្ធផលនៃកិច្ចប្រជុំ ថ្នាក់រដ្ឋមន្ត្រីខេមមីតជាពិសេសពិភាក្សាពីតួនាទី ភារកិច្ច និងទិសដៅបន្តរបស់កម្ពុជាក្នុងការធ្វើជាប្រធាន ប្ដូរវេនខេមមីត និងស្ដីពីស្ថានភាពបច្ចុប្បន្ននៃអំពើជួញដូរមនុស្សនៅកម្ពុជា រៀបចំយន្តការ បញ្ជូនឆ្លងដែន និងយន្តការបញ្ជូនថ្នាក់ជាតិ ចែករំលែកបទពិសោធន៍ល្អៗ។

❖ ថ្នាក់ក្រោមជាតិ

▪ **ខេត្តបន្ទាយមានជ័យ៖** ក/-ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានជួបពិភាក្សាជាមួយ៖ (១)-តំណាង អង្គការទេសន្តរប្រវេសន្តអន្តរជាតិ IOM ទៅលើការត្រៀមរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ពង្រឹងសុវត្ថិភាព សុខភាពតាមរយៈការធ្វើផែនទីប្រជាជនចល័តក្នុងតំបន់ និងអនុតំបន់មេគង្គ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងពលករចំណាកស្រុក, (២).តំណាងមន្ទីរធម្មការ និងសាសនា ដើម្បីត្រៀមរៀបចំកម្មវិធីអន្តរសាសនាផ្សព្វផ្សាយ ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមប្រធានបទ «រួមគ្នាបញ្ឈប់ ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើគ្រប់រូបភាព»។ ខ/-ប្រធានមជ្ឈមណ្ឌលសំចតប៉ោយប៉ែត បានទទួលទស្សនៈកិច្ច និងសម្ដែងការគួរសម្យពីអង្គការកុមារឥតព្រំដែនអន្តរជាតិ ដើម្បីសិក្សាពីកិច្ចសហការផ្ដល់សេវាជូនកុមារ ពីការធ្វើចំណាកស្រុក និងកុមារវិលត្រឡប់ពីប្រទេសថៃ។

▪ **ខេត្តបាត់ដំបង៖** ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានទទួលជួបពិភាក្សាការងារជាមួយ៖ (១)-អង្គការសាម៉ារីតានកីសសង្គ្រោះអន្តរជាតិ ក្នុងគោលបំណងផ្ដល់នូវធាតុចូលសំខាន់ៗក្នុងការធ្វើយុទ្ធសាស្ត្រ៥ឆ្នាំ (២០២៣-២០២៨) ដើម្បីចូលរួមទប់ស្កាត់ការធ្វើចំណាកស្រុកខុសច្បាប់ និងការរំលោភបំពានលើយេនឌ័រ នៅសាលាខេត្តបាត់ដំបង, (២)-អង្គការវីនរ៉ក់ ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

- **ខេត្តសៀមរាប៖** លោកស្រី អនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានដឹកនាំក្រុមការងារ ជួបពិភាក្សាការងារជាមួយ៖ (១)-អង្គការយូនីសេហ្វប្រចាំកម្ពុជា ស្តីពីកិច្ចការពារកុមារ, (២)-ជាមួយអង្គការមូលនិធិអេ២១ និងអង្គការជីវិតនៅកម្ពុជា ដើម្បីរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីច្បាប់យុត្តិធម៌អនីតិជន ការកំណត់អត្តសញ្ញាណជនរងគ្រោះ កិច្ចការពារកុមារ និងការផ្តល់សេវាសមស្របដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស, (៣)-អង្គការអន្តរជាតិខាងការងារ (ILO) ស្តីពីការអនុវត្តកម្មវិធីនានារបស់ស្ថាប័ន និងអង្គការដៃគូពាក់ព័ន្ធ លើការផ្តល់ភាពអង់អាចទៅដល់ពលករទេសន្តរប្រវេសន៍, (៤)-អ្នកជំនាញការជប៉ុន (ទីប្រឹក្សាគម្រោងប្រចាំក្រសួង ស.អ.យ) ស្តីពីការផ្តល់សេវាជនរងគ្រោះដោយផ្តោតលើការកំណត់អត្តសញ្ញាណ ការការពារ ការវាយតម្លៃអំពីតម្រូវការ និងវិសាលភាពសម្រាប់ការកែសម្រួលគោលការណ៍ណែនាំ ស្តីពីការកំណត់អត្តសញ្ញាណ និងការកសាងយន្តការបញ្ជូន, (៥)-អង្គការអន្តរជាតិការងារ (ILO) ក្នុងការផ្តល់បទសម្ភាសន៍លើបទពិសោធន៍ នៃការផ្តល់សេវារបស់មជ្ឈមណ្ឌលទេសន្តរប្រវេសន៍ (កម្មវិធីសុវត្ថិភាព និងយុត្តិធម៌) និងបានចុះសម្ភាសន៍ជាមួយពលករទេសន្តរប្រវេសន៍ខុសច្បាប់ជាស្ត្រី ដើម្បីចងក្រងព័ត៌មានសម្រាប់ធ្វើការចែករំលែកទៅដល់ប្រជាពលរដ្ឋ អំពីហានិភ័យនៃការធ្វើចំណាកស្រុកខុសច្បាប់ដើម្បីស្វែងរកការងារធ្វើ។
- **ខេត្តកោះកុង៖** ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានជួបពិភាក្សាការងារស្តីពី យុត្តិធម៌សម្រាប់ពលករចំណាកស្រុកក្នុងវិស័យនេសាទ និងកែច្នៃម្ហូបអាហារ (JMFS) ជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារនិងស្ត្រី នៅសាលប្រជុំសាលាខេត្ត មានអ្នកចូលរួម ០៩នាក់ (ស្រី០ ៥នាក់)។
- **ខេត្តប៉ៃលិន៖** ប្រធានគណៈកម្មាធិការ គ.ខ.ប.ជ បានអនុញ្ញាត និងទទួលជួបពិភាក្សាការងារជាមួយ៖ (១)-មេបញ្ជាការយោធា ខេត្តចាន់បុរី ចូលជួបសម្តែងការគួរសម ពិភាក្សាការងារ និងបង្កើនទំនាក់ទំនងល្អ រវាងខេត្តប៉ៃលិន និងខេត្តចាន់បុរី, (២)-ប្រតិភូថៃ ដែលដឹកនាំដោយអភិបាលខេត្តចាន់បុរី ដើម្បីពង្រឹងចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងខេត្តនៅជាប់ព្រំដែន នៃប្រទេសទាំង២ ខេត្តប៉ៃលិន និងខេត្តចាន់បុរី ឱ្យបានកាន់តែល្អប្រសើរឡើងថែមទៀត បន្ទាប់ពីជម្ងឺកូវីដ-១៩ មានភាពជាប្រក្រតីឡើងវិញ និងដើម្បីទប់ស្កាត់រាល់បទល្មើសផ្សេងៗ ជាពិសេសទប់ស្កាត់ការឆ្លងដែនខុសច្បាប់។
- **ខេត្តកំពង់ស្ពឺ៖** អនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានដឹកនាំក្រុមការងារទាំង ៦ ទទួលជួបពិភាក្សាការងារជាមួយអង្គការផ្លូវច្បាប់ដល់កុមារ និងស្ត្រី ស្តីពីការជំរុញឱ្យទទួលបានភាពយុត្តិធម៌ និងសេវាគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស តាមប្រព័ន្ធវីដេអូ។
- **ខេត្តត្បូងឃ្មុំ** មន្ត្រីជំនាញនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានជួបពិភាក្សាជាមួយ៖ (១)-អង្គការJICA ដោយមានគោលបំណងសិក្សា វាយតម្លៃ ដើម្បីសម្រេចជ្រើសរើសយកខេត្តសម្រាប់អនុវត្តគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ខេត្តដែលអង្គការធ្វើការសិក្សាមមានតែខេត្តចំនួន ០៣ ដែលនឹងជ្រើសយកអនុវត្តគម្រោងនេះ, (២)-បានជួបពិភាក្សាជាមួយអង្គការសម្ព័ន្ធចាប់ដៃ និងអង្គការសេចក្តីសង្ឃឹមពិភពលោកអន្តរជាតិ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងនោះក៏មានគម្រោង និងសកម្មភាពរបស់ខ្លួនដែលបានកំពុងអនុវត្ត នាពេលបច្ចុប្បនេះ, (៣)-អង្គការក្តីសង្ឃឹមពិភពលោកអន្តរជាតិ(W.H.I) ស្តីពីការវាយតម្លៃគម្រោងពង្រឹងប្រព័ន្ធដែលផ្តោតសំខាន់ទៅលើការកសាងសមត្ថភាពរបស់អ្នកពាក់ព័ន្ធទៅនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការស្វែងយល់បន្ថែមទៀតពីតម្រូវការដើម្បីដាក់ចូលក្នុងគម្រោង ឆ្នាំ២០២៤។
- **ខេត្តកំពង់ចាម៖** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មន្ទីរកិច្ចការនារី និងស្នងការដ្ឋាននគរបាលខេត្ត បានចូលជួបប្រជុំពិភាក្សាជាមួយ អង្គការសម្ព័ន្ធចាប់ដៃ ដើម្បីលើកឡើងពីការផ្តល់វគ្គបណ្តុះបណ្តាល ស្តីពី «នីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស និងក្រមសីលធម៌ ក្នុងការការសម្ភាសន៍កំណត់អត្តសញ្ញាណជនរងគ្រោះ»។
- **ខេត្តព្រៃវែង៖** ស្នងការដ្ឋាននគរបាលខេត្ត បានជួបពិភាក្សាជាមួយអង្គការ IJM ដើម្បីចែករំលែកបទពិសោធន៍ និងបន្តពង្រឹងកិច្ចសហការលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

▪ **ខេត្តកណ្តាល៖** អនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានដឹកនាំក្រុមការងារ ទទួលជួបពិភាក្សាការងារជាមួយ៖ (១)-អង្គការអង្គការសកម្មភាពដើម្បីកុមារ (APLE) ស្តីពី «ការលើកកម្ពស់ការយល់ដឹង និងកម្មវិធីបណ្តុះបណ្តាល ដែលបន្សាំជាមួយផែនការសកម្មភាពប្រចាំឆ្នាំ២០២៣ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តកណ្តាល» តាមប្រព័ន្ធវីដេអូ សរុបអ្នកចូលរួមចំនួន ០៧នាក់ (ស្រី ០៤នាក់), (២)-ប្រតិភូទីភ្នាក់ងារអន្តរជាតិប្រទេសស៊ុយអែត (SIDA) ដែលគាំទ្រដោយអង្គការយូនីសេហ្វ ដើម្បីស្វែងយល់ពីការអនុវត្តសកម្មភាពកិច្ចការពារកុមារ សរុបអ្នកចូលរួមចំនួន ០៩នាក់ (ស្រី ០៣នាក់)។

▪ **ខេត្តកំពង់ឆ្នាំង៖** អនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានជួបពិភាក្សាការងារជាមួយតំណាង អង្គការណ្ហមីណេតរីកកម្ពុជា ស្តីពីវឌ្ឍនភាពរបស់ស្ត្រីទាក់ទងនឹងការអប់រំជំនាញវិជ្ជាជីវៈ សកម្មភាពសេដ្ឋកិច្ច ការធ្វើ ចំណាកស្រុក និងភាពងាយរងគ្រោះដោយអំពើជួញដូរមនុស្ស មានអ្នកចូលរួម ០៤នាក់ (ស្រី ០៣នាក់)។

### គ. ការខាសម្របសម្រួល

គ.ជ.ប.ជ/គ.រ.ប.ជ/គ.ខ.ប.ជ និងអង្គការដៃគូ បានចូលរួម និងសម្របសម្រួលក្នុងកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកម្មវិធីផ្សេងៗទៀត ដោយផ្ទាល់ និងតាមប្រព័ន្ធ Zoom ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយផ្អែកលើផែនការជាតិយុទ្ធសាស្ត្រជាតិទាំងបួន (ការបង្ការ ទប់ស្កាត់ ការការពារ និងជួយជនរងគ្រោះ ការពង្រឹងកិច្ចសហប្រតិបត្តិការ និងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបនឹងអំពើជួញដូរមនុស្ស) សរុបចំនួន **៩៩៥**លើក មានអ្នកចូលរួមសរុប **៧.០៦៣**នាក់ (ស្រី **៣.០៧៧**នាក់) ដូចមានក្នុងតារាងខាងក្រោម៖

| សកម្មភាពចូលរួមរបស់ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអង្គការដៃគូ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្រី |
|---|---|---|---|
| **ថ្នាក់ជាតិ** | | | |
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | ២៩៥ | ១.៦៩៦ | ៥៤៨ |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៤៥ | ១១៦ | ៦៨ |
| ក្រសួងអប់រំ យុវជន និងកីឡា | ១៦ | ៩៨ | ៣៥ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១០៨ | ៧៣៧ | ៤១២ |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០៦ | ៧៩ | ៣២ |
| ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ០៥ | ២២ | ១០ |
| ក្រសួងទេសចរណ៍ | ០៩ | ៤៧ | ១៩ |
| កាកបាទក្រហមកម្ពុជា | ០៤ | ៦០៦ | ២១០ |
| អង្គការរតនៈអ៊ីនធើណេសិនណល | ២៤ | ១៥៨ | ៦៩ |
| អង្គការមូលនិធិអេ ២១ | ១៥ | ៥២ | ៣៧ |
| **សរុប** | **៥២៧លើក** | **៣.៦១១នាក់** | **១.៤៤០នាក់** |
| **ថ្នាក់ក្រោមជាតិ** | | | |
| រាជធានីភ្នំពេញ | ១៩ | ៧៩ | ៤៥ |
| ខេត្តបន្ទាយមានជ័យ | ៥៤ | ៣៥០ | ១២៨ |
| ខេត្តព្រះវិហារ | ១៥ | ៥៤ | ៣២ |
| ខេត្តបាត់ដំបង | ៣៩ | ៩២០ | ៣៩៥ |
| ខេត្តពោធិ៍សាត់ | ១៣ | ៣៩ | ១៨ |
| ខេត្តសៀមរាប | ៥០ | ១៧២ | ១០៥ |

| | | | |
|---|---|---|---|
